ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត

មុខវិជ្ជា

# ភាសាខ្មែរ

សម្រាប់

## កម្រិតបឋមសិក្សា

២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៥០៥ អយក.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា កម្រិតបឋមសិក្សា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- តាមសំណើរបស់គណៈកម្មការនិងអនុគណៈកម្មការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល

## សម្រេច

**ប្រការ១.**

ប្រកាសដាក់ឱ្យប្រើជាផ្លូវការ "**កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតបឋមសិក្សា**" ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ប្រការ២ .-**

កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតបឋមសិក្សានេះ មានមាតិកាសំខាន់ៗ ដូចខាងក្រោម៖

- សេចក្តីផ្តើម
- គោលបំណង
- គោលគំនិតសំខាន់ៗ
- របាយម៉ោងសិក្សា
- ការណែនាំអនុវត្ត
- ការវាយតម្លៃ
- តារាងកម្មវិធីសិក្សា

ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតបឋមសិក្សាជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានបឋមសិក្សា ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង អយក
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ អគ.អរ

# បុព្វកថា

ការអប់រំជាវិស័យគន្លឹះមួយក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ បច្ចុប្បន្ននេះ សង្គមនិងសេដ្ឋកិច្ចមានការអភិវឌ្ឍនិងការរីកចម្រើនដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គមនិងសេដ្ឋកិច្ច។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកកាន់តែបើកចំហ ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន វិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែទំនើបនិងប្រសើរឡើង។ កត្តាទាំងនេះនាំឱ្យប្រទេសឬជាតិសាសន៍នានាខិតខំពង្រឹងធនធានមនុស្សរបស់ខ្លួន ដើម្បីតាមឱ្យទាន់និងអាចឈរជើងប្រកបដោយឧត្តមភាពក្នុងបរិបទថ្មីនៃសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោក។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មី ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវការកែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅដែលជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សានិងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត សំដៅលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលជាធាតុសំខាន់ក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នាតែប្រទាក់ក្រឡានិងគាំទ្រគ្នា។ កម្មវិធីសិក្សាលម្អិតកម្រិតបឋមសិក្សា បានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សា។ ការកែទម្រង់កម្មវិធីសិក្សានៅកម្រិតបឋមសិក្សា សំដៅបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញរបស់អ្នកសិក្សាលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានសម្រាប់ការអប់រំនៅកម្រិតបន្ត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារៈឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដាន វាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។

ថ្ងៃ អង្គារ [illegible] ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ឯកសារកម្មវិធីសិក្សាលម្អិតចំណេះទូទៅភាសាខ្មែរនៅបឋមសិក្សាពីថ្នាក់ទី១ដល់ថ្នាក់ទី៦នេះ ត្រូវបានរៀបចំឡើងយោងតាមគោលការណ៍នៃកំណែទម្រង់កម្មវិធីសិក្សា ក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស និងច្បាប់ស្ដីពីការអប់រំ។ ឯកសារនេះផលិតឡើងក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំផ្នែកបឋមសិក្សា ពិសេសផ្ដោតលើសកម្មភាពរៀននិងបង្រៀនទៅតាមសមត្ថភាពទាំងបួនគឺ ស្ដាប់ និយាយ អាន និងសរសេរ ក្នុងគោលបំណងអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដែលសិស្សត្រូវសម្រេចបានទៅតាមកម្រិតថ្នាក់នីមួយៗ។

ក្នុងកម្មវិធីសិក្សានេះ មានការកែលម្អទៅលើចំណុចមួយចំនួនដូចជា ខ្លឹមសារសំខាន់ៗ លទ្ធផលរំពឹងទុក របាយម៉ោង ការណែនាំអនុវត្ត ការវាយតម្លៃ និងវិធីសាស្ត្របង្រៀនសម្រាប់ជាជំនួយដល់ការអភិវឌ្ឍសៀវភៅសិក្សាគោល និងសម្ភារៈសិក្សាផ្សេងៗទៀត ដើម្បីជួយគ្រូបង្រៀនក្នុងការធ្វើបំណែងចែកកម្មវិធីសិក្សាប្រចាំខែ ការកំណត់សម្ភារៈឧបទេស និងការធ្វើកិច្ចតែងការបង្រៀន សំដៅពង្រឹងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់សិស្សឱ្យឆ្លើយតបទៅនឹងក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ។

កម្មវិធីសិក្សាលម្អិតនេះក៏បានកំណត់នូវលទ្ធផលសិក្សាទៅតាមកម្រិតថ្នាក់នីមួយៗ ដែលមានខ្លឹមសារសំខាន់ៗតាមលំដាប់លំដោយដូចជា សមាសភាគទាំងប្រាំនៃអំណានដំបូងមាន ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ វាក្យសព្ទ ការអានស្ទាត់ និងការយល់ន័យ។ លើសពីនេះនៅមានខ្លឹមសារសំខាន់ៗមួយចំនួនទៀតដូចជា ការរៀនពាក្យកន្សោមពាក្យ ឃ្លា ល្បះ កថាខណ្ឌ អត្ថបទផ្សេងៗ កំណាព្យ ចម្រៀង អក្សរផ្ចង់ សរសេរតាមអាន វេយ្យាករណ៍ និងតែងសេចក្ដី។ ក្រៅពីនេះ មានប្រធានបទផ្សេងៗទៀតដែលផ្សារភ្ជាប់នឹងជីវភាពជាក់ស្ដែងដូចជា ការប្រើសុជីវធម៌សង្គម ការចងក្រងឯកសារ ការធ្វើផែនការ ការធ្វើគម្រោង ការធ្វើបទបង្ហាញ ការធ្វើបទសម្ភាស ការសម្ដែងមតិយោបល់ ការសម្ដែងអារម្មណ៍ ការបញ្ចុះបញ្ចូលនិងការឆ្លើយតប ការនាំពាក្យ ការពន្យល់បកស្រាយ ការកាន់កម្មវិធី ការប្រើប្រាស់ប្រព័ន្ធបណ្ដាញសង្គម ការធ្វើទំនាក់ទំនង ការសរសេរលិខិតផ្សេងៗ។ល។

អនុគណៈកម្មការ សង្ឃឹមនិងមានជំនឿជាក់ថា កម្មវិធីសិក្សាលម្អិតចំណេះទូទៅសម្រាប់បឋមសិក្សានេះនឹងបានជាប្រយោជន៍ដល់ការប្រើប្រាស់នៅតាមសាលាបឋមសិក្សា អ្នកពាក់ព័ន្ធដទៃទៀត សំដៅធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត។

**អនុគណៈកម្មការ មុខវិជ្ជាឯកទេសភាសាខ្មែរ**

# មាតិកា


| | |
|---|---|
| ប្រកាស................................................................................................ | i |
| បុព្វកថា................................................................................................ | iii |
| អារម្ភកថា................................................................................................ | iv |
| មាតិកា................................................................................................ | v |
| ១- សេចក្តីផ្តើម................................................................................................ | 1 |
| ២- គោលបំណង................................................................................................ | 2 |
| ៣- គោលគំនិតៗសំខាន់ៗ................................................................................................ | 3 |
| ៤- របាយម៉ោងសិក្សា................................................................................................ | 10 |
| ៥- ការណែនាំអនុវត្ត................................................................................................ | 11 |
| ៦- ការវាយតម្លៃ................................................................................................ | 15 |
| ៧- តារាងកម្មវិធីសិក្សា................................................................................................ | 23 |
| ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១................................................................................................ | 23 |
| ៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី២................................................................................................ | 47 |
| ៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៣................................................................................................ | 65 |
| ៧.៤- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៤................................................................................................ | 81 |
| ៧.៥- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៥................................................................................................ | 96 |
| ៧.៦- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៦................................................................................................ | 113 |
| ៨- ឯកសារយោង................................................................................................ | 130 |
| ៩- បញ្ជីឈ្មោះគណៈកម្មការ................................................................................................ | 131 |

## ១- សេចក្តីផ្តើម

### ១.១- សារតារ

ក្រសួងអប់រំ យុវជននិងកីឡា បានធ្វើកំណែទម្រង់កម្មវិធីសិក្សា ជាបន្តបន្ទាប់ច្រើនលើកច្រើនគ្រាមកហើយ។ ដំណាក់កាលទី១ ចាប់ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៦ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តប្រព័ន្ធអប់រំ១០ឆ្នាំ គឺនៅបឋមសិក្សា៤ឆ្នាំ មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ។ ដំណាក់កាលនេះ វិស័យអប់រំយើងបានប្រមែប្រមូលអ្នកចេះដឹង ដែលនៅសល់ពីការសម្លាប់នៃរបបកម្ពុជាប្រជាធិបតេយ្យមកធ្វើជាគ្រូបង្រៀន ដោយអនុវត្តគោលការណ៍ អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ។ ដំណាក់កាលទី២ ចាប់ពីឆ្នាំ១៩៨៧ដល់ឆ្នាំ១៩៩៦ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ប្រព័ន្ធអប់រំចំណេះទូទៅ ដោយប្តូរពីប្រព័ន្ធអប់រំ១០ឆ្នាំ មកអនុវត្តប្រព័ន្ធអប់រំ១១ឆ្នាំ គឺនៅបឋមសិក្សា៥ឆ្នាំ មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ។ ក្នុងដំណាក់កាលនេះ យើងបានធ្វើការកែលម្អបន្ថែមលើរបាយម៉ោងសិក្សា និងខ្លឹមសារសំខាន់ៗមួយចំនួនជាពិសេសបានពង្រឹងនិងពង្រីកទៅលើផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រជាតិខ្មែរ។ ដំណាក់កាលទី៣ ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០៤ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ ដោយបានប្តូរពីប្រព័ន្ធអប់រំ១១ឆ្នាំ មកអនុវត្តប្រព័ន្ធអប់រំ១២ឆ្នាំ គឺនៅបឋមសិក្សា៦ឆ្នាំ មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ។ ក្នុងដំណាក់កាលនេះ បានកែសម្រួលលើ ទម្រង់ មុខវិជ្ជា របាយម៉ោង ខ្លឹមសារ វិធីសាស្ត្រ និងការអនុវត្ត។ ដំណាក់កាលទី៤ ចាប់ពីឆ្នាំ២០០៥ដល់ឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ និងបានធ្វើបច្ចុប្បន្នភាពលើកម្មវិធីសិក្សា ជាបន្តបន្ទាប់ថែមទៀតគឺ សិស្សសិក្សាតាមជម្រើសមុខវិជ្ជា និងសិក្សាតាមបណ្តុំមុខវិជ្ជាមានបណ្តុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ ដំណាក់កាលទី៥ នៅក្នុងឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់មួយលើកទៀត គឺបានអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សា និងកម្មវិធីសិក្សាថ្មីគ្រប់មុខវិជ្ជា ព្រមទាំងបានបន្ថែមមុខវិជ្ជាមួយចំនួនទៀត។ ក្នុងដំណាក់កាលនេះ បានកែសម្រួលលើ ទម្រង់ មុខវិជ្ជា របាយម៉ោង ខ្លឹមសារ វិធីសាស្ត្រ និងការអនុវត្ត សំដៅធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត ព្រមទាំងធ្វើឱ្យស្របតាមការវិវឌ្ឍយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចសង្គម និងវប្បធម៌ក្នុងតំបន់និងអន្តរជាតិ។

### ១.២- ការកែទម្រង់កម្មវិធីសិក្សា

ការកែទម្រង់កម្មវិធីសិក្សា ជានិន្នាការមួយស្របទៅនឹងការវិវត្តយ៉ាងលឿននៃសេដ្ឋកិច្ចសង្គមនិងវប្បធម៌កម្ពុជាក្នុងសម័យបច្ចុប្បន្ន និងស្របពេលដែលពិភពលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ ទស្សនវិជ្ជាថ្មី មានទំនោរកំណត់បញ្ចូលលទ្ធផលសិក្សា ជាគោលបំណងចម្បងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ បញ្ញត្តិនៃកម្មវិធីសិក្សាបានធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈ គោលគំនិត គរុកោសល្យ និងវិធីសាស្ត្របង្រៀន។ ការកែទម្រង់កម្មវិធីសិក្សា ជាផ្នែកមួយនៃកំណែទម្រង់វិស័យអប់រំនៅកម្ពុជា ដែលក្រសួងអប់រំ យុវជន និងកីឡា មានចក្ខុវិស័យ កសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជា ឱ្យក្លាយជាសង្គមរីកចម្រើន លើផ្នែកចំណេះដឹងនិងចំណេះធ្វើជាមូលដ្ឋាន។ ដើម្បីឆ្លើយតបនឹងចក្ខុវិស័យនេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំពីរចំណុចគឺ (១)ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត និង(២)ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំបានគឺត្រូវពឹងផ្អែកទៅលើសសរស្តម្ភទាំង៥មាន (១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២)ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោលនិងកែលម្អបរិស្ថាន (៣)ការដាក់ឱ្យអនុវត្តអធិការកិច្ច (៤)ការពង្រឹងវាយតម្លៃសិក្សាដូចជាការប្រឡង វាយតម្លៃថ្នាក់ជាតិ តំបន់

និងអន្តរជាតិ និង(៥)ការកែទម្រង់ឧត្តមសិក្សា។ ក្រសួងបានរៀបចំរចនាសម្ព័ន្ធដែលមានអនុវិស័យទាំង៧ក្នុងនោះមាន (១)អនុវិស័យការអប់រំកាយនិងកីឡា (២)អនុវិស័យការអភិវឌ្ឍយុវជន (៣)អនុវិស័យការអប់រំក្រៅប្រព័ន្ធ (៤)អនុវិស័យការអប់រំឧត្តមសិក្សា (៥)អនុវិស័យការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស (៦)អនុវិស័យការអប់រំបឋមសិក្សា និង(៧) អនុវិស័យការអប់រំកុមារតូច។ ដើម្បីសម្រេចបានជោគជ័យក្នុងវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីកំណែទម្រង់១៥ចំណុចគឺ (១)ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២)ការពង្រាយគ្រូបង្រៀន (៣)កំណែទម្រង់មជ្ឈមណ្ឌលបណ្ដុះបណ្ដាលគ្រូបង្រៀន (៤)ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (៥)ការងារអធិការកិច្ច (៦)វង្វាយតម្លៃលទ្ធផលសិក្សា (៧)កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ (៨)កំណែទម្រង់កម្មវិធីសិក្សានិងសៀវភៅសិក្សា (៩)ការសាងសង់អគារសិក្សានិងការជួសជុល (១០)ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា (១១) ការលើកកម្ពស់វិស័យកីឡា (១២)ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន (១៣)ការអប់រំបច្ចេកទេស (១៤)ការបង្កើតសាលារៀនជំនាន់ថ្មី និង(១៥)ការរៀបចំគន្លងអាជីព និងបណ្ដុះបណ្ដាលនាយកសាលា។

## ២- គោលបំណង

ការអប់រំនៅបឋមសិក្សា មានគោលបំណងបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈល្អប្រពៃ និងលើកកម្ពស់សមត្ថភាពផ្លូវកាយ ចិត្ត និងប្រាជ្ញាដល់កុមារា កុមារីកម្ពុជាទាំងអស់។ កម្មវិធីសិក្សានេះ ធានាឱ្យសិស្សទទួលបាននូវចំណេះដឹង និងបំណិនមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការរៀនអក្សរដំបូង។ សិស្សមាន បំណិនដោះស្រាយបញ្ហា ជួយរំលែកការលំបាក ចូលចិត្តរៀនសូត្រ ស្រឡាញ់ពលកម្ម ដើម្បីឱ្យពួកគេក្លាយជាមនុស្សមានប្រយោជន៍សម្រាប់គ្រួសារ សហគមន៍ និងសង្គម។ ជំរុញសិស្សឱ្យមានការរីកចម្រើនខាងគំនិត បញ្ញាស្មារតី និងអធ្យាស្រ័យ ហើយខិតខំបង្កលក្ខណៈឱ្យមានការអភិវឌ្ឍព្រមៗគ្នាខាងកោសល្យ ឥរិយាបថ តម្លៃ ការច្នៃប្រឌិត សីលធម៌សង្គម និងសិល្បៈសោភ័ណ។ ទន្ទឹមនឹងនេះត្រូវតែជំរុញឱ្យមាន កិច្ចសហការយ៉ាងជិតស្និទ្ធរវាងគ្រូ សិស្ស សាលារៀន គ្រួសារ និងសហគមន៍។ អភិវឌ្ឍចំណេះដឹងសិស្សទៅលើការប្រើប្រាស់ភាសាខ្មែរបានត្រឹមត្រូវតាមរចនាបថ និងរក្សានូវតម្លៃអរិយធម៌ វប្បធម៌ ប្រពៃណីជាតិ។ គោលបំណងនៃការសិក្សាមុខវិជ្ជាភាសាខ្មែរ សិស្សទទួលបាន៖

- ការអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា សម្រាប់ប្រាស្រ័យទាក់ទងគ្នាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។
- ការប្រើប្រាស់ភាសាខ្មែរជាយានក្នុងការអាននិងសរសេរបានត្រឹមត្រូវនឹងអាចបន្តការសិក្សា ទៅមុខវិជ្ជាដទៃទៀត។
- ការបញ្ចេញគំនិតផ្ទាល់ខ្លួនស្របតាមប្រធានបទសិក្សាបានត្រឹមត្រូវ។
- ការអភិវឌ្ឍចំណេះដឹង គឺបានចាប់ផ្ដើមឱ្យតម្លៃលើភាសាជាតិរបស់ខ្លួន និងចេះថែរក្សា ការពារ អភិវឌ្ឍវប្បធម៌ជាតិឱ្យកាន់តែរុងរឿងថែមទៀត។
- ការសិក្សាស្រាវជ្រាវតាមបែបកិច្ចការគម្រោង ឬការស្រាវជ្រាវផ្សេងៗ ដោយផ្ដោតលើ សកម្មភាពក្រុម។
- ការបណ្ដុះទម្លាប់សិស្សឱ្យចូលចិត្តស្ដាប់ កំណត់បានឈ្មោះ សូរ និងការប្រើប្រាស់តួអក្សរ ហើយចេះកត់ត្រាសង្ខេបព្រឹត្តិការណ៍ ឬស្រង់ព័ត៌មានផ្សេងៗតាមរយៈបទពិសោធ និងការវិភាគដោយមានអំណះអំណាងបានត្រឹមត្រូវ។
- សមត្ថភាពក្នុងការនិយាយ ដោយចេះប្រើសំនួនពាក្យតាមប្រធានបទ និយាយមានបែបបទត្រឹមត្រូវ ប្រើប្រាស់ពាក្យសម្ដីទន់ភ្លន់ ថ្លៃថ្នូរ ស្របតាមកាលៈទេសៈទាំងក្នុងការផ្ដល់ព័ត៌មាន ការសួរឆ្លើយ ការបកស្រាយ ការពន្យល់ ការប្រៀបធៀប ការបញ្ចេញមតិ ឬគំនិតជាដើម។

- សមត្ថភាពក្នុងការអានឈ្មោះ សូរ ចេះប្រើប្រាស់តួអក្សរ ចេះពាក្យ ដោយផ្អែកលើការបណ្តុះបំណិនក្នុងការរៀនដោយខ្លួនឯងមានដូចជា ការស្គាល់ឈ្មោះតួអក្សរនៅក្នុងពាក្យ ការស្គាល់សូរតួអក្សរ ការស្គាល់ចំនួនសូរ ការស្គាល់ទីតាំងសូរ ការចេះវិធីផ្សំសូរដើម្បីអានពាក្យ ការចេះអាន ដោយប្រកប ការចេះអានដោយមិនផ្សំប្រកប(អានស្ទាត់) ការចេះអានដើម្បីយល់ន័យ និង ការចេះប្រើប្រាស់ពាក្យ សំដៅធ្វើយ៉ាងណាឱ្យការរៀនពាក្យមួយ សិស្សចេះអានយល់ន័យ ចេះ សរសេរ និងចេះប្រើប្រាស់។ ការចេះអានស្ទាត់ ការអានតាមបែបបទ និងអានដើម្បីយល់ន័យពាក្យ កន្សោមពាក្យ ឃ្លា ល្បះ កថាខណ្ឌ អត្ថបទអធិប្បាយ កំណាព្យ ចម្រៀង រឿងនិទាន ព័ត៌មាន និងលិខិតផ្សេងៗបានច្បាស់លាស់។
- ការបណ្តុះទម្លាប់សិស្សឱ្យមានចំណង់ចំណូលចិត្តក្នុងការអានអត្ថបទ ព័ត៌មាន រឿងនិទាន ផ្សេងៗ ហើយចេះសង្ខេបឡើងវិញ។
- សមត្ថភាពក្នុងការសរសេរតួអក្សរ ពាក្យ កន្សោមពាក្យ ឃ្លា ល្បះ តែងកថាខណ្ឌ អត្ថបទ កំណាព្យ តែងសេចក្តីបែបពិពណ៌នា សរសេរអក្សរផ្ចង់ សរសេរតាមអាន កត់ត្រាចំណុច សំខាន់ៗ លិខិតផ្សេងៗបានត្រឹមត្រូវ។
- ផ្តល់ឱកាសសម្តែងមតិយោបល់ និងចំណាប់អារម្មណ៍របស់គេទាំងក្នុងសាលារៀន និងក្រៅសាលារៀនតាមរយៈការចូលរួមកម្សាន្តក្នុងរបាំ ចម្រៀង តន្ត្រី និងការសម្តែងតួផ្សេងៗប្រកបដោយគំនិតច្នៃប្រឌិត។

## ៣- គោលគំនិតសំខាន់ៗ

### ៣.១- គោលគំនិតសំខាន់ៗថ្នាក់ទី១

#### ក- សមត្ថភាពស្តាប់

នៅផ្នែកនេះ សិស្សចេះកត់សម្គាល់អត្ថន័យនៃពាក្យ កន្សោមពាក្យ ឃ្លា ល្បះ ការណែនាំងាយៗ និងធ្វើតាមការណែនាំដែលបានស្តាប់។ សិស្សចាប់ផ្តើមចេះកត់សម្គាល់សេចក្តីលម្អិតដែលប្រាប់ត្រង់និងបង្កប់ កត់សម្គាល់លំដាប់ត្រឹមត្រូវ កត់សម្គាល់ភាពដូចគ្នានិងភាពខុសគ្នានៃតួអង្គ ប្រាប់ប្រធានបទរបស់អត្ថបទ ប្រាប់ទំនាក់ទំនងរវាងហេតុនិងផល និងបង្ហាញដំបូន្មានរឿងនៅពេលស្តាប់រឿងនិទានខ្លីៗ ឬអត្ថបទងាយៗ។

#### ខ- សមត្ថភាពនិយាយ

ក្នុងសមត្ថភាពនិយាយ សិស្សចាប់ផ្តើមប្រើសុជីវធម៌សង្គម នៅពេលជួបគ្នា លាគ្នាប្រើពាក្យអរគុណ និងសូមអភ័យទោស។ សិស្សដឹងអំពីរបៀបប្រើពាក្យគួរសមងាយៗ និងរៀននិយាយតាម បែបបទ ដើម្បីផ្តល់ព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានផ្សេងៗ ណែនាំឱ្យស្គាល់គ្នា សួរនិងឆ្លើយសំណួរងាយៗ ធ្វើសំណើឬសំណូមពរផ្ទាល់ខ្លួន សម្តែងអារម្មណ៍ និងសម្តែងមតិយោបល់។ សិស្សរៀនបកស្រាយសញ្ញាងាយៗ រៀបរាប់ខ្លីៗ និងប្រៀបធៀបវត្ថុដែលនៅជុំវិញខ្លួន និងនិទានរឿងខ្លីៗឡើងវិញ។

#### គ- សមត្ថភាពអាន

បំណិនប្រសប់ដំបូងក្នុងការបង្រៀនអានគឺបុរេអំណាន។ សមាសភាគទាំង៥របស់អំណាន រួមមាន ការយល់ដឹងអំពីសូរ ទំនាក់ទំនងរវាងសូរនិងតួអក្សរ ការអានស្ទាត់ វាក្យសព្ទ និងការយល់ន័យ។ នៅថ្នាក់នេះ សិស្សចាប់ផ្តើមចេះកំណត់សូរអក្សរ ព្យាង្គ ពាក្យ បំបែកល្បះជាព្យាង្គ និងបំបែកពាក្យជាព្យាង្គ ផ្សំព្យាង្គជាពាក្យនិងបំបែកពាក្យជាព្យាង្គប្រកបសូរជាពាក្យនិងបំបែកពាក្យជាសូរ និងស្គាល់ពាក្យចួន។ សិស្សរៀនស្គាល់ទំនាក់ទំនងរវាងតួអក្សរនិងសូរ ចេះបន្លឺតួអក្សរ ចេះអានព្យាង្គ អានពាក្យដោយប្រកប និងមិនប្រកប។ សិស្សចេះអានពាក្យដែលមានសញ្ញាវណ្ណយុត្តិនិងពាក្យចំណាំងាយៗ។ បំណិនក្នុងវាក្យសព្ទរួមមាន ការកត់សម្គាល់និងពន្យល់ន័យនៃពាក្យដែលបានអាន ដោយប្រើវិធីផ្សេងៗ និងចេះប្រើប្រាស់ពាក្យ។ សិស្សរៀនអានពាក្យ ល្បះ និងអត្ថបទខ្លីៗ ឱ្យបានស្ទាត់ ដោយផ្តោតលើការគោរពសញ្ញា

ផ្សេងៗនៅក្នុងល្បះ។ សិស្សអាននិងបង្ហាញការយល់ន័យនៃអត្ថបទខ្លីៗដែលមានព័ត៌មានបង្ហាញត្រង់ តាមរយៈការរៀប ព្រឹត្តិការណ៍ ឡើងវិញ តាមលំដាប់ ការនិទានរឿងឡើងវិញ ការបង្ហាញអារម្មណ៍ ការបង្ហាញភាពដូចគ្នានិងខុសគ្នា ការបង្ហាញដំបូន្មានរឿង និងការប្រាប់ទំនាក់ទំនងរវាងហេតុនិងផលនៅក្នុងរឿង។

### ឃ- សមត្ថភាពសរសេរ

រយៈពេលនេះ សិស្សស្ថិតក្នុងដំណាក់កាលនៃការចាប់ផ្ដើមសរសេរ។ ដំបូងសិស្សរៀនគ្រប់ គ្រងចលនាភ្នែកនិងចលនាដៃ ដើម្បីគូសតាមទិសដៅនៃទ្រង់ទ្រាយខ្លះៗ។ សិស្សរៀនសរសេរតួអក្សរ សរសេរវណ្ណយុត្តដែលប្រើញឹកញាប់ សញ្ញាខណ្ឌនិងសញ្ញាសួរ តាមចលនា។ សិស្សរៀនសរសេរពាក្យ តាមរូបភាព សរសេរពាក្យផ្សេងៗ រួមទាំងពាក្យដែលមានតួអក្សរមិនអានដោយធ្វើអក្ខរាវិរុទ្ធ។ សិស្សសរសេរតាមអានចម្លង រៀបចំ និងត្រួតពិនិត្យតួអក្សរ ពាក្យ ល្បះខ្លីៗ និងសរសេរអក្សរផ្ចង់។ សិស្សរៀនបំពេញល្បះ រៀនប្រើសញ្ញាខណ្ឌ សញ្ញាសួរ រៀនតែងល្បះខ្លីៗដើម្បីធ្វើទំនាក់ទំនង តែងល្បះតាមរូបភាពនិងតាមគំនិតផ្ទាល់ខ្លួន រៀនតែងល្បះងាយៗទាក់ទងគ្នាចំនួនពីរល្បះ និងរៀនសរសេរពាក្យឃ្លា ឬល្បះ ដើម្បីឆ្លើយនឹងសំណួរខ្លីៗ។

## ៣.២- គោលគំនិតសំខាន់ៗថ្នាក់ទី២

### ក- សមត្ថភាពស្ដាប់

នៅផ្នែកនេះ សិស្សអភិវឌ្ឍបន្ថែមលើការយល់ន័យនៃពាក្យ កន្សោមពាក្យ ឃ្លា ល្បះ ដែលបាន ស្ដាប់។ លើសពីនេះ សិស្សកត់សម្គាល់សេចក្ដីលម្អិតនិងបង្ហាញការយល់ន័យអត្ថបទពណ៌នា រឿង និទាន កំណាព្យ និងចម្រៀងខ្លីៗដែលប្រាប់ត្រង់និងបង្កប់។ សិស្សចេះកត់សម្គាល់លំដាប់ត្រឹមត្រូវ កត់សម្គាល់ភាពដូចគ្នានិងភាពខុសគ្នានៃតួអង្គ និងទីកន្លែង ប្រាប់ខ្លឹមសារខ្លះនៅក្នុងអត្ថបទពណ៌នា ប្រាប់ប្រធានបទនិងគំនិតសំខាន់របស់កថាខណ្ឌ ឬអត្ថបទខ្លី ប្រាប់ទំនាក់ទំនងរវាងហេតុនិងផល បង្ហាញអារម្មណ៍ និងបង្ហាញដំបូន្មានរឿង នៅពេលស្ដាប់រឿងនិទានខ្លីៗ ឬអត្ថបទងាយៗ។

### ខ- សមត្ថភាពនិយាយ

ចំពោះសមត្ថភាពនេះ សិស្សបន្តការប្រើសុជីវធម៌សង្គម និងគារវកិច្ច។ សិស្សដឹងអំពីរបៀបប្រើ ពាក្យគួរសមងាយៗ និងនិយាយតាមបែបបទដើម្បីផ្ដល់ព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានអ្នកដទៃ និងព័ត៌មានផ្សេងៗ។ សិស្សចេះណែនាំឱ្យស្គាល់គ្នា សួរនិងឆ្លើយសំណួរ ធ្វើសំណើឬសំណូមពរផ្ទាល់ខ្លួន សម្រាប់ក្រុមឬថ្នាក់រៀន ចេះសម្ដែងអារម្មណ៍ និងសម្ដែងមតិយោបល់ខ្លីៗ។ សិស្សចេះបកស្រាយសញ្ញា រៀបរាប់ខ្លីៗនិងប្រៀបធៀបវត្ថុនិងសកម្មភាព និងនិទានរឿងខ្លីៗឡើងវិញ។

### គ- សមត្ថភាពអាន

សិស្សចេះកំណត់ព្យាង្គ នៅក្នុងពាក្យតម្រួតព្យាង្គ។ សិស្សបន្តរៀនស្គាល់ទំនាក់ទំនងរវាងតួអក្សរ និងសូរ រៀនអានពាក្យដែលមានស្រៈពេញតួ ពាក្យព្យាង្គតម្រួត និងពាក្យតម្រួតព្យាង្គ រៀនអានពាក្យចំណាំ(ពាក្យដែលមានតួអក្សរមិនអាន ពាក្យប្ដូរសូរ និងអញ្ញត្រសព្ទ)។ បំណិនក្នុងវាក្យសព្ទរួមមាន ការកត់សម្គាល់និងពន្យល់ន័យនៃពាក្យដែលបានអានតាមរយៈការភ្ជាប់ពាក្យទៅនឹងរូបភាព ការរកបដិសព្ទ និងវេវចនសព្ទរបស់ពាក្យ និងចេះប្រើប្រាស់ពាក្យ។ សិស្សរៀនប្រើវិធីផ្សេងៗ ដើម្បីរកន័យ របស់ពាក្យដូចជា ការប្រើបទានុក្រមនិងប្រើរូបភាពជាបរិបទបញ្ជាក់។ សិស្សបន្តរៀនអានពាក្យ ល្បះ និងអត្ថបទខ្លីៗ ឱ្យបានស្ទាត់ ដោយផ្ដោតលើការគោរពសញ្ញាផ្សេងៗនៅក្នុងល្បះ។ សិស្សអាននិងបង្ហាញការយល់ន័យ និងវិភាគអត្ថបទដែលមានព័ត៌មានបង្ហាញត្រង់និងបង្កប់ តាមរយៈការរៀបព្រឹត្តិការណ៍ឡើងវិញតាមលំដាប់ ការនិទានរឿងឡើងវិញ ការប្រាប់ប្រធានបទនិងគំនិតសំខាន់បង្ហាញ ត្រង់ ការបង្ហាញអារម្មណ៍ ការបង្ហាញ

ភាពដូចគ្នានិងខុសគ្នា ការបង្ហាញដំបូន្មានរឿង ការប្រាប់ទំនាក់ ទំនងរវាងហេតុ និងផល និងការបង្កើតគំនិតថ្មីដើម្បីបញ្ចប់រឿងដែលបានអាន។

### ឃ- សមត្ថភាពសរសេរ

សិស្សបន្តរៀនសរសេរពាក្យតាមរូបភាព សរសេរពាក្យផ្សេងៗ រួមទាំងពាក្យដែលមានតួអក្សរ មិនអាន និងពាក្យដែលប្តូរសូរ ដោយធ្វើអក្ខរាវិរុទ្ធ។ សិស្សសរសេរតាមអានចម្លង រៀបចំ និងត្រួតពិនិត្យ ពាក្យនិងល្បះ និងសរសេរអក្សរផ្ចង់។ សិស្សបំពេញល្បះ ប្រើសញ្ញាខណ្ឌ សញ្ញាសួរ តែងល្បះតាមរូបភាពនិងតាមគំនិតផ្ទាល់ខ្លួន តែងល្បះចំនួនបីទៅបួនល្បះទាក់ទងគ្នា ដោយប្រើពាក្យងាយ និងសរសេរពាក្យ ឃ្លា ឬល្បះដើម្បីឆ្លើយនឹងសំណួរខ្លីៗ។

### ៣.៣- គោលគំនិតសំខាន់ៗថ្នាក់ទី៣

### ក- សមត្ថភាពស្តាប់

សិស្សអភិវឌ្ឍបន្ថែមទៀត លើការយល់ន័យនៃពាក្យ កន្សោមពាក្យ ឃ្លា ល្បះ ដែលបានស្តាប់។ លើសពីនេះ សិស្សកត់សម្គាល់សេចក្តីលម្អិតនិងបង្ហាញការយល់ន័យ វិភាគ និងវាយតម្លៃអត្ថបទ ពណ៌នា រឿងនិទាន កំណាព្យ និងចម្រៀងខ្លីៗ ដែលបង្ហាញត្រង់និងបង្កប់។ សិស្សបន្តកត់សម្គាល់លំដាប់ត្រឹមត្រូវ កត់សម្គាល់ភាពដូចគ្នានិងភាពខុសគ្នានៃតួអង្គ ទីកន្លែង និងពេលវេលា នៅក្នុងរឿង ប្រាប់ខ្លឹមសារខ្លះនៅក្នុងអត្ថបទពណ៌នា។ សិស្សប្រាប់ប្រធានបទនិងគំនិតសំខាន់បង្ហាញត្រង់និងបង្កប់របស់កថាខណ្ឌឬអត្ថបទខ្លី ប្រាប់ទំនាក់ទំនងរវាងហេតុនិងផល បង្ហាញអារម្មណ៍និងបង្ហាញដំបូន្មានរឿងនៅពេលស្តាប់រឿងនិទានឬអត្ថបទងាយៗ។

### ខ- សមត្ថភាពនិយាយ

សិស្សបន្តប្រើពាក្យគួរសម និងនិយាយតាមបែបបទ ដើម្បីផ្តល់ព័ត៌មានផ្ទាល់ខ្លួននិងអ្នកដទៃ និងព័ត៌មានផ្សេងៗទៀត។ សិស្សបន្តរៀនធ្វើសំណើឬសំណូមពរសម្រាប់ក្រុមឬថ្នាក់រៀន ដោយផ្តល់ហេតុផល សម្តែងអារម្មណ៍និងសម្តែងមតិយោបល់ខ្លីៗដូចថ្នាក់ទី២ដែរ។ សិស្សបកស្រាយសញ្ញាឬនិមិត្តសញ្ញានិងតារាងកាលវិភាគ។ សិស្សបន្តរៀបរាប់ និងប្រៀបធៀបវត្ថុដោយផ្តោតលើតម្លៃនិងគុណភាព បន្តរៀបរាប់ខ្លីៗអំពីសកម្មភាពនិងនិទានរឿងខ្លីៗឡើងវិញ។ សិស្សបញ្ចេញយោបល់ខ្លីៗលើប្រធានបទ អ្វីមួយដោយផ្តល់អំណះអំណាង។

### គ- សមត្ថភាពអាន

សិស្សបន្តរៀនស្គាល់ទំនាក់ទំនងរវាងតួអក្សរនិងសូរ អានពាក្យដែលមានស្រៈពេញតួ ពាក្យពហុព្យាង្គ និងអានពាក្យចំណាំ(ពាក្យដែលមានតួអក្សរមិនអាន ពាក្យប្តូរសូរ និងអញ្ញត្រសព្ទ) និងបង្ហាញពាក្យចួន។ បំណិនក្នុងវាក្យសព្ទរួមមាន ការពន្យល់ន័យនៃពាក្យដែលបានអាន និងចេះប្រើប្រាស់ពាក្យ។ សិស្សប្រើវិធីផ្សេងៗ ដើម្បីរកន័យរបស់ពាក្យដូចជា ការប្រើបទានុក្រម ការប្រើរូបភាព ការប្រើបដិសព្ទ និងវេវចនសព្ទជាបរិបទបញ្ជាក់។ ចំណុចផ្តោតសំខាន់នៅថ្នាក់នេះគឺ ការអានស្ទាត់ និងការយល់ន័យ។ សិស្សបន្តអានអត្ថបទពណ៌នា រឿងនិទាន កំណាព្យនិង ចម្រៀងខ្លីៗឱ្យបានស្ទាត់ ដោយគោរពសញ្ញាផ្សេងៗនៅក្នុងល្បះ។ សិស្សអាននិងបង្ហាញការយល់ន័យ ការវិភាគ និងវាយតម្លៃអត្ថបទដែលមានព័ត៌មានបង្ហាញត្រង់និងបង្កប់ តាមរយៈការប្រាប់ខ្លឹមសារ ការរៀបព្រឹត្តិការណ៍ឡើងវិញតាមលំដាប់ ការនិទានរឿងឡើងវិញ ការប្រាប់ប្រធានបទ និងគំនិតសំខាន់បង្ហាញត្រង់ ការបង្ហាញអារម្មណ៍ ការបង្ហាញភាពដូចគ្នានិងខុសគ្នា ការបង្ហាញដំបូន្មានរឿង ការប្រាប់ទំនាក់ទំនងរវាងហេតុនិងផល និងការបង្កើតគំនិតថ្មី ដើម្បីបញ្ចប់រឿងដែលបានអាន។

### ឃ- សមត្ថភាពសរសេរ

សិស្សរៀនសរសេរពាក្យផ្សេងៗ រួមទាំងពាក្យដែលមានតួអក្សរមិនអាន និងពាក្យដែលប្ដូរសូរ ដោយធ្វើអក្ខរាវិរុទ្ធ បន្តពីថ្នាក់ទី២។ សិស្សសរសេរតាមអានរៀបចំ និងត្រួតពិនិត្យល្បះ និងអត្ថបទខ្លី និងសរសេរអក្សរផ្ចង់តាមទម្រង់អក្សរជ្រៀង។ សិស្សបំពេញល្បះ បំពេញទម្រង់ ប្រើសញ្ញាខណ្ឌ សញ្ញាសួរ តែងល្បះតាមរូបភាព និងតាមគំនិតផ្ទាល់ខ្លួន សរសេរពាក្យ ឃ្លា ឬល្បះ ដើម្បីឆ្លើយនឹងសំណួរខ្លីៗ។ សិស្សតែងល្បះច្រើនទាក់ទងគ្នាដោយប្រើពាក្យងាយៗ និងតែងកថាខណ្ឌខ្លីៗ។

### ង- វេយ្យាករណ៍

សិស្សកត់សម្គាល់សញ្ញាណដំបូងនៃការប្រើប្រាស់វណ្ណយុត្តមានដូចជាសញ្ញាមូសិកទន្ត(៉) សញ្ញាត្រីសព្ទ(៊) និងសញ្ញាបន្តក់(់)។ សិស្សកត់សម្គាល់សញ្ញាណដំបូងនៃការប្រើប្រាស់វណ្ណវាទមានដូចជាសញ្ញាខណ្ឌ(។) សញ្ញាសួរ (?) និងសញ្ញាឧទាន(!)។

## ៣.៤- គោលគំនិតសំខាន់ៗថ្នាក់ទី៤

### ក- សមត្ថភាពស្ដាប់

សិស្សស្ដាប់អត្ថបទពណ៌នា អធិប្បាយ រឿងនិទាន កំណាព្យឬចម្រៀង សេចក្ដីជូនដំណឹង សេចក្ដីអញ្ជើញ និងសេចក្ដីប្រកាសព័ត៌មាន។

សិស្សមានសមត្ថភាពក្នុងការចងចាំ យល់ន័យ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី ដោយឆ្លើយទៅនឹងសំណួរ អ្វី នរណា ឯណា ពេលណា ដូចម្ដេច ហេតុអ្វី ក្នុងការរកសេចក្ដីលម្អិតបង្ហាញត្រង់និងបង្កប់ ពន្យល់ពាក្យ បដិសព្ទ វេវចនសព្ទ សទិសសព្ទ ឧទាហរណ៍ គំនិតសំខាន់ ដំបូន្មាន ទំនាក់ទំនងរវាងហេតុនិងផល ការពិតនិងមតិ ប្រភព ប៉ាន់ស្មានខ្លឹមសារ ប៉ាន់ស្មានព្រឹត្តិការណ៍ ប៉ាន់ស្មានលទ្ធផល រៀបព្រឹត្តិការណ៍តាមលំដាប់ តួអង្គ កាលអាកាស បង្កើតគំនិតថ្មីដើម្បីច្នៃប្រឌិតរឿង ប្រភព ប្រធានបទ គោលបំណង ប្រភេទ ធាតុផ្សេងៗនៃកំណាព្យ និងសង្ខេបអត្ថបទ។

### ខ- សមត្ថភាពនិយាយ

បង្ហាញឥរិយាបថល្អប្រពៃដោយយកចិត្តទុកដាក់ស្ដាប់អ្នកដទៃ ចេះប្រើសំនួនពាក្យ យល់ដឹងពីបែបបទក្នុងការនិយាយប្រកបដោយភាពវិជ្ជមាននិងមានប្រសិទ្ធភាពដើម្បីរៀបរាប់ពីស្ថានភាពគ្រួសារ រៀបរាប់ពីព្រឹត្តិការណ៍ ប្រាប់ទិសក្នុងការរកទីកន្លែង ណែនាំខ្លួនឯងនិងអ្នកដទៃ រាយការណ៍ផ្ទាល់មាត់ ណែនាំនិងធ្វើតាមការណែនាំផ្ទាល់មាត់ក្នុងការប្រើប្រាស់ទូរស័ព្ទនិងអ៊ីនធើណែត ធ្វើការទាក់ទងគ្នាដោយផ្ទាល់ តាមទូរស័ព្ទនិងតាមអ៊ីនធើណែត បកស្រាយតារាងព្យាករណ៍អាកាសធាតុ សញ្ញាឬនិមិត្តសញ្ញា រូបភាព ក្រាបសសរ ធ្វើសំណើឬសំណូមពរ ធ្វើការអញ្ជើញ ធ្វើសេចក្ដីជូនដំណឹង បញ្ចេញយោបល់ក្នុងការពិភាក្សាក្រុម និទានរឿងនិងនិទានរឿងឡើងវិញ សម្ដែងអារម្មណ៍ សម្ដែងមតិ បញ្ចេញមតិលើប្រធានបទអ្វីមួយ ផ្ដល់អំណះអំណាងឬហេតុផល ប្រើសុជីវធម៌និងគារវកិច្ចក្នុងការសន្ទនាជាមួយភ្ញៀវ។

### គ- សមត្ថភាពអាន

សិស្សចេះអានលើកដាក់សំឡេងគោរពតាមសញ្ញាផ្សេងៗបានត្រឹមត្រូវ ក្នុងការអានស្ទាត់ពាក្យ កន្សោមពាក្យ ឃ្លា ល្បះ អត្ថបទពណ៌នា អធិប្បាយ រឿងនិទាន សេចក្ដីជូនដំណឹង សេចក្ដីអញ្ជើញ សេចក្ដីប្រកាសព័ត៌មាន ព្រមទាំងសូត្រកំណាព្យបទកាកគតិ បទពាក្យ៧ និងច្រៀងចម្រៀងត្រឹមត្រូវតាមបែបបទ។

សិស្សមានសមត្ថភាពក្នុងការចងចាំ យល់ន័យ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី ដោយឆ្លើយទៅនឹងសំណួរ អ្វី នរណា ឯណា ពេលណា ដូចម្ដេច ហេតុអ្វី ក្នុងការរកសេចក្ដីលម្អិតបង្ហាញត្រង់និងបង្កប់ ដើម្បីយល់ន័យពាក្យ កន្សោមពាក្យ ឃ្លា ល្បះ ប្រើប្រាស់បរិបទមានដូចជាពន្យល់ពាក្យ បដិសព្ទ វេវចនសព្ទ សទិសសព្ទ ឧទាហរណ៍ និងឧបបទ ព្រមទាំងបង្ហាញគំនិតសំខាន់ ដំបូន្មាន ទំនាក់ទំនងរវាងហេតុនិងផល រៀបព្រឹត្តិការណ៍តាមលំដាប់ ប៉ាន់ស្មានខ្លឹមសារ ប៉ាន់ស្មានព្រឹត្តិការណ៍ ប៉ាន់ស្មានលទ្ធផល ប្រភព តួអង្គ កាលអាកាស សង្ខេប បង្កើតគំនិតថ្មីដើម្បី

ច្នៃប្រឌិតរឿង ការពិតនិងមតិ ប្រើបទានុក្រម វចនានុក្រម ធាតុផ្សេងៗនៃកំណាព្យ ប្រភព ប្រធានបទ គោលបំណង ទម្រង់ ប្រភេទ បកស្រាយ តារាងព្យាករណ៍អាកាសធាតុ សញ្ញាឬនិមិត្តសញ្ញា រូបភាព ក្រាបសសរ និងសង្ខេបអត្ថបទ។

### ឃ- សមត្ថភាពសរសេរ

សិស្សយល់ដឹងពីសំនួនពាក្យនិងទម្រង់បែបបទនៃសំណេរផ្សេងៗដូចជា អក្សរផ្ទង់ទម្រង់អក្សរមូល ល្បះ សរសេរតាមអានរៀបចំនិងត្រួតពិនិត្យ សំណេរបំពេញទម្រង់ងាយៗ កថាខណ្ឌ កំណត់ត្រាប្រចាំថ្ងៃ ផែនការ សំណេរបកស្រាយខ្លីៗ ជីវប្រវត្តិ សំណេរស្រាវជ្រាវបែបគម្រោង លិខិតផ្សេងៗ តែងសេចក្ដីបែបពិពណ៌នា។

សិស្សមានសមត្ថភាពសរសេរ អក្សរផ្ទង់ទម្រង់អក្សរមូល ពាក្យ កន្សោមពាក្យ ឃ្លា ល្បះ កថាខណ្ឌខ្លីៗតាមរយៈការសរសេរតាមអានរៀបចំនិងត្រួតពិនិត្យ បំពេញល្បះ រៀបពាក្យជាល្បះ តែងល្បះតាមរូបភាព តែងល្បះនឹងពាក្យដែលផ្ដល់ឱ្យ តែងល្បះដោយគំនិតផ្ទាល់ខ្លួន បំពេញបណ្ណសម្គាល់ខ្លួន ពាក្យសុំច្បាប់ កថាខណ្ឌ កំណាព្យឬចម្រៀង តែងកថាខណ្ឌ ធ្វើកំណត់ត្រាប្រចាំថ្ងៃ ធ្វើផែនការប្រចាំថ្ងៃសម្រាប់ខ្លួនឯង បកស្រាយតារាងព្យាករណ៍អាកាសធាតុ សញ្ញាឬនិមិត្តសញ្ញាគ្រោះថ្នាក់មីន រូបភាពការអប់រំសុខភាព ក្រាបសសរ ជីវប្រវត្តិគ្រួសារខ្លីៗ សំណេរស្រាវជ្រាវបែបគម្រោង សេចក្ដីជូនដំណឹងខ្លីៗ លិខិតអញ្ជើញ តែងសេចក្ដីបែបពិពណ៌នាពីមនុស្ស សត្វ វត្ថុ និងរុក្ខជាតិ។

### ង- វេយ្យាករណ៍

សិស្សកត់សម្គាល់បញ្ញត្តិនិងចេះប្រើប្រាស់ប្រភេទពាក្យមានដូចជា នាម គុណនាម កិរិយាសព្ទ វណ្ណយុត្តមានសញ្ញាចុចពីរឬយុគលពិន្ទុ(ះ) សញ្ញាទណ្ឌឃាដ(៍) សញ្ញាលេខទោ(ៗ) វណ្ណវាទមានដូចជា សញ្ញាដំពីរ(៖) សញ្ញាចុចពីរ(:) សញ្ញាចំណុចបី(...) និងដំណកឃ្លា។

## ៣.៥- គោលគំនិតសំខាន់ៗថ្នាក់ទី៥

### ក- សមត្ថភាពស្ដាប់

សិស្សស្ដាប់អត្ថបទពណ៌នា អធិប្បាយ រឿងនិទាន កំណាព្យឬចម្រៀង សេចក្ដីជូនដំណឹង សេចក្ដីអញ្ជើញ សេចក្ដីប្រកាសព័ត៌មាន និងសារព័ត៌មាន។

សិស្សមានសមត្ថភាពក្នុងការចងចាំ យល់ន័យ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី ដោយឆ្លើយទៅនឹងសំណួរ អ្វី នរណា ឯណា ពេលណា ដូចម្ដេច ហេតុអ្វី ដើម្បីរកសេចក្ដីលម្អិតបង្ហាញត្រង់និងបង្កប់ ពន្យល់ពាក្យ បដិសព្ទ វេវចនសព្ទ សទិសសព្ទ ឧទាហរណ៍ ឧបបទ គំនិតសំខាន់ ដំបូន្មាន ទំនាក់ ទំនងរវាងហេតុនិងផល ការពិតនិងមតិ ប្រភព ប៉ាន់ស្មានខ្លឹមសារ ប៉ាន់ស្មានព្រឹត្តិការណ៍ ប៉ាន់ស្មានលទ្ធផល រៀបព្រឹត្តិការណ៍តាមលំដាប់ តួអង្គ ចរិតលក្ខណៈតួអង្គ កាលអាកាស បង្កើតគំនិតថ្មីដើម្បីច្នៃប្រឌិតរឿង ប្រភព ប្រធានបទ គោលបំណង ប្រភេទ ធាតុផ្សេងៗនៃកំណាព្យ កត់ត្រាចំណុចសំខាន់ៗ សង្ខេប ទាញសេចក្ដីសន្និដ្ឋាន និងតែងរឿងខ្លី។

### ខ- សមត្ថភាពនិយាយ

បង្ហាញឥរិយាបថល្អប្រពៃដោយយកចិត្តទុកដាក់ស្ដាប់អ្នកដទៃ ចេះប្រើសំនួនពាក្យ យល់ដឹងពីបែបបទក្នុងការនិយាយប្រកបដោយភាពវិជ្ជមាននិងមានប្រសិទ្ធភាពដើម្បីរៀបរាប់ពីស្ថានភាពគ្រួសារ ធ្វើការនាំពាក្យ រៀបរាប់ពីព្រឹត្តិការណ៍ ប្រាប់ទិសក្នុងការរកទីកន្លែងតាមផែនទី ណែនាំខ្លួនឯងនិងអ្នកដទៃ រាយការណ៍ផ្ទាល់មាត់ ណែនាំនិងធ្វើតាមការណែនាំផ្ទាល់មាត់ក្នុងការប្រើប្រាស់ទូរស័ព្ទនិងអ៊ិនធើណែត ធ្វើការទាក់ទងគ្នាដោយផ្ទាល់ តាមទូរស័ព្ទនិងតាមអ៊ិនធើណែត បកស្រាយតារាងអត្រាប្ដូរប្រាក់ និមិត្តសញ្ញាទង់ជាតិកម្ពុជា រូបភាពគ្រោះមហន្តរាយផ្សេងៗ ក្រាបផ្ចិត ដ្យាក្រាម ធ្វើសំណើឬសំណូមពរ ធ្វើការអញ្ជើញ ធ្វើសេចក្ដីជូនដំណឹង ពង្រីកគំនិតដើម្បីផ្ដល់សេចក្ដីពន្យល់ ពន្យល់ដោយផ្ដល់អំណះអំណាង ធ្វើការបញ្ចុះបញ្ចូល ឆ្លើយតបនឹងការបញ្ចុះបញ្ចូលនិងការដាក់សម្ពាធ បញ្ចេញយោបល់ក្នុងការពិភាក្សាក្រុម សម្ដែងអារម្មណ៍ សម្ដែងមតិ បញ្ចេញមតិលើប្រធានបទអ្វីមួយ ផ្ដល់អំណះអំណាងឬ

ហេតុផលនិងគារវកិច្ច និងធ្វើបទបង្ហាញ។

### គ- សមត្ថភាពអាន

សិស្សចេះអានលើកដាក់សំឡេង គោរពតាមសញ្ញាផ្សេងៗបានត្រឹមត្រូវក្នុងការអានស្ទាត់ពាក្យ កន្សោមពាក្យ ឃ្លា ល្បះ អត្ថបទពណ៌នា អធិប្បាយ រឿងនិទាន សេចក្តីជូនដំណឹង សេចក្តីអញ្ជើញ សេចក្តីប្រកាសព័ត៌មាន ការឃោសនា សារព័ត៌មាន ព្រមទាំងសូត្រកំណាព្យបទពំនោល បទព្រហ្មគីតិ និងច្រៀងចម្រៀងត្រឹមត្រូវតាមបែបបទ។

សិស្សមានសមត្ថភាពក្នុងការចងចាំ យល់ន័យ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី ដោយឆ្លើយទៅនឹងសំណួរ អ្វី នរណា ឯណា ពេលណា ដូចម្តេច ហេតុអ្វី ក្នុងការរកសេចក្តីលម្អិតបង្ហាញត្រង់និងបង្កប់ ដើម្បីយល់ន័យពាក្យ កន្សោមពាក្យ ឃ្លា ល្បះ បង្ហាញការយល់ដឹងអំពីការប្រើប្រាស់បរិបទបញ្ជាក់ដូចជាពន្យល់ពាក្យ បដិសព្ទ វេវចនសព្ទ សទិសសព្ទ ឧទាហរណ៍ ឧបបទ និងបំភ្លឺបន័យ ព្រមទាំងបង្ហាញគំនិតសំខាន់ ដំបូន្មាន ទំនាក់ទំនងរវាងហេតុនិងផល ប៉ាន់ស្មានខ្លឹមសារ ការពិតនិងមតិ ប្រើបទានុក្រម វចនានុក្រម ធាតុផ្សេងៗនៃកំណាព្យ ប្រភព ប្រធានបទ គោលបំណង ទម្រង់ ប្រភេទ តួអង្គ ចរិតលក្ខណៈតួអង្គ កាលអាកាស ដំណើររឿង កត់ត្រាចំណុចសំខាន់ៗ បង្កើតគំនិតថ្មី ដើម្បីច្នៃប្រឌិតរឿង បកស្រាយតារាងអត្រាប្តូរប្រាក់ និមិត្តសញ្ញាទង់ជាតិកម្ពុជា រូបភាពគ្រោះមហន្ត
រាយផ្សេងៗ ក្រាបផ្លិត ដ្យាក្រាម ទាញសេចក្តីសន្និដ្ឋាន និងសង្ខេបអត្ថបទ។

### ឃ- សមត្ថភាពសរសេរ

សិស្សយល់ដឹងពីសំនួនពាក្យនិងទម្រង់បែបបទនៃសំណេរផ្សេងៗដូចជា អក្សរផ្ចង់ទម្រង់អក្សរខម ល្បះ សរសេរតាមអានរៀបចំនិងត្រួតពិនិត្យ សំណេរបំពេញទម្រង់ងាយៗ កថាខណ្ឌ កំណត់ត្រាប្រចាំថ្ងៃ ផែនការ ការកត់ត្រាចំណុចសំខាន់ៗ កំណាព្យ ជីវប្រវត្តិ សំណេរបកស្រាយខ្លីៗ សំណេរស្រាវជ្រាវបែបគម្រោង លិខិតផ្សេងៗ និងតែងសេចក្តីបែបពិពណ៌នា។

សិស្សមានសមត្ថភាពសរសេរអក្សរផ្ចង់ទម្រង់អក្សរខម ពាក្យ កន្សោមពាក្យ ឃ្លា ល្បះ កថាខណ្ឌខ្លីៗតាមរយៈការសរសេរតាមអានរៀបចំនិងត្រួតពិនិត្យ បំពេញល្បះ រៀបពាក្យជាល្បះ តែងល្បះតាមរូបភាព តែងល្បះនឹងពាក្យដែលផ្តល់ឱ្យ តែងល្បះដោយគំនិតផ្ទាល់ខ្លួន បំពេញអត្តសញ្ញាណបណ្ណ ពាក្យសុំចូលរៀន កថាខណ្ឌ កំណាព្យឬចម្រៀង ធ្វើកំណត់ត្រាប្រចាំថ្ងៃ ធ្វើផែនការប្រចាំខែសម្រាប់ខ្លួនឯង កត់ត្រាចំណុចសំខាន់ៗ តែងកំណាព្យបទកាកគតិនិងបទពាក្យ ៧ បកស្រាយតារាងអត្រាប្តូរប្រាក់ និមិត្តសញ្ញាទង់ជាតិកម្ពុជា រូបភាពគ្រោះមហន្តរាយផ្សេងៗ ក្រាបផ្លិត ដ្យាក្រាម ជីវប្រវត្តិគ្រួសារខ្លីៗ សំណេរស្រាវជ្រាវបែបគម្រោង លិខិតអញ្ជើញចូលរួមប្រជុំ លិខិតជូនពរ លិខិតសួរសុខទុក្ខ លិខិតអញ្ជើញភ្ញៀវចូលរួមក្នុងពិធីបុណ្យ តែងសេចក្តីបែបពិពណ៌នាពីទីកន្លែង ទេសភាព ព្រឹត្តិការណ៍ និងបាតុភូតធម្មជាតិ។

### ង- វេយ្យាករណ៍

សិស្សកត់សម្គាល់បញ្ញត្តិនិងចេះប្រើប្រាស់ប្រភេទពាក្យមានដូចជា សព្វនាម គុណកិរិយា ធ្នាក់ ឈ្នាប់ វណ្ណយុត្តមានសញ្ញារបាទ(៌) សំយោគសញ្ញា(៎) សញ្ញាអស្តា(៏) វណ្ណវាទមានដូចជាសញ្ញាបេយ្យាល(។ល។) សញ្ញាវង់ក្រចក ( ) អព្ទន្តរសញ្ញា(« ») ដំណកឃ្លា ល្បះទោលមានផ្នែកផ្សេងៗនៃល្បះទោល ទម្រង់ល្បះទោល តែងល្បះទោលវចនាបថផ្ទាល់ និងវចនាបថមិនផ្ទាល់។

## ៣.៦- ខ្លឹមសារសំខាន់ៗថ្នាក់ទី៦

### ក- សមត្ថភាពស្តាប់

សិស្សស្តាប់អត្ថបទពណ៌នា អធិប្បាយ រឿងនិទាន កំណាព្យឬចម្រៀង សេចក្តីជូនដំណឹង សេចក្តីអញ្ជើញ ការឃោសនា សេចក្តីប្រកាសព័ត៌មាន និងសារព័ត៌មាន។

សិស្សមានសមត្ថភាពក្នុងការចងចាំ យល់ន័យ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី ដោយឆ្លើយទៅនឹងសំណួរ អ្វី នរណា ឯណា ពេលណា ដូចម្ដេច ហេតុអ្វី ដើម្បីរកសេចក្ដីលម្អិតបង្ហាញត្រង់និងបង្កប់ ដើម្បីយល់ដឹងក្នុងការប្រើប្រាស់បរិបទបញ្ជាក់ដូចជា ពន្យល់ពាក្យ បដិសព្ទ វេវចនសព្ទ សទិសសព្ទ ឧទាហរណ៍ ឧបបទ និងបំរៀបន័យ ព្រមទាំងបង្ហាញគំនិតសំខាន់ ដំបូន្មាន ទំនាក់ទំនងរវាងហេតុនិងផល ការពិតនិងមតិ ប្រភព ប៉ាន់ស្មានខ្លឹមសារ ប៉ាន់ស្មានព្រឹត្តិការណ៍ ប៉ាន់ស្មានលទ្ធផល រៀបព្រឹត្តិការណ៍តាមលំដាប់ តួអង្គឯក តួអង្គរង ចរិតលក្ខណៈតួអង្គ កាលអាកាស តថកថា ប្រឌិតកថា ប្រៀបធៀបតួអង្គ បង្កើតគំនិតថ្មីដើម្បីច្នៃប្រឌិតរឿង ប្រភព ប្រធានបទ គោលបំណង ប្រភេទ ធាតុផ្សេងៗនៃកំណាព្យ កត់ត្រាចំណុចសំខាន់ៗ សង្ខេប ទាញសេចក្តីសន្និដ្ឋាន និងតែងរឿងខ្លី។

### ខ- សមត្ថភាពនិយាយ

បង្ហាញឥរិយាបថល្អប្រពៃដោយយកចិត្តទុកដាក់ស្ដាប់អ្នកដទៃ ចេះប្រើសំនួនពាក្យ យល់ដឹងពីបែបបទក្នុងការនិយាយប្រកបដោយភាពវិជ្ជមាននិងមានប្រសិទ្ធភាពដើម្បី រៀបរាប់ពីស្ថានភាពគ្រួសារ ធ្វើការនាំពាក្យ រៀបរាប់ពីព្រឹត្តិការណ៍ ណែនាំខ្លួនឯងនិងអ្នកដទៃ រាយការណ៍ផ្ទាល់មាត់ ណែនាំនិងធ្វើតាមការណែនាំផ្ទាល់មាត់ក្នុងការប្រើប្រាស់ប្រព័ន្ធបណ្ដាញសង្គម(អ៊ីមែល ហ្វេសបុក តេឡេក្រាម...) ធ្វើការទាក់ទងគ្នាដោយផ្ទាល់តាមប្រព័ន្ធបណ្ដាញសង្គម(អ៊ីមែល ហ្វេសបុក តេឡេក្រាម...) បកស្រាយតារាងជើងហោះហើរ និមិត្តសញ្ញាទង់អាស៊ាន រូបភាពគំនូរសេរី ក្រាបខ្សែ ដ្យាក្រាម ធ្វើសំណើឬសំណូមពរ ធ្វើការអញ្ជើញ ធ្វើសេចក្ដីជូនដំណឹងទៅកាន់សហគមន៍ ស្ថាប័នសាធារណៈ និងស្ថាប័នឯកជន ពង្រីកគំនិតដើម្បីផ្តល់សេចក្តីពន្យល់ ពន្យល់ដោយផ្តល់អំណះអំណាង ធ្វើការបញ្ចុះបញ្ចូលនិងឆ្លើយតបនឹងការបញ្ចុះបញ្ចូលនិងការដាក់សម្ពាធ បញ្ចេញយោបល់ក្នុងការពិភាក្សាក្រុម សម្ដែងចំណាប់អារម្មណ៍ក្នុងកម្មវិធីផ្ទាល់ខ្លួនឬគ្រួសារ កម្មវិធីផ្លូវការ សម្ដែងមតិ បញ្ចេញមតិលើប្រធានបទអ្វីមួយ ផ្តល់អំណះអំណាងឬហេតុផល ធ្វើការរៀបចំនិងការកាន់កម្មវិធីប្រជុំ និងរៀបចំនិងការកាន់កម្មវិធីសម្ដែង និងធ្វើបទបង្ហាញ។

### គ- សមត្ថភាពអាន

សិស្សចេះអានលើកដាក់សំឡេង គោរពតាមសញ្ញាផ្សេងៗ បានត្រឹមត្រូវក្នុងការអានស្ទាត់ពាក្យ កន្សោមពាក្យ ឃ្លា ល្បះ អត្ថបទពណ៌នា អធិប្បាយ រឿងនិទាន សេចក្ដីជូនដំណឹង សេចក្ដីអញ្ជើញ សេចក្ដីប្រកាសព័ត៌មាន ការឃោសនា សារព័ត៌មាន ព្រមទាំងសូត្រកំណាព្យបទភុជង្គលីលា ពំនោល និងព្រហ្មគីតិ និងច្រៀងចម្រៀងត្រឹមត្រូវតាមបែបបទ។

សិស្សមានសមត្ថភាពក្នុងការចងចាំ យល់ន័យ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី ដោយឆ្លើយទៅនឹងសំណួរ អ្វី នរណា ឯណា ពេលណា ដូចម្ដេច ហេតុអ្វី ក្នុងការរកសេចក្ដីលម្អិតបង្ហាញត្រង់និងបង្កប់ ដើម្បីយល់ន័យពាក្យ កន្សោមពាក្យ ឃ្លា ល្បះ បង្ហាញការយល់ដឹងអំពីការប្រើប្រាស់បរិបទបញ្ជាក់ដូចជា ពន្យល់ពាក្យ បដិសព្ទ វេវចនសព្ទ សទិសសព្ទ ឧទាហរណ៍ ឧបបទ បំរៀបន័យ ព្រមទាំងបង្ហាញគំនិតសំខាន់ ដំបូន្មាន ទំនាក់ទំនងរវាងហេតុនិងផល ប៉ាន់ស្មានខ្លឹមសារ ការពិតនិងមតិ ប្រើបទានុក្រម វចនានុក្រម ធាតុផ្សេងៗនៃកំណាព្យ ប្រភព ប្រធានបទ គោលបំណង ទម្រង់ ប្រភេទ តួអង្គឯក តួអង្គរង ចរិតលក្ខណៈតួអង្គ កាលអាកាស ដំណើររឿង ពិតកថា ប្រឌិតកថា កត់ត្រាចំណុចសំខាន់ៗ បង្កើតគំនិតថ្មីដើម្បីច្នៃប្រឌិតរឿង បកស្រាយតារាងជើងហោះហើរ និមិត្តសញ្ញាទង់អាស៊ាន រូភាពគំនូរសេរី ក្រាបខ្សែ ដ្យាក្រាម ទាញសេចក្ដីសន្និដ្ឋាន និងសង្ខេបអត្ថបទ។

### ឃ- សមត្ថភាពសរសេរ

សិស្សយល់ដឹងពីសំនួនពាក្យ និងទម្រង់បែបបទនៃសំណេរផ្សេងៗដូចជា អក្សរផ្ចង់ទម្រង់អក្សរឆ្លាក់ ល្បះ សរសេរតាមអានរៀបចំនិងត្រួតពិនិត្យ សំណេរបំពេញទម្រង់ងាយៗ កថាខណ្ឌ កំណត់ត្រាប្រចាំថ្ងៃ ផែនការ ការកត់ត្រា

ចំណុចសំខាន់ៗ សំណេរបកស្រាយខ្លីៗ កំណាព្យ ជីវប្រវត្តិ សំណេរស្រាវជ្រាវបែបគម្រោង លិខិតផ្សេងៗ តែងសេចក្តីបែបពិពណ៌នា។

សិស្សមានសមត្ថភាពសរសេរ អក្សរផ្ចង់ទម្រង់អក្សរឆ្លាក់ ពាក្យ កន្សោមពាក្យ ឃ្លា ល្បះ កថាខណ្ឌខ្លីៗតាមរយៈការសរសេរតាមអានរៀបចំនិងត្រួតពិនិត្យ បំពេញល្បះ រៀបពាក្យជាល្បះ តែងល្បះតាមរូបភាព តែងល្បះនឹងពាក្យដែលផ្តល់ឱ្យ តែងល្បះដោយគំនិតផ្ទាល់ខ្លួន បំពេញសំបុត្រកំណើត ពាក្យសុំផ្លាស់ប្តូរសាលារៀន កថាខណ្ឌ កំណាព្យឬចម្រៀង ធ្វើផែនការប្រចាំឆ្នាំសម្រាប់ខ្លួនឯង កត់ត្រាចំណុចសំខាន់ៗ ជីវប្រវត្តិគ្រួសារខ្លីៗ តែងកំណាព្យបទកាកគតិនិងបទពាក្យ៧ បកស្រាយតារាងជើងហោះហើរ និមិត្តសញ្ញាទង់អាស៊ាន រូបភាពគំនូរសេរី ក្រាបខ្សែ ដ្យាក្រាម សំណេរស្រាវជ្រាវបែបគម្រោង លិខិតចូលរួមរំលែកទុក្ខ លិខិតសូមអភ័យទោស លិខិតថ្លែងអំណរគុណ លិខិតអញ្ជើញភ្ញៀវចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍ តែងអត្ថបទពណ៌នាខ្លីៗ តែងសេចក្តីបែបពិពណ៌នាពីរូបភាព
ឧបទ្ទវហេតុ សកម្មភាព ពិធីផ្សេងៗ និងការនិទានរឿង។

### ង- វេយ្យាករណ៍

សិស្សកត់សម្គាល់បញ្ញត្តិនិងចេះប្រើប្រាស់ប្រភេទពាក្យមានដូចជា សព្វនាមបុរិស សព្វនាមសំណួរ សព្វនាមចង្អុល គុណនាមប្រក្រតី គុណនាមកម្មសិទ្ធិ គុណនាមចំនួន វណ្ណយុត្តមានដូចជា សញ្ញារះមុខ(ះ) សញ្ញាដំលើ(៎) វណ្ណវាទមានដំណកឃ្លា ល្បះទោលមាន ផ្នែកផ្សេងៗនៃល្បះទោល ទម្រង់ល្បះទោល តែងល្បះទោល រចនាបថផ្ទាល់និងរចនាបថមិនផ្ទាល់។

## ៤- របាយម៉ោងសិក្សា

### ៤.១- របាយម៉ោងសម្រាប់ថ្នាក់ទី១ដល់ទី៣

មុខវិជ្ជាភាសាខ្មែរថ្នាក់ទី១-៣ មានរយៈពេលសិក្សាចំនួន**៣៥**សប្តាហ៍ក្នុងមួយឆ្នាំសិក្សា។ ចំនួនថ្ងៃសិក្សាក្នុងមួយសប្តាហ៍មាន៦ថ្ងៃ។ ចំនួនម៉ោងសិក្សាក្នុងមួយសប្តាហ៍មាន**១៣**ម៉ោង។ ក្នុង១ម៉ោងសិក្សាមានរយៈពេល៤០នាទី។ ចំនួនម៉ោងសរុបក្នុងមួយឆ្នាំសិក្សាមាន **៤៥៥**ម៉ោង។

### ៤.២- របាយម៉ោងសម្រាប់ថ្នាក់ទី៤ដល់ទី៦

មុខវិជ្ជាភាសាខ្មែរថ្នាក់ទី៤-៦ មានរយៈពេលសិក្សាចំនួន**៣៥**សប្តាហ៍ក្នុងមួយឆ្នាំសិក្សា។ ចំនួន ថ្ងៃសិក្សាក្នុងមួយសប្តាហ៍មាន៦ថ្ងៃ។ ចំនួនម៉ោងសិក្សាក្នុងមួយសប្តាហ៍មាន**៩**ម៉ោង។ ក្នុង១ម៉ោងសិក្សាមានរយៈពេល៤០នាទី។ ចំនួនម៉ោងសរុបក្នុងមួយឆ្នាំសិក្សាមាន**៣១៥**ម៉ោង។

### ៤.៣- តារាងរបាយម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរតាមកម្រិតថ្នាក់នីមួយៗពីថ្នាក់ទី១ដល់ថ្នាក់ទី៦

| ថ្នាក់ទី | ចំនួនសប្តាហ៍ ក្នុង១ឆ្នាំសិក្សា | ចំនួនថ្ងៃ ក្នុង១សប្តាហ៍ | ចំនួនម៉ោង ក្នុង១សប្តាហ៍ | ចំនួននាទី ក្នុង១ម៉ោងសិក្សា | ចំនួនម៉ោង ក្នុង១ឆ្នាំសិក្សា |
|---|---|---|---|---|---|
| ១ | ៣៥ | ៦ | ១៣ | ៤០ | ៤៥៥ |
| ២ | ៣៥ | ៦ | ១៣ | ៤០ | ៤៥៥ |
| ៣ | ៣៥ | ៦ | ១៣ | ៤០ | ៤៥៥ |
| ៤ | ៣៥ | ៦ | ៩ | ៤០ | ៣១៥ |
| ៥ | ៣៥ | ៦ | ៩ | ៤០ | ៣១៥ |
| ៦ | ៣៥ | ៦ | ៩ | ៤០ | ៣១៥ |

### ៤.៤- សមាសភាគ និងម៉ោងសិក្សានៃមុខវិជ្ជាភាសាខ្មែរថ្នាក់ទី១-៦

ម៉ោងសិក្សានៅតាមសមាសភាគនានានៃមុខវិជ្ជាភាសាខ្មែរ ត្រូវបានបែងចែកដូចខាងក្រោម៖

- ម៉ោងសិក្សាសម្រាប់សមត្ថភាពស្តាប់ មានចំនួនប្រហែល ១០%
- ម៉ោងសិក្សាសម្រាប់សមត្ថភាពនិយាយ មានចំនួនប្រហែល ១០%
- ម៉ោងសិក្សាសម្រាប់សមត្ថភាពអាន មានចំនួនប្រហែល ៣០%
- ម៉ោងសិក្សាសម្រាប់សមត្ថភាពសរសេរ មានចំនួនប្រហែល ៣០%
- ម៉ោងសិក្សាសម្រាប់បំណិន មានចំនួនប្រហែល ១០%
- ម៉ោងសិក្សាសម្រាប់វេយ្យាករណ៍ មានចំនួនប្រហែល ១០%។
- ម៉ោងសិក្សាសម្រាប់បំណិន មានចំនួនប្រហែល ១០%




## ៥- ការណែនាំអនុវត្ត

### ៥.១- ការអនុវត្តកម្មវិធីសិក្សាភាសាខ្មែរ

ការកែទម្រង់កម្មវិធីសិក្សាភាសាខ្មែរ ជាផ្នែកមួយក្នុង កំណែទម្រង់កម្មវិធីសិក្សានៃកម្មវិធីកំណែទម្រង់វិស័យអប់រំ ពោលគឺធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត។ ការកែទម្រង់កម្មវិធីសិក្សាភាសាខ្មែរ ធ្វើឡើងដោយផ្អែកតាមក្របខណ្ឌកម្មវិធីសិក្សា ដែលផ្ដោតចំណុចសំខាន់ៗដូចជា ប្រធានបទ លទ្ធផលសិក្សា ខ្លឹមសារគន្លឹះសំខាន់ៗ វិធីសាស្ត្របង្រៀន របាយម៉ោង ការវាយតម្លៃ ការពិនិត្យតាមដាន សៀវភៅសិក្សាគោល និងសម្ភារៈសិក្សា។ កម្មវិធីសិក្សាលម្អិតនេះ មានបួនសមត្ថភាពគឺ ស្ដាប់ និយាយ អាន និង សរសេរ។ នៅក្នុងសម្ថភាពនីមួយៗ បានកំណត់នូវលទ្ធផលសិក្សាទៅតាមកម្រិតថ្នាក់។ ដូច្នេះដើម្បីអនុវត្តកម្មវិធីសិក្សា ឱ្យមានប្រសិទ្ធភាពត្រូវ៖

- សៀវភៅសិក្សាគោល ៖ ការតាក់តែងសៀវភៅសិក្សាគោល ត្រូវមានទាំងសៀវភៅសម្រាប់សិស្ស និងសៀវភៅសម្រាប់គ្រូ។ សៀវភៅសិក្សាគោល ត្រូវរៀបចំឱ្យមានភាពគ្របដណ្ដប់ខ្លឹមសាររបស់កម្មវិធីសិក្សា និងមានចង្អុលបង្ហាញពី ខ្លឹមសារគន្លឹះសំខាន់ៗ វិធីសាស្ត្រ ម៉ោងសិក្សា សម្ភារឧទេស ការវាយតម្លៃ និងផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្ដែង។ ការរៀបចំសៀវភៅសិក្សាគោល ត្រូវធានាថា សិស្សគ្រប់តំបន់ ជនជាតិ ជនពិការអាចយកមកច្នៃប្រឌិតអនុវត្តបានទាំងអស់គ្នា។
- ការអនុវត្តម៉ោងសិក្សា៖ របាយម៉ោងកម្មវិធីសិក្សាភាសាខ្មែរ អនុវត្តតាមម៉ោងកំណត់ក្នុងក្របខណ្ឌកម្មវិធីសិក្សា។ ម៉ោងសិក្សាត្រូវបានបែងចែកទៅតាមសម្ថភាពស្ដាប់ និយាយ អាន សរសេរ បំណិន និងវេយ្យាករណ៍។ ការអនុវត្តម៉ោងសិក្សា ត្រូវមានភាពទន់ភ្លន់ និងត្រឹមត្រូវច្បាស់លាស់ ទើបមានប្រសិទ្ធភាព។
- ការវាយតម្លៃ ៖ ការវាយតម្លៃត្រូវធ្វើជាប្រចាំ អាស្រ័យនឹងពេលវេលា និងប្រភេទតេស្តនីមួយៗ។ រាល់ការធ្វើតេស្តត្រូវមានឧបករណ៍សម្រាប់វាយតម្លៃជាការចាំបាច់។ ឧបករណ៍តេស្ត គួររៀបចំជារួមទៅតាមកម្រង ខណ្ឌ ក្រុង ស្រុក រាជធានី ខេត្ត និងអាចប្រើឧបករណ៍ថ្នាក់ជាតិ។ ការវាយតម្លៃមានច្រើនរូបភាពគឺការសង្កេត ការសម្ភាស ការពិនិត្យតាមដាន និងការធ្វើតេស្ត។ ការធ្វើតេស្ត មានច្រើនរូបភាពដូចជា បុរេតេស្ត តេស្តតាមដំណាក់

(តេស្តវាយតម្លៃដំណើរការរៀននិងបង្រៀន និងតេស្តវាយតម្លៃសមត្ថភាពសិស្ស) តេស្តបញ្ចប់ តេស្តប្រចាំខែ តេស្តប្រចាំឆមាស តេស្តថ្នាក់ជាតិ និងការប្រឡងថ្នាក់ជាតិ។ ចំពោះតេស្តប្រចាំខែនិងឆមាស គួរធ្វើឡើងដោយមានឧបករណ៍តេស្តរួមគ្នាទៅតាមកម្រង ខណ្ឌ ក្រុង ស្រុក រាជធានីខេត្ត និងអាចប្រើឧបករណ៍ថ្នាក់ជាតិ។

- សម្ភារឧបទេស : សម្ភារឧបទេស គឺជាសមាសភាគចាំបាច់មួយ សម្រាប់ជួយឱ្យការរៀននិងបង្រៀនមានប្រសិទ្ធភាព។ ការប្រើប្រាស់សម្ភារឧបទេស ត្រូវធានាថាបានប្រើប្រាស់ទាំងគ្រូទាំងសិស្ស។ សម្ភារឧបទេសមានដូចជា សម្ភារៈជាក់ស្តែង សម្ភារៈច្នៃប្រឌិត ករណីសិក្សា ឯកសារផ្សេងៗ សម្ភារៈអេឡិចត្រូនិច អ៊ិនធើណែត និងប្រព័ន្ធបណ្តាញសង្គមជាដើម។
- ឯកសារជំនួយ : ការប្រើប្រាស់សៀវភៅសិក្សាគោលតែមួយមុខ មិនគ្រប់គ្រាន់សម្រាប់ការអនុវត្តកម្មវិធីសិក្សាឱ្យបានល្អនោះទេ។ ការផលិតនិងប្រើប្រាស់ឯកសារជំនួយ គឺមានសារៈសំខាន់ណាស់សម្រាប់ជួយដល់ដំណើរការរៀននិងបង្រៀន។ ឯកសារជំនួយមានដូចជា អំណានបន្ថែម សម្ភារៈសិក្សា គរុកោសល្យ វិធីសាស្ត្របង្រៀន លំហាត់កិច្ចការ ខ្លឹមសារគន្លឹះ ឧបករណ៍វាយតម្លៃ និងឯកសារយោងផ្សេងៗជាដើម។
- ការយល់ដឹងពីកម្មវិធីសិក្សា : សមាសភាគសំខាន់ៗមាន លទ្ធផលសិក្សា(វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា) វិធីសាស្ត្របង្រៀន របាយម៉ោងសិក្សា សម្ភារឧបទេស ឯកសារជំនួយ ការណែនាំអនុវត្តប្រធានបទ ការវាយតម្លៃ និងឯកសារជំនួយ។ ដើម្បីអនុវត្តកម្មវិធីសិក្សាមានប្រសិទ្ធភាព គ្រូបង្រៀននិងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវយល់ដឹងពីកម្មវិធីសិក្សា និងចេះប្រើប្រាស់កម្មវិធីសិក្សា ព្រមទាំងដាក់បញ្ចូលលទ្ធផលសិក្សាទៅក្នុងកិច្ចតែងការបង្រៀន និងបំណែងចែកកម្មវិធីបង្រៀនប្រចាំខែ។
- ការផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្តែង : ការរៀននិងបង្រៀនភាសាខ្មែរ ត្រូវផ្សារភ្ជាប់ជាមួយនឹងជីវភាពជាក់ស្តែង។ ក្នុងការរៀននិងបង្រៀន ធ្វើយ៉ាងណាឱ្យសិស្សទទួលបាននូវចំណេះដឹងនិងបំណិនឬជំនាញ។ សិស្សត្រូវយល់ដឹងពីសារៈសំខាន់និងសារប្រយោជន៍នៃចំណេះដឹងនិងបំណិនឬជំនាញទាំងនោះ ហើយចេះយកចំណេះដឹងនិងបំណិនឬជំនាញទាំងនោះទៅប្រើប្រាស់ឬអនុវត្ត សំដៅធ្វើឱ្យទទួលបាននូវគុណតម្លៃ ដែលកើតឡើងពីការសិក្សាភាសាខ្មែរគ្រប់កម្រិត។

### ៥.២- ការប្រើប្រាស់វិធីសាស្ត្របង្រៀន

- វិធីសាស្ត្របង្រៀន : ការបង្រៀនភាសាខ្មែរ ធ្វើយ៉ាងណាឱ្យសិស្សយល់ដឹងពីរបៀបរៀនដោយខ្លួនឯង ពោលគឺមិនត្រូវឱ្យសិស្សរៀនបានត្រឹមតែត្រាប់តាមនោះទេ។ គ្រូគប្បីប្រើប្រាស់វិធីសាស្ត្របង្រៀនសម្បូរបែបស្របតាមកាលៈទេសៈ និងស្ថានភាព ជាពិសេសវិធីសាស្ត្របង្រៀនថ្មីៗមានវិធីសាស្ត្របែបសំយោគ បែបស្រាវជ្រាវ បែបសហការ និងបែបរិះរកជាដើម។ យើងអាចនិយាយបានថា ការបង្រៀនត្រូវរកឱ្យឃើញចំណុចគន្លឹះដែលអាចធ្វើឱ្យសិស្សយល់ដឹងច្បាស់លាស់។ ឧទាហរណ៍ : ចំណុចគន្លឹះក្នុងការបង្រៀនពាក្យមួយ ត្រូវឱ្យសិស្សចេះបួនចំណុចគឺ ចេះអានពាក្យ យល់ន័យពាក្យ ចេះសរសេរពាក្យ និងចេះប្រើប្រាស់ពាក្យ។ ចំណុចគន្លឹះក្នុងការបង្រៀនវេយ្យាករណ៍ ត្រូវឱ្យសិស្សចេះបកស្រាយបញ្ញត្តិ ចេះវិភាគ និងចេះប្រើប្រាស់។ ការរៀននិងបង្រៀនភាសាខ្មែរត្រូវយកចិត្តទុកដាក់ប្រើប្រាស់សំណួរទាំង៦កម្រិតគឺ ចងចាំ យល់ដឹង អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី។
- ការប្រើប្រាស់វិធីសាស្ត្របង្រៀន នៅក្នុងសកម្មភាពរៀននិងបង្រៀន ជាទូទៅគ្រូបង្រៀនត្រូវពិចារណាទៅលើការប្រើប្រាស់វិធីសាស្ត្របង្រៀនដ៏សម្បូរបែបដូចជា វិធីសាស្ត្របែបរិះរក វិធីសាស្ត្រសកម្ម វិធីសាស្ត្រសំយោគ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ការប្រើវិធីអនុមានញែក អនុមានរួម អន្តរកម្ម ការណែនាំសកម្មភាពស្រាវជ្រាវ និងការប្រើល្បិចបង្រៀនផ្សេងៗ ដើម្បីធានាបាននូវគុណភាពសិក្សា។ ដូច្នេះមុននឹងចាប់ផ្តើមបង្រៀនមេរៀននីមួយៗ អ្នកគ្រូ លោកគ្រូ គប្បីយល់ពីខ្លឹមសារ និងវត្ថុបំណងមេរៀន កំណត់រយៈពេលបង្រៀន និង

សម្ភារៈដោយមានការរៀបចំកិច្ចតែងការបង្រៀនឱ្យស្របទៅតាមខ្លឹមសារមេរៀននិងតាមកម្រិតថ្នាក់នីមួយៗជាមុនសិន ដោយផ្តោតលើវិធីសាស្ត្របង្រៀនដែលមានប្រសិទ្ធភាពក្នុងការបង្រៀនសមត្ថភាពទាំងបួន។ ពិសេសត្រូវសង្កត់ធ្ងន់ទៅលើសមត្ថភាពអាននិងសរសេរដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការរៀនអក្សរដំបូង។ ក្នុងការបង្រៀនគ្រូត្រូវ៖

- ប្រើក្តារខៀនដែលមានគូសក្រឡាទម្រង់៣/៤
- ប្រើក្តារឆ្នួនដែលមានក្រឡាទម្រង់៣/៤
- ប្រើសៀវភៅសរសេរដែលមានក្រឡាទម្រង់៣/៤
- ណែនាំពីរបៀបប្រើក្តារឆ្នួន របៀបកាន់ និងរបៀបសរសេរជាដើម
- ណែនាំពីរបៀបប្រើសៀវភៅសរសេរ ការកាន់ខ្មៅដៃ ឬប៊ិក ការដាក់សៀវភៅ និងសរសេរ
- ការពិនិត្យសៀវភៅសរសេររបស់សិស្សជាប្រចាំ និងដាក់ពិន្ទុ
- បិទតាំងសំណេរផ្សេងៗក្នុងបន្ទប់ រៀបចំ និងគ្រប់គ្រងស្នាដៃសិស្ស
- គ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព។
- ស្វែងយល់ និងណែនាំសិស្សឱ្យយល់ច្បាស់ពីគោលបំណងនិងសារៈសំខាន់នៃការសិក្សាពីសមត្ថភាព
- ស្តាប់ និយាយ អាន សរសេរ និងបំណិនផ្សេងៗព្រមទាំងការអភិវឌ្ឍឥរិយាបថរបស់សិស្សក្នុងការសិក្សា
- ណែនាំសិស្សឱ្យយល់ដឹងពីវិធីរៀនដោយខ្លួនឯង និងណែនាំសម្របសម្រួលរាល់ដំណឹកនាំ សកម្មភាពសិក្សានៅក្នុងថ្នាក់ សាលារៀន និងក្រៅសាលា នូវរបៀបសិក្សាស្រាវជ្រាវតាមរយៈសកម្មភាព បុគ្គល ដៃគូ ក្រុមតូច និងក្រុមធំ។
- សកម្មភាពរៀននិងបង្រៀន ត្រូវយកចិត្តទុកដាក់ទៅលើ ការបង្រៀនខ្លឹមសារមេរៀនបានច្បាស់ លាស់ ដោយឱ្យសិស្សមានការហ្វឹកហាត់  អនុវត្តដោយផ្ទាល់ និងមានការវាយតម្លៃជាប្រចាំ។
- រៀបចំលំនាំរៀននិងបង្រៀនអំណានដំបូង ដោយអនុវត្តវិធីសាស្ត្រសំយោគ។ ដូច្នេះក្នុងការរៀន និងបង្រៀនតួអក្សរត្រូវឱ្យសិស្សស្គាល់ឈ្មោះតួអក្សរ ស្គាល់សូរ និងចេះប្រើប្រាស់។ ការរៀន និងបង្រៀនពាក្យមួយគប្បីអនុវត្តសកម្មភាពមួយចំនួនដូចជាការស្គាល់ឈ្មោះតួអក្សរនៅក្នុងពាក្យ ការស្គាល់សូរតួអក្សរនៅក្នុងពាក្យ ការស្គាល់ចំនួនសូរ ការស្គាល់ទីតាំងសូរ ការចេះវិធីផ្សំសូរ ការចេះអានដោយប្រកប ការអានដោយមិនផ្សំប្រកប(អានស្ទាត់) ការយល់ន័យពាក្យ និងការចេះប្រើប្រាស់ពាក្យជាដើម សំដៅធ្វើយ៉ាងណាឱ្យការរៀនពាក្យមួយសិស្សត្រូវចេះអាន ចេះសរសេរ យល់ន័យ និងចេះប្រើប្រាស់ពាក្យបានត្រឹមត្រូវ។
- រៀបចំលំនាំរៀននិងបង្រៀនភាសាខ្មែរដោយអនុវត្តវិធីសាស្ត្រវិភាគ។ គ្រូត្រូវរៀបចំសកម្មភាព រៀននិងបង្រៀន ឱ្យសម្បូរបែបទាំងក្នុងថ្នាក់ ក្រៅថ្នាក់ ក្នុងសហគមន៍ ធ្វើយ៉ាងណាឱ្យសិស្ស យល់ដឹង ពីវិធីរៀនដោយខ្លួនឯង និងចៀសវាងការរៀនបានត្រឹមតែត្រាប់តាម ឬអនុវត្តបានតែធ្វើត្រាប់តាមគ្រូ។
- រៀបចំលំនាំរៀននិងបង្រៀនដែលមានសមាសភាគទាំង៥នៃអំណានគឺ ការយល់ដឹងពីសូរ ទំនាក់ទំនងរវាងសូរនិងតួអក្សរ បំណិនវាក្យសព្ទ ការអានស្ទាត់ និងការអានដើម្បីយល់ន័យ។
- រៀបចំលំនាំរៀននិងបង្រៀនសំណេរ ដោយអនុវត្តវិធីសាស្ត្រហ្វឹកហាត់សរសេរបែបចម្លង សរសេរបែបរៀបចំ និងសរសេរបែបត្រួតពិនិត្យ គឺធ្វើយ៉ាងណាធានាថាសិស្សចេះធ្វើអក្ខរាវិរុទ្ធ និងសរសេរបានស្អាតត្រឹមត្រូវ។
- រៀបចំសិស្សឱ្យមានសកម្មភាពច្រើនក្នុងការសិក្សាដូចជាសកម្មភាព ល្បែងដើរតួ ការពិភាក្សា ការស្រាវជ្រាវ ការសិក្សាបែបគម្រោង ដោយបណ្តុះនូវស្មារតីឱ្យចេះសហការ ចូលរួម សាមគ្គីភាព ភាពម្ចាស់ការ ការទទួលខុសត្រូវតាមតួនាទី និងភារកិច្ចក្រុម ក្រោមការសម្របសម្រួលពីគ្រូបង្រៀន។

- រៀបចំសកម្មភាពរៀន និងបង្រៀន ដើម្បីបណ្ដុះសិស្សឱ្យរៀនតាមបែបស្វ័យសិក្សា ការបង្កើត ក្លិបសិក្សា នៅក្នុងសាលារៀន ក្រៅសាលារៀន ឬសហគមន៍ ដើម្បីពង្រឹងចំណេះដឹងសិស្សបន្ថែម បណ្ដុះចំណង់ចំណូលចិត្តអាន និងបណ្ដុះចំណង់ចំណូលចិត្តស្រាវជ្រាវជាដើម។
- សកម្មភាពនីមួយៗត្រូវមានអន្តរកម្ម ឬទំនាក់ទំនងរវាងគ្រូ និងសិស្សនៅក្នុងថ្នាក់រៀន។ គ្រូបង្រៀនមិនត្រូវនិយាយបន្ទុះបង្អាប់សិស្ស ហើយមានឥរិយាបថទន់ភ្លន់តែម៉ឺងម៉ាត់ និងចេះ យោគយល់អធ្យាស្រ័យ
- រាល់កំហុស ដែលសិស្សប្រព្រឹត្តដោយចេតនា ឬអចេតនាក្ដី។
- យកចិត្តទុកដាក់បង្រៀនសិស្សគ្រប់សមត្ថភាព មិនត្រូវផ្ដោតតែលើសមត្ថភាពណាមួយ ឡើយ។
- ជំរុញសិស្សឱ្យមានភាពក្លាហានចូលរួមសិក្សា ក្នុងការបញ្ចេញមតិយោបល់ គាំទ្រ ជំទាស់
- បង្ហាញហេតុផល  ហ៊ានសួរ ឆ្លើយ ហ៊ានទទួលខុសត្រូវ ស្ថិតក្នុងក្របខ័ណ្ឌវិន័យ និងច្បាប់។
- បណ្ដុះចំណង់ចំណូលចិត្តក្នុងការតាក់តែង ឬការសរសេរអត្ថបទកំណាព្យ ចម្រៀងខ្លីៗជាដើម។
- រៀបចំសកម្មភាពរៀននិងបង្រៀនស្របទៅតាមកម្មវិធីសាលាកុមារមេត្រី និងក្របខណ្ឌសាលារៀនសុវត្ថិភាព។
- បញ្ចូលការអប់រំអំពីបរិស្ថាន ការអប់រំពលរដ្ឋសកល យែនឌ័រ សុវត្ថិភាពចរាចរណ៍ ការប្រឆាំង អំពើពុករលួយ វប្បធម៌សន្តិភាព អនាម័យ សុខភាព ចំណីអាហារ ច្បាប់ សិទ្ធិមនុស្ស ទេសចរណ៍ និងវិធីដោះស្រាយបញ្ហាផ្សេងៗក្នុងមេរៀន។
- រៀបចំការវាយតម្លៃផ្សេងៗ ដើម្បីវាស់ស្ទង់លទ្ធផលសិក្សារបស់សិស្សនៅក្នុងដំណើរការរៀននិងការបង្រៀន ក្រោយពីបញ្ចប់ខ្លឹមសារមេរៀន ជំពូក វាយតម្លៃតាមដំណាក់កាល ប្រចាំខែ ឆមាស និងប្រចាំឆ្នាំជាដើម។

## ៥.៣- ការប្រើប្រាស់សម្ភារៈ

### ក- ឯកសារជំនួយសម្រាប់រៀបចំដំណើរការរៀននិងបង្រៀន

ឯកសារជំនួយផ្សេងៗ ពិតជាមានសារៈសំខាន់ណាស់សម្រាប់លោកគ្រូ អ្នកគ្រូ ប្រើប្រាស់ក្នុង ការរៀបចំដំណើរការរៀន និងបង្រៀនឱ្យបានល្អ។ លោកគ្រូ អ្នកគ្រូ គប្បីចេះច្បិចយកចំណុចសំខាន់ៗ ដែលពាក់ព័ន្ធនឹងខ្លឹមសារមេរៀន ដើម្បីយកមករៀបចំខ្លឹមសារមេរៀន។ ឯកសារជំនួយសម្រាប់រៀបចំ ដំណើរការរៀន និងបង្រៀនមានដូចជា សៀវភៅសិក្សាគោលសម្រាប់សិស្ស សៀវភៅណែនាំគ្រូ សៀវភៅកិច្ចការ សៀវភៅលំហាត់ ឯកសារវិធីសាស្ត្របង្រៀន និងជំនួយគរុកោសល្យ ឯកសារណែនាំផលិត និងប្រើប្រាស់សម្ភារឧបទេស កិច្ចតែងការបង្រៀន ការសិក្សាបែបគម្រោង ស្តង់ដាអំណាន ឯកសារតេស្តវាយតម្លៃ ឯកសារសម្រាប់សិក្សាស្រាវជ្រាវ និងឯកសារយោងផ្សេងៗទៀត។

### ខ- សម្ភារៈឧបទេស

សម្ភារៈឧបទេស ជាមធ្យោបាយ និងជាលក្ខខណ្ឌចាំបាច់ សម្រាប់ប្រើប្រាស់ក្នុងដំណើរការរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព។ ដូច្នេះសម្ភារឧបទេស គឺជាធនធានទាំងឡាយណាដែលគ្រូ និងសិស្សយកមកប្រើប្រាស់ក្នុងការរៀននិងបង្រៀន ដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែជាក់លាក់ច្បាស់ លាស់ ងាយយល់ ងាយចាប់បាន ហើយអាចសម្រេចវត្ថុបំណងមេរៀនបានល្អប្រសើរ។ សម្ភារឧបទេសត្រូវមានទាំងគ្រូទាំងសិស្ស។ ការបង្រៀនដោយប្រើប្រាស់សម្ភារឧបទេស គឺជាការជួយពង្រឹងដល់ការសិក្សារបស់សិស្ស ឱ្យកាន់តែយល់ច្បាស់នូវន័យរបស់ពាក្យ កន្សោមពាក្យ ឃ្លា ល្បះ កថាខណ្ឌ និងអត្ថបទផ្សេងៗ។ អ្នកគ្រូ លោកគ្រូ ត្រូវឱ្យសិស្សហាត់ប្រើសម្ភារៈដោយខ្លួនឯង ដើម្បីឱ្យសិស្សកាន់តែយល់ច្បាស់ខ្លឹមសារមេរៀនដែលបានបង្រៀនរួច។ កត្តាសំខាន់ គ្រូបង្រៀនត្រូវកំណត់ សម្ភារៈបង្រៀនឱ្យបានច្បាស់លាស់ទៅតាមតម្រូវការនៃមេរៀននីមួយៗ។ សម្ភារឧបទេស ដែលគ្រូបង្រៀនត្រូវប្រើប្រាស់សម្រាប់ដំណើរការរៀន និងបង្រៀនគឺជាសម្ភារៈទាំងឡាយណាដែលងាយរក ងាយផលិត និងប្រើប្រាស់ហើយមានគុណភាពនិងប្រសិទ្ធភាព។

សម្ភារឧបទេសទាំងនោះមាន សម្ភារៈរូបី ពាក់កណ្ដាលរូបី និងអរូបី។

### ខ.១- សម្ភារៈរូបី

កម្មវិធីសិក្សាលម្អិតចំណេះទូទៅសម្រាប់បឋមសិក្សា ទាមទារឱ្យគ្រូបង្រៀនចេះប្រើប្រាស់វត្ថុ ពិតជាក់ស្ដែង រុក្ខជាតិឬធម្មជាតិ សត្វ មកពន្យល់បង្ហាញដើម្បីបង្កើនការយល់ដឹងអំពីបញ្ញត្តិ ឬខ្លឹមសារឬសម្ភារៈពិតមេរៀនទាក់ទង នឹងការសិក្សាពីអំណានឬសំណេរពាក្យ ឃ្លា ល្បះនិងអត្ថបទ។ ចំពោះសម្ភារៈរូបី គឺសំដៅលើប្រភេទសម្ភារៈមួយចំនួន ដូចជា កែវ ចូ កង់ មួក ចង្អេរ ផ្លែចេក មាន់...។

### ខ.២- សម្ភារៈពាក់កណ្ដាលរូបី

កម្មវិធីសិក្សាលម្អិតចំណេះទូទៅសម្រាប់បឋមសិក្សា ទាមទារឱ្យគ្រូបង្រៀនចេះផលិត និងប្រើប្រាស់សម្ភារៈពាក់កណ្ដាលរូបី។ សម្ភារៈពាក់កណ្ដាលរូបី សំដៅលើប្រភេទសម្ភារៈមួយចំនួន ដែល ផលិតពីរូបពិត និងវត្ថុពិត។ សម្ភារៈទាំងនេះមានដូចជា រូបថតឬរូបភាពមនុស្ស សត្វ វត្ថុ រុក្ខជាតិ ឬធម្មជាតិ ដែលគ្រូផលិតឡើងសម្រាប់ជាជំនួយក្នុងការរៀន និងបង្រៀន។

### ខ.៣- សម្ភារៈអរូបី

សម្ភារៈអរូបី គឺជាសម្ភារៈដែលមិនមានរូបជាតំណាងទេ ប៉ុន្តែវាមានលក្ខណៈជាគ្រឿងសម្គាល់ឈ្មោះមនុស្ស សត្វ វត្ថុ និងរុក្ខជាតិដែលត្រូវផលិតឡើងតាមរយៈបណ្ណអក្សរចល័ត បណ្ណពាក្យ។សម្ភារៈទាំងនេះ គ្រូផលិតឡើង សម្រាប់ជាជំនួយក្នុងការរៀន និងបង្រៀន។

### ខ.៤- សម្ភារៈអេឡិចត្រូនិច

ក្រៅពីការណែនាំប្រើប្រាស់សម្ភារៈសំខាន់ៗទាំងបីខាងលើ អ្នកគ្រូ លោកគ្រូ ត្រូវមានសមត្ថភាពក្នុងការប្រើប្រាស់ ប្រភេទសម្ភារៈអេឡិចត្រូនិចទំនើបមួយចំនួនទៀតដូចខាងក្រោម៖

**- សម្ភារៈអេឡិចត្រូនិចសម្រាប់ការរៀន និងបង្រៀន**

សម្ភារឧបទេសប្រភេទនេះ ជាសម្ភារៈទំនើបដែលគ្រូបង្រៀនអាចយកមកប្រើប្រាស់សម្រាប់រៀន និងបង្រៀន ដើម្បីសម្រួលដល់ការបង្រៀន ការប្រើប្រាស់ពេលវេលា ការធ្វើតេស្តសិស្ស និងការទាក់ទាញការចូលរួមរបស់សិស្សផង ដែរ។ សម្ភារៈអេឡិចត្រូនិចទាំងនេះមានដូចជា កុំព្យូទ័រ កម្មវិធី បង្រៀនតាមសៀវភៅអេឡិចត្រូនិច កម្មវិធីបង្រៀន អំណាន កម្មវិធីធ្វើតេស្តតាមថាប់ប្លែត(Tablets)។ល។

**- សម្ភារៈអេឡិចត្រូនិចសម្រាប់ធ្វើបទបង្ហាញ**

សម្ភារឧបទេសប្រភេទនេះ សំដៅលើសម្ភារៈសម្រាប់គ្រូធ្វើបទបង្ហាញសង្ខេបពីខ្លឹមសារមេរៀនឬប្រធានបទ ផ្សេងៗទាក់ទងការរៀននិងបង្រៀន។ សម្ភារៈប្រភេទនេះមានការទាក់ទាញអារម្មណ៍អ្នកសិក្សាឬអ្នកចូលរួមបានច្រើន។ សម្ភារៈនេះ ទាមទារឱ្យមានការរៀបចំនិងចងក្រងខ្លឹមសារមេរៀន ឬប្រធានបទនានាតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មានទំនើបដោយប្រើប្រាស់កម្មវិធីមួយចំនួនរបស់កុំព្យូទ័រ ព្រមទាំងសម្ភារៈមួយចំនួនទៀតដូចជាឌីវីឌី ម៉ាញ៉េ វីដេអូ ជាដើម។

**- សម្ភារៈអេឡិចត្រូនិចសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងផ្ដល់ព័ត៌មាន**

សម្ភារៈសម្រាប់ធ្វើការសិក្សាស្រាវជ្រាវមានដូចជាការស្រាវជ្រាវតាមកុំព្យូទ័រ ប្រព័ន្ធអ៊ិនធឺណែត អ៊ីមែល ហ្វេសប៊ុក តេឡេក្រាម យូធូប និងទូរស័ព្ទជាដើម។ សម្ភារៈប្រភេទនេះ ទាមទារឱ្យគ្រូបង្រៀនមានសមត្ថភាពគ្រប់គ្រាន់ និងចំណេះ ដឹងពីបច្ចេកវិទ្យាព័ត៌មានឱ្យច្បាស់លាស់។ លើសពីនេះទៅទៀត ទាមទារចំណេះដឹងផ្នែកភាសាបរទេស ពិសេសគឺ ភាសាអង់គ្លេស។ នៅក្នុងកម្មវិធីទាំងនេះ យើងអាចមើលឃើញឯកសារជាច្រើនជុំវិញពិភពលោក។ ការសិក្សាស្រាវ ជ្រាវដោយប្រើប្រាស់សម្ភារៈទាំងនេះ ធ្វើឱ្យមានការយល់ដឹងកាន់តែទូលំទូលាយ។

## ៦- ការវាយតម្លៃ

ការវាយតម្លៃជាការវាស់ស្ទង់សមត្ថភាពសិស្សដើម្បីឱ្យដឹងថា លទ្ធផលនៃការសិក្សារបស់សិស្សទទួលបានកម្រិតណា ដោយផ្អែកលើស្តង់ដាកម្មវិធី និងកម្មវិធីសិក្សាលម្អិត។ ការប្រើប្រាស់ប្រភេទវាយតម្លៃទាំងអស់នឹងជួយឱ្យការវាយតម្លៃបានច្បាស់លាស់ថា តើលទ្ធផលសិក្សារបស់សិស្សបាន សម្រេចតាមស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតដែរ ឬទេ? នៅពេលបង្រៀនបំណិន ឬមេរៀននីមួយៗចប់ អ្នកគ្រូ លោកគ្រូ ត្រូវធ្វើការវាយតម្លៃ ដើម្បីវាស់ស្ទង់លទ្ធផលនៃការសិក្សារបស់សិស្ស។ការវាយតម្លៃត្រូវធ្វើជាប្រចាំតាមដំណាក់រហូតបញ្ចប់ និងការប្រឡងប្រចាំខែប្រចាំត្រីមាសប្រចាំឆមាស។ ការវាយតម្លៃត្រូវឱ្យសមស្របទៅនឹងលទ្ធផលសិក្សាតាមកម្រិតថ្នាក់នីមួយៗ។

### ៦.១- គោលបំណង

ការវាយតម្លៃការសិក្សារបស់សិស្ស ជាផ្នែកមួយដ៏សំខាន់នៃការរៀននិងបង្រៀន។ ជាទូទៅការវាយតម្លៃមានគោលបំណងដូចតទៅ៖

- វាស់កម្រិតចំណេះដឹង បំណិន ឬសមត្ថភាពរបស់សិស្សក្រោយពីបានសិក្សាចប់មេរៀន ជំពូក ប្រធានបទ ឬកម្មវិធីសិក្សាតាមថ្នាក់ តាមមុខវិជ្ជា ឬក៏តាមភូមិសិក្សានីមួយៗ។
- វាស់កម្រិតនៃការប្រែប្រួលឬការរីកចម្រើនផ្លូវចិត្ត និងគុណតម្លៃនានាដូចជាតម្លៃសីលធម៌ ឥរិយាបថសាមគ្គីភាព ព្រហ្មវិហារធម៌។ល។
- ឆ្លុះបញ្ចាំងពីលទ្ធផលនៃការរៀន និងបង្រៀនដោយផ្តល់ព័ត៌មានត្រឡប់ក្នុងការជួយគ្រូ សិស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស និងគណៈគ្រប់គ្រង ដើម្បីលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀនឱ្យកាន់តែមានគុណភាពនិងប្រសិទ្ធភាពខ្ពស់។
- ដើម្បីជួយសិស្សក្នុងការរៀនសូត្រ នេះគឺជាគំនិតទី១ដែលគេនិយាយពីរង្វាយតម្លៃ។ ចំណុចនេះ មានសារៈសំខាន់ណាស់ សម្រាប់ជួយដល់គ្រូបង្រៀនតាមថ្នាក់។
- ដើម្បីស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្ស ការវាយតម្លៃចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្ស គឺជាការចាំបាច់ដើម្បីគោលបំណងពីរយ៉ាងគឺ ទីមួយដើម្បីកសាង និងកសាងឡើងវិញនូវសកម្មភាពរៀន និងទីពីរដើម្បីរៀបចំកែសម្រួលឡើងវិញនូវទម្រង់កម្មវិធីសិក្សា។ ពាក់ព័ន្ធទៅនឹងគោលបំណងទី១ ឧទាហរណ៍ថា ទិន្នន័យដែលបានមកពីចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្សលើខ្លឹមសារនិងបំណិនគឺមានសារៈសំខាន់ណាស់ ក្នុងការរៀបចំខ្លឹមសារឱ្យបានសមស្រប សម្រាប់អភិវឌ្ឍទាំងបំណិននិងបញ្ញា។ នេះគឺជារង្វាយតម្លៃវិនិច្ឆ័យរង្វាយតម្លៃមុនពេលរៀន។ ចំពោះគោលបំណងទី២ ដែលនិយាយអំពីទិន្នន័យនៃចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្សនៅលើខ្លឹមសារ និងបំណិនគឺមានប្រយោជន៍ណាស់សម្រាប់ការកែលម្អកម្មវិធីសិក្សា។
- ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃយុទ្ធវិធីបង្រៀន វាគឺជាការសំខាន់ណាស់ ដែលអ្នកត្រូវដឹងថា តើយុទ្ធវិធីមួយណាដែលជួយឱ្យសម្រេចគោលដៅ ឬវត្ថុបំណងបានល្អជាងគេ។ គ្រូដែលមានសមត្ថភាព គឺឆ្លុះបញ្ចាំងនិងវាយតម្លៃជាបន្តបន្ទាប់នូវឱកាសជាយុទ្ធសាស្ត្ររបស់គេ ដោយប្រើប្រភពជាច្រើនដូចជា សមិទ្ធិផលសិស្សមកធ្វើជារង្វាស់សម្រាប់វាយតម្លៃ ប្រើអព្ភន្តរញាណរបស់គេ ប្រើមតិត្រឡប់ធម្មតាដែលផ្តល់ដោយសិស្ស និងជួនកាលប្រើមតិត្រឡប់ធម្មតារបស់សហសេវិក ដូចជាសមាជិកក្រុមគ្រូបង្រៀន ឬគ្រូណែនាំ។
- ដើម្បីវាយតម្លៃនិងបង្កើនប្រសិទ្ធភាពនៃកម្មវិធីសិក្សា សមាសភាគនៃកម្មវិធីសិក្សា ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយគណៈកម្មការមួយដោយមានគ្រូបង្រៀន និងបុគ្គលិកគ្រប់គ្រងរដ្ឋបាល។ រង្វាយតម្លៃធ្វើឡើងខណៈដែលសិស្សកំពុងតែរៀនគឺធ្វើរង្វាយតម្លៃតាមដំណាក់ហើយបន្ទាប់មកគឺធ្វើការវាយតម្លៃសរុប។

- ដើម្បីវាយតម្លៃនិងបង្កើនប្រសិទ្ធភាពនៃការបង្រៀន ពោលគឺការធ្វើឱ្យការរៀនរបស់សិស្សរីកចម្រើន គ្រូត្រូវបានទទួលការវាយតម្លៃជាដំណាក់ៗ ដោយផ្អែកលើមូលដ្ឋាននេះ៖
  - ការប្រព្រឹត្តរបស់គ្រូក្នុងការធ្វើការងារជាមួយសិស្សក្នុងកម្រិតណាមួយ
  - សមត្ថភាពរបស់គ្រូក្នុងដំណោះស្រាយបញ្ហាជាមួយសិស្ស ទៅតាមកម្រិតអាយុ និងតាមកម្រិតថ្នាក់
  - សមត្ថភាពរបស់គ្រូដែលបង្ហាញពីការគ្រប់គ្រងបាននូវបច្ចេកទេសបង្រៀនបានសមស្រប។
- ដើម្បីផ្តល់ទិន្នន័យដែលជួយសម្រួលដល់ការធ្វើការសម្រេចចិត្ត អំពីអនាគតរបស់សិស្ស រង្វាយតម្លៃពីសមិទ្ធិផលរបស់សិស្ស គឺមានសារសំខាន់ណាស់ក្នុងការបង្ហាញផ្លូវជំនួយដល់សេចក្តីសម្រេចចិត្តពីវគ្គសិក្សា និងកម្មវិធីរៀបសិស្សតាមកន្លែង ការដំឡើងថ្នាក់ ការផ្ទេរការសិក្សា ការឈរថ្នាក់ ការទទួលកិត្តិយស អាហារូបករណ៍ អាជីព ការបន្តការសិក្សា។
- ដើម្បីប្រាស្រ័យទាក់ទងជាមួយមាតាបិតា ឬអាណាព្យាបាលសិស្ស អំពីការរៀនសូត្ររបស់កូនចៅរបស់ពួកគាត់។ មាតាបិតាសិស្ស សហគមន៍ និងគណៈនាយកសាលារៀន ត្រូវរួមចំណែកទទួលខុសត្រូវទាំងអស់គ្នាលើប្រសិទ្ធភាពនៃការរៀនរបស់សិស្ស។ សាលារៀនបច្ចុប្បន្ននេះ គឺបានផ្សារភ្ជាប់មាតាបិតា ឬអាណាព្យាបាលសិស្ស និងសហគមន៍ទៅក្នុងការអប់រំសិស្ស។ គ្រូទាំងអស់ គឺមានតួនាទីដើរតួដ៏សំខាន់នៅក្នុងដំណើរការប្រាស្រ័យទាក់ទងជាមួយមាតាបិតាឱ្យចូលរួមជាមួយសាលារៀន ។

## ៦.២- គោលការណ៍វាយតម្លៃ

ការវាយតម្លៃមានគោលការណ៍ មួយចំនួនសម្រាប់ណែនាំដល់កម្មវិធីវាយតម្លៃ៖

- ត្រូវតែដឹងថា ខ្លួនកំពុងតែធ្វើបានល្អប៉ុណ្ណា។
- សិស្សត្រូវតែដឹងថា ពួកគេកំពុងតែធ្វើបានល្អប៉ុណ្ណា។
- ការវាយតម្លៃគឺជាដំណើរការទៅវិញទៅមកមួយ ដែលរួមបញ្ចូលទាំងការវាយតម្លៃនៃការប្រព្រឹត្តរបស់គ្រូផង និងរង្វាយតម្លៃសមិទ្ធិផលរបស់សិស្សផងដែរ។
- កម្មវិធីនៃការវាយតម្លៃ អាចជួយដល់ប្រសិទ្ធភាពនៃការបង្រៀន និងចូលរួមចំណែកដល់ការរីកលូតលាស់នៃបញ្ញានិងចិត្តគំនិតរបស់សិស្សដែរ។
- ត្រូវមានភស្តុតាង និងការបញ្ចូលទិន្នន័យដើម្បីឱ្យដឹងថា តើសកម្មភាព ឬការងារដែលគ្រូ និងសិស្សកំពុងធ្វើ និងត្រូវមានទម្រង់ផ្សេងៗនៃឧបករណ៍ សម្រាប់ប្រមូលទិន្នន័យនោះមកពីប្រភពណា ហើយល្អបែបណា។
- ការវាយតម្លៃ គឺជាដំណើរការបន្តគ្នា។ ការជ្រើសរើស និងការអនុវត្តសកម្មភាពទាមទារការត្រួតពិនិត្យជាបន្តបន្ទាប់។ ការវាយតម្លៃគឺដើម្បីត្រួតពិនិត្យការរីកចម្រើន និងការផ្លាស់ប្តូរ ឬចាប់យកយុទ្ធវិធីដើម្បីជំរុញបង្កើនការអនុវត្តដែលយើងចង់បាន។
- ការឆ្លុះបញ្ចាំង និងស្វ័យវាយតម្លៃ គឺជាសមាសធាតុសំខាន់នូវរាល់ជោគជ័យនៃកម្មវិធីរង្វាយតម្លៃ។ ប្រសិនបើសិស្សចង់អភិវឌ្ឍបំណិនដែលចាំបាច់សម្រាប់ពួកគេ និងដើម្បីបង្កើនភាពជាម្ចាស់នៃការរៀនសូត្ររបស់ពួកគេឱ្យកាន់តែធំទៅទៀត នោះការឆ្លុះបញ្ចាំង និងស្វ័យវាយតម្លៃមានសារៈសំខាន់ណាស់។
- ការទទួលខុសត្រូវរបស់គ្រូបង្រៀន គឺជួយសម្រួលដល់ការរៀនរបស់សិស្ស និងដើម្បីវាយតម្លៃលើការរីកចម្រើនក្នុងការរៀននោះ ហើយភារកិច្ចនេះគ្រូបង្រៀនគួរតែទទួលខុសត្រូវ។

## ៦.៣- ភាពចាំបាច់នៃការវាយតម្លៃ

ការវាយតម្លៃជាកិច្ចការមួយចាំបាច់បំផុត ដែលគ្រូបង្រៀនត្រូវតែធ្វើ។ តាមរយៈរង្វាយតម្លៃនេះ អាចឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការសិក្សារបស់សិស្ស និងលទ្ធផលនៃការបង្រៀនរបស់គ្រូ។ ឈរលើលទ្ធផលនៃរង្វាយតម្លៃនេះ លោកគ្រូ

អ្នកគ្រូអាចកែលម្អការបង្រៀន និងរៀនឱ្យកាន់តែមានលក្ខណៈសុក្រិតថែមទៀត។ វាយតម្លៃអាចធ្វើនៅពេលកំពុងសិក្សា ឬក្រោយពេលសិក្សាខ្លឹមសារថ្មី(សមត្ថភាពថ្មី) តាមតម្រូវការនៃភាពចាំបាច់របស់គ្រូ ឬសិស្ស។ ដើម្បីឱ្យលទ្ធផលនៃការវាយតម្លៃមានប្រសិទ្ធភាព និងប្រកបដោយជោគជ័យនោះ លោកគ្រូ អ្នកគ្រូ ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវ៖

- វត្ថុបំណងនៃការវាយតម្លៃ
- សមត្ថភាព ឬបំណិនដែលត្រូវវាយតម្លៃ
- កម្រិតនៃការវាយតម្លៃ
- រូបភាពនៃការវាយតម្លៃដូចជាសំណេរ សំណួរផ្ទាល់មាត់ ឬការប្រើសម្ភារៈ ពិសោធ។ល។
- កាលបរិច្ឆេទនៃការវាយតម្លៃ
- រយៈពេលនៃការវាយតម្លៃ។

### ៦.៤- នានាភាពនៃការវាយតម្លៃ

- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាមកម្រិតថ្នាក់នីមួយៗ។
- ការវាយតម្លៃលទ្ធផលសិក្សាធៀបទៅនឹងស្តង់ដាកម្មវិធីសិក្សា។
- ការវាយតម្លៃបញ្ចប់ភូមិសិក្សាឬប្រឡងថ្នាក់ជាតិ។ល។
- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាមកម្រិតថ្នាក់នីមួយៗ ត្រូវធ្វើឡើងទៅតាមដំណាក់ដូចតទៅ៖
  - ការវាយតម្លៃជាប្រចាំ : ធ្វើឡើងក្នុងពេលកំពុងបង្រៀនមេរៀននីមួយៗ។
  - ការវាយតម្លៃតាមដំណាក់ : ធ្វើឡើងនៅពេលបញ្ចប់ដំណាក់តូចៗនៃមេរៀន បំណិន សមត្ថភាព ឬផ្នែកនីមួយៗ។
  - ការវាយតម្លៃប្រចាំខែ និងប្រចាំឆមាសៈ ធ្វើឡើងនៅពេលដំណាច់ខែ ឬបញ្ចប់ឆមាសនីមួយៗនៃឆ្នាំសិក្សា។

ចំណែកឯវិធីវាយតម្លៃ អាចធ្វើជាសំណួរផ្ទាល់មាត់ សំណេរ ឬជាការប្រតិបត្តិដូចជា ការសម្តែង ល្បែងសិក្សា ករណីសិក្សាស្រាវជ្រាវ។ល។ គ្រូនិងគណៈគ្រប់គ្រងសាលារៀនគួរតែផ្តល់ការបញ្ជាក់យ៉ាងច្បាស់លាស់ដល់សិស្ស និងមាតាបិតាឬអាណាព្យាបាលសិស្ស អំពីលទ្ធផលសិក្សាដែលសិស្សទទួលបានទៅតាមដំណាក់នីមួយៗ។ សិស្សគួរតែទទួលបានព័ត៌មាន ច្បាស់លាស់អំពីចំណុចខ្លាំង ចំណុចខ្សោយ និងជំហានដែលពួកគេត្រូវអភិវឌ្ឍបន្ត ដើម្បីបង្កើនលទ្ធផលសិក្សារបស់ពួកគេ។

### ៦.៥- ឧបករណ៍វាយតម្លៃ

តេស្ត គឺជាឧបករណ៍មូលដ្ឋានសម្រាប់ធ្វើការវាយតម្លៃសមត្ថភាពសិស្សគ្រប់ស្ថានភាព និងកាលៈទេសៈ។ ក្នុងការវាយតម្លៃលោកគ្រូ អ្នកគ្រូអាចប្រើប្រភេទតេស្តផ្សេងៗដូចជា៖

**៦.៥.១- បុរេតេស្តៈ** តេស្តនេះ ជាតេស្តដំបូងសម្រាប់ស្ទាបស្ទង់សមត្ថភាពសិស្ស មុនពេលចាប់ផ្តើមមេរៀនថ្មី ឬប្រធានបទអ្វីមួយ។

**៦.៥.២- តេស្តបុរេពុទ្ធិ** : តេស្តនេះ ជាតេស្តធ្វើនៅក្នុងជំហានទី២ និងទៅតាមដំណាក់នៅក្នុងជំហានទី៣ មុនពេលផ្តល់សមត្ថភាព ឬបំណិនថ្មី ដើម្បីស្ទាបស្ទង់សមត្ថភាពចាំបាច់ ដែលទាក់ទងនឹងសមត្ថភាព ឬបំណិនថ្មីនីមួយៗ ដែល ត្រូវលើកមកបង្រៀន។

**៦.៥.៣- តេស្តតាមដំណាក់** : ការវាយតម្លៃតាមដំណាក់មានគោលបំណង៖

- វិនិច្ឆ័យលើតម្រូវការរបស់សិស្ស
- រៀបចំផែនការដើម្បីជួយសិស្ស
- វាយតម្លៃលើវិធីសាស្ត្របង្រៀនផ្ទាល់ខ្លួនរបស់គ្រូ។

សម្រាប់គ្រូបង្រៀន ការវាយតម្លៃតាមដំណាក់ជាផ្នែកមួយនេះ៖

- ការតាមដានការងារ និងការរីកចម្រើនរបស់សិស្សតាមមធ្យោបាយផ្លូវការ និងមិនផ្លូវការ។
- ការផ្តល់អនុសាសន៍ និងព័ត៌មានត្រឡប់សម្រាប់សកម្មភាពផ្សេងៗប្រសើរជាងការដាក់ពិន្ទុ ឬនិទ្ទេសលើតេស្ត។
- ការវាយតម្លៃតាមដំណាក់ជាផ្នែកនៃដំណើរការបង្រៀន និងរៀនពីមួយថ្ងៃទៅមួយថ្ងៃ។
- គ្រូបង្រៀន ត្រូវតែបញ្ចូលសកម្មភាពវាយតម្លៃទៅក្នុងកិច្ចតែងការបង្រៀន។

តេស្តតាមដំណាក់ ជាប្រភេទតេស្តដ៏សំខាន់មួយ។ គេច្រើនធ្វើតេស្តនេះ នៅជំហានទី៣ ឬជំហានទី៤ ក្រោយពេលផ្តល់សមត្ថភាពថ្មីរួចហើយ។ តេស្តតាមដំណាក់ក៏អាចចាត់ទុកជា«ការវាយតម្លៃជាផ្លូវការ» បានដែរ។ ការវាយតម្លៃនេះ ជាគោលការណ៍ដែលគ្រូបង្រៀនត្រូវធ្វើជាបន្តបន្ទាប់នៅក្នុងដំណើរការសិក្សារបស់សិស្សសំដៅកែលម្អ និងពង្រឹងគុណភាពនៃការសិក្សារបស់គេឱ្យទាន់ពេលវេលា។ ផលប្រយោជន៍នៃការវាយតម្លៃតាមដំណាក់ ធ្វើឱ្យគ្រូបង្រៀនក្តាប់បានជាក់លាក់អំពីការរីកចម្រើនរបស់សិស្សម្នាក់ៗ។ ពេលដែលគ្រូបង្រៀនអនុវត្តការវាយតម្លៃតាមដំណាក់ នោះគាត់គួរឱ្យតម្លៃលើសមត្ថភាពពិតប្រាកដរបស់សិស្សច្រើនជាងការផ្តល់ពិន្ទុលើចម្លើយតេស្ត។ នៅក្នុងការវាយតម្លៃតាមដំណាក់ គ្រូបង្រៀនមិនត្រឹមតែដាក់ពិន្ទុប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្តល់ការណែនាំផងដែរ ដើម្បីឱ្យដំណើរការវាយតម្លៃលើការរីកចម្រើនរបស់សិស្សមានសុពលភាពត្រឹមត្រូវ។ ការណែនាំនោះត្រូវបាន កត់ត្រា និងរាយការណ៍ទៅដល់សិស្ស និងឪពុកម្តាយរបស់គេ។ ប្រភេទនៃការវាយតម្លៃបែបនេះគឺជា«ការវាយតម្លៃមិនផ្លូវការ»។ ការវាយតម្លៃមិនផ្លូវការ គឺមានតួនាទីសំខាន់ណាស់សម្រាប់ជួយសិស្ស ដោយផ្សារភ្ជាប់ការអប់រំក្នុងសាលារៀនជាមួយការអប់រំក្នុងគ្រួសារ។

**ឧទាហរណ៍ការវាយតម្លៃតាមដំណាក់បែបមិនផ្លូវការ គេធ្វើឡើងតាមរយៈ៖**

- ការសង្កេតក្នុងពេលរៀន និងបង្រៀន
- ការសង្កេតក្នុងពេលធ្វើកិច្ចការក្រុម
- ការសង្កេតអ្នកដឹកនាំនៅក្នុងក្រុមពិក្សារបស់សិស្ស
- ការរក្សាទុកបញ្ជីឈ្មោះសិស្សដែលធ្វើកិច្ចការមិនទាន់ចប់
- ការកត់សម្គាល់ឱ្យដឹងអ្នកមិនបានបំពេញកិច្ចការក្រុម
- ការកត់សម្គាល់អ្នកដែលត្រូវការជំនួយបន្ថែម
- ការកត់សម្គាល់អ្នកដែលមិនបានចូលរួមសកម្មភាពពិភាក្សា
- ការស្តាប់ និងកត់ត្រានូវអ្វីដែលអ្នកដទៃនិយាយប្រាប់អំពីសិស្ស(នាយកសាលារៀន ឪពុកម្តាយ និងបងប្អូន)។

លោកគ្រូ អ្នកគ្រូកត់សម្គាល់ចំណុចទាំងនេះគ្រប់ពេល ប៉ុន្តែចំណុចទាំងនេះកន្លងមកមិនត្រូវបានគេយកមកប្រើក្នុការវាយតម្លៃមិនផ្លូវការ និងចុះបញ្ជីក្នុងនោះឡើយ។ គ្រូបង្រៀនត្រូវហ្វឹកហាត់បំណិនសង្កេត និងរកមធ្យោបាយបញ្ជូនយោបល់ មិនផ្លូវការទាំងនោះទៅក្នុងការវាយតម្លៃសរុបរបស់សិស្ស។ គណៈគ្រប់គ្រងអាចជួយដល់ដំណើរការនេះក្នុងការវាយតម្លៃមិនផ្លូវការ។

**៦.៥.៤- តេស្តបញ្ចប់:** តេស្តនេះ ធ្វើនៅពេលបញ្ចប់ខ្លឹមសារមួយ មេរៀន ជំពូក ប្រធានបទ ប្រចាំខែ ប្រចាំឆមាសប្រចាំឆ្នាំ។ល។ ដើម្បីស្ទាបស្ទង់សមត្ថភាពដែលសិស្សទទួលបានក្រោយពេលរៀនចប់។

## ៦.៦- យុទ្ធវិធីក្នុងការវាយតម្លៃ

មធ្យោបាយប្លែកៗគ្នាជាច្រើនដែលគ្រូមាន និងធ្វើដើម្បីធ្វើការវាយតម្លៃលើការរីកចម្រើនរបស់សិស្ស។ គ្រូអាចប្រើយុទ្ធវិធីផ្សេងៗ ដើម្បីធ្វើការវាយតម្លៃសិស្សដោយសារសិស្សរៀនតាមរបៀបផ្សេងៗ និងមានបំណិនខុសគ្នាជាច្រើន។ នៅពេលសិស្សបង្ហាញនូវអ្វីដែលគេបានរៀន ឬបំណិនដែលពួកគេមាននោះពួកគេគួរតែត្រូវបានអនុញ្ញាតឱ្យបង្ហាញតាម

របៀបផ្សេងៗ។ ប្រភេទនៃការវាយតម្លៃដែលគ្រូ យកមកប្រើប្រាស់គួរតែផ្សារភ្ជាប់ទៅនឹងបំណិន ឬបទពិសោធដែលបានបង្រៀន។

**៦.៦.១- តេស្តរៀបចំឡើងដោយគ្រូបង្រៀនៈ** តេស្តរៀបចំឡើងដោយគ្រូ គឺជាតេស្តខ្លីៗមានប្រយោជន៍ពិនិត្យមើលថា តើសិស្សសម្រេចបានវត្ថុបំណងមេរៀនថ្មីដែរឬទេ។ ដូច្នេះគប្បីប្រើប្រាស់តេស្ត ដើម្បីជួយដល់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ព្រោះវាមានប្រយោជន៍ណាស់នៅពេលគ្រូបង្រៀនផ្តល់ព័ត៌មានត្រឡប់បន្ទាប់ពីតេស្តនីមួយៗ ដើម្បីពិភាក្សាលើបញ្ហាសិក្សារបស់សិស្ស។ គ្រូបង្រៀនគប្បីលើកទឹកចិត្តសិស្សឱ្យកែកំហុសរបស់ខ្លួនដោយខ្លួនគេផ្ទាល់ដោយមាន ឬគ្មានជំនួយពីគ្រូ ឬមិត្តភក្តិ។ ការរៀបចំតេស្តមានដូចជាៈ

- ការប្រើប្រាស់សម្ភារៈ : ដើម្បីឱ្យសិស្សសង្កេត ពិសោធ រួចឱ្យគេឆ្លើយប្រាប់នូវអ្វីដែលយើងចង់បានហើយពាក់ព័ន្ធនឹងខ្លឹមសារមេរៀន។
- ការប្រើប្រាស់សំណួរផ្ទាល់មាត់ : ឱ្យសិស្សឆ្លើយនឹងសំណួរភ្លាមៗ ដើម្បីបញ្ជាក់សមត្ថភាពពិតប្រាកដរបស់ពួកគេ។
- ការប្រើសំណួរសរសេរ : ឱ្យសិស្សឆ្លើយនឹងកម្រងសំណួរ ឬឱ្យសិស្សធ្វើកិច្ចការតាមប្រភេទសំណួរផ្សេងៗ។ សំណួរទាំងនោះមានដូចជាសំណួរបើក សំណួរបិទ សំណួរឆ្លាស់ សំណួរផ្គូផ្គង សំណួរពហុជ្រើសរើស សំណួរបែបធ្វើបញ្ជី។

**៦.៦.២- ការវាយតម្លៃមិនផ្លូវការលើសកម្មភាពរបស់សិស្សៈ** ការសង្កេត គឺជាបច្ចេកទេសសាមញ្ញដែលគេប្រើសម្រាប់វាយតម្លៃ សកម្មភាពប្រចាំថ្ងៃនៅក្នុងថ្នាក់រៀន។ គ្រូបង្រៀនសង្កេតជាបន្តបន្ទាប់លើ អាកប្បកិរិយា ឥរិយាបថ និងការសិក្សារបស់សិស្ស ហើយវិនិច្ឆ័យតាមការសង្កេតទាំងនោះ។ ការសង្កេតទាក់ទងទៅនឹងៈ

- ទិដ្ឋភាពមួយចំនួននៃការអភិវឌ្ឍរាងកាយរបស់សិស្ស
- ចំណាប់អារម្មណ៍ក្នុងការសិក្សា និងទម្លាប់សិក្សារបស់សិស្ស
- លទ្ធភាពដែលសិស្សអាចធ្វើបាន បន្ទាប់ពីការណែនាំរបស់គ្រូ
- លទ្ធភាពចូលរួមក្នុងសកម្មភាពរបស់សាលារៀន
- ទំនាក់ទំនងជាមួយសិស្សដទៃក្នុងថ្នាក់។

***កំណត់សម្គាល់ :*** ចំពោះអនុសាសន៍ទាំងនេះ ត្រូវធ្វើតាមមធ្យោបាយដូចខាងក្រោមៈ

- ប្រើប្រាស់សៀវភៅលំហាត់ រួមជាមួយនឹងសន្លឹកកិច្ចការដែលបានផ្តល់ឱ្យសិស្សម្នាក់ៗ
- បញ្ជីឈ្មោះសិស្សត្រូវទុកចន្លោះសម្រាប់កត់ត្រាសកម្មភាពរបស់សិស្សម្នាក់ៗ
- គ្រូព្យាយាមធ្វើដូចនេះ ឱ្យបានរយៈពេលមួយខែ។

**៦.៦.៣- កិច្ចការផ្ទះ** កិច្ចការផ្ទះមានប្រយោជន៍សម្រាប់បំណិនចាត់ចែងការងាររបស់សិស្ស និងជួយពួកគេឱ្យរៀនពីរបៀបធ្វើកិច្ចការជាក់ស្តែងឱ្យបានជោគជ័យ។ វាផ្តល់នូវព័ត៌មានអំពីការលំបាក ឬបញ្ហាដែលសិស្សជួបប្រទះពេលធ្វើការងារផ្ទាល់ខ្លួន។

**៦.៦.៤- ស្វ័យវាយតម្លៃ**ៈ សិស្សត្រូវរៀនពីរបៀបវាយតម្លៃកិច្ចការផ្ទាល់ខ្លួន នេះគេហៅថាស្វ័យវាយតម្លៃ។ ស្វ័យវាយតម្លៃលើកទឹកចិត្តសិស្ស ឱ្យកាន់តែមានភាពទទួលខុសត្រូវចំពោះកិច្ចការរបស់គេ។

**៦.៦.៥- ការវាយតម្លៃជាដៃគូៈ** ពេលខ្លះ គ្រូប្រើការវាយតម្លៃដៃគូក្នុងថ្នាក់របស់គាត់។ នេះគឺជាពេលសិស្សវាយតម្លៃការងារគ្នាទៅវិញទៅមក។ សិស្សត្រូវរៀនពីបំណិនស្តីពី របៀបធ្វើការវាយតម្លៃដៃគូឱ្យបានសមស្រប។

**៦.៦.៦- ការវាយតម្លៃពេលធ្វើការងារក្រុម**ៈ គោលវិធីសិស្សមជ្ឈមណ្ឌល ជំរុញគ្រូឱ្យប្រើប្រាស់ការងារក្រុមជាច្រើន។ ការអនុវត្តការងារក្រុម សិស្សនឹងអភិវឌ្ឍបំណិនសង្គមរបស់ពួកគេ និងសិក្សាពីរបៀបធ្វើការងារជាមួយគ្នា។ វាជារឿងសំខាន់ក្នុងការវាយតម្លៃសិស្ស អំពីរបៀបធ្វើការជាមួយគ្នា។ គ្រូសង្កេតសិស្សដើម្បីឱ្យដឹងថា តើ

សមាជិកក្រុមនីមួយៗទទួលបានឱកាសពិភាក្សា និងវិធីដែលសិស្សត្រូវដោះស្រាយបញ្ហាដែរ ឬទេ?

**គ្រូត្រូវសួរខ្លួនឯងនូវសំណួរដូចជា៖**

- តើសិស្សទាំងអស់មានឱកាសចូលរួមដែរ ឬទេ?
- តើសិស្សពេញចិត្តនឹងធ្វើការងារក្រុមដែរ ឬទេ?
- តើមានហេតុផលអ្វីខ្លះចំពោះការងារនេះ?
- តើកិច្ចការនេះមានភាពច្បាស់លាស់ដែរ ឬទេ?
- តើពិតជាកិច្ចការបែបសហការមែន ឬទេ?

**៦.៦.៧- តេស្តតាមកម្មវិធីថ្នាក់ជាតិ៖** តេស្តកម្មវិធីថ្នាក់ជាតិធ្វើឡើងដោយក្រសួងដើម្បីត្រួតពិនិត្យថា លទ្ធផលសិក្សារបស់សិស្សអាចសម្រេចតាម ស្តង់ដាកម្មវិធីសិក្សាថ្នាក់ជាតិដែរ ឬទេ។

**៦.៦.៨- ការចូលរួមរបស់មាតាបិតាក្នុងការវាយតម្លៃ៖** មាតាបិតា ឬអាណាព្យាបាលគួរតែទទួល និងចុះហត្ថលេខាលើរបាយការណ៍រីកចម្រើនរបស់កូនជារៀងរាល់ខែ។ មាតាបិតាឬអាណាព្យាបាលគប្បីចូលរួមឱ្យបានច្រើន ក្នុងការវាយតម្លៃការអប់រំកូនរបស់ខ្លួន។ សាលារៀនត្រូវមានដំណើរការប្រជុំជាមួយមាតាបិតាឬអ្នកអាណាព្យាបាលសិស្សឱ្យបានទៀងទាត់។ នៅក្នុងពេលប្រជុំគ្រូត្រូវរៀបរាប់អំពី ដំណើរការរីកចម្រើនរបស់សិស្ស និងបញ្ហារបស់សិស្ស។

***កំណត់សម្គាល់៖***

- រង្វាយតម្លៃអាចធ្វើតាមរូបភាពណាក៏បាន ឱ្យតែឆ្លុះបញ្ចាំងសមត្ថភាពសិស្សបានត្រឹមត្រូវ។
- រង្វាយតម្លៃសមត្ថភាពថ្មីត្រូវធ្វើយ៉ាងណា ឱ្យឆ្លើយតបទៅនឹងវត្ថុបំណងនៃមេរៀន ជាពិសេស ត្រូវសង្កត់ធ្ងន់ទៅលើលក្ខខណ្ឌ និងសមត្ថភាព ឬបំណិនដែលបានកំណត់។
- លោកគ្រូ អ្នកគ្រូ អាចប្រើប្រាស់ប្រភេទសំណួរណាក៏បាន ឱ្យតែសំណួរនោះស្របនឹងសមត្ថភាព របស់សិស្ស។

**គ្មានការវាយតម្លៃគឺមិនអាចដឹងបានច្បាស់ពីសមត្ថភាពសិស្សនិងមិនអាចដឹងពីការរីកចម្រើននៃការបង្រៀនរបស់គ្រូ។**

## ៦.៧- កំណត់ត្រា និងការដាក់ពិន្ទុ

**៦.៧.១- ការរក្សាទុកកំណត់ត្រារីកចម្រើនរបស់សិស្សបានល្អមានមុខងារសំខាន់បីដើម្បី៖**

- ផ្តល់ព័ត៌មានត្រឡប់ឬការកែលម្អសិស្ស។
- រាយការណ៍ដល់នាយក គ្រូ សិស្ស មាតាបិតាឬអាណាព្យាបាលសិស្ស។ល។
- ធ្វើសកម្មភាពបង្រៀន និងរៀនសម្រាប់ថ្ងៃមុខឱ្យស្របទៅនឹងកម្រិតនៃការយល់ដឹង និងការរីកចម្រើនរបស់សិស្ស។ ម្យ៉ាងទៀតកំណត់ត្រាបែបនេះ ផ្តល់នូវព័ត៌មានដែលមានប្រយោជន៍ទៅឱ្យសាលារៀនអំពីប្រសិទ្ធភាពនៃសកម្មភាពបង្រៀននិងរៀន និងការសម្រេចបានតាមកម្មវិធីសិក្សា។ សាលារៀនភាគច្រើនកត់ត្រាការវាយតម្លៃសិស្ស តែលើការដាក់ពិន្ទុជាលេខប៉ុណ្ណោះ។ ពិន្ទុជាច្រើន ត្រូវបានគេប្រមូលនៅក្នុងអំឡុងពេលមួយ ដើម្បីរកមធ្យមភាគដែលត្រូវចុះក្នុងរបាយកាណ៍របស់សាលារៀន។ ពិន្ទុគ្រាន់តែជាផ្នែកតូចមួយនៃព័ត៌មាន ដែលបង្ហាញពីសកម្មភាព ការប្រឹងប្រែង ការរីកចម្រើន និងលទ្ធផលដែលសម្រេចបានប៉ុណ្ណោះ។ ការផ្តល់ព័ត៌មានលើការប្រឹងប្រែង និងការរីកចម្រើនរបស់សិស្សតាមរយៈមូលវិចាររួមជាមួយពិន្ទុមានប្រយោជន៍ណាស់។ មូលវិចារត្រូវធ្វើជាផ្លូវការ និងចាំបាច់ត្រូវបង្ហាញពីអ្វីដែលគួរធ្វើដើម្បីអភិវឌ្ឍដំណើរការសិក្សា។ ការដាក់ពិន្ទុ និងកំណត់ត្រាទាមទារឱ្យគ្រូប្រើពេលវេលាច្រើនក្នុងការពិចារណា។

### ៦.៧.២- យោបល់ខ្លះសម្រាប់ជាជំនួយដល់ការគ្រប់គ្រងកំណត់ត្រា និងការដាក់ពិន្ទុឱ្យមានប្រសិទ្ធភាព៖

- គ្រូត្រូវកំណត់យកសិស្សមួយក្រុមម្តងៗមកត្រួតពិនិត្យ និងធ្វើកំណត់ត្រារៀងរាល់សប្តាហ៍ ព្រោះគ្រូមិនមានលទ្ធភាពសង្កេតសិស្សទាំងអស់ក្នុងពេលតែមួយបានទេ។តែគ្រូគប្បីសង្កេតសិស្សទាំង អស់ក្នុងរយៈពេលមួយខែ។
- រៀបចំសំណួរតេស្តប្រឡងមួយ សម្រាប់ធ្វើប្រចាំខែតាមថ្នាក់នីមួយៗ។ គ្រូត្រូវកំណត់វត្ថុបំណងឱ្យច្បាស់ អាចមានចម្លើយគំរូ និងលំនាំនៃការដាក់ពិន្ទុ។ លំនាំនៃការដាក់ពិន្ទុត្រូវធានាថា ឆ្លើយតបនឹងគុណភាព និងប្រសិទ្ធភាព។
- ការដាក់ពិន្ទុ និងការកត់ត្រាជាផ្នែកមួយនៃកិច្ចការប្រចាំថ្ងៃរបស់គ្រូ។

### ៦.៧.៣- យុទ្ធវិធីសំខាន់ពីរសម្រាប់ការដាក់ពិន្ទុ និងមូលវិចារ

គ្រូត្រូវលើកទឹកចិត្តសិស្សឱ្យប្រើវិធីទាំងពីរនេះ គឺសៀវភៅកំណត់ត្រារបស់គ្រូ ឬសៀវភៅតាមដាន និងសំណុំកិច្ចការសិស្ស។

**ក- សៀវភៅតាមដាន**

គ្រូភាគច្រើនបានប្រើប្រាស់សៀវភៅតាមដានសម្រាប់ការដាក់ពិន្ទុ និងមូលវិចារដែលគាត់ផ្តល់ឱ្យសិស្ស។ នៅដំណាច់ឆមាស គ្រូសរុបមធ្យមភាគមុខវិជ្ជាទាំងអស់សម្រាប់សិស្សម្នាក់ៗ។

សៀវភៅតាមដានអាចរៀបចំតាមវិធីដូចខាងក្រោម៖

- បញ្ជីប្រចាំថ្នាក់ គួរមានចន្លោះតូចៗសម្រាប់សរសេរមូលវិចារសិស្សម្នាក់ៗ
- ប្រើក្រដាសមួយទំព័រសម្រាប់សិស្ស១០នាក់
- ប្រើក្រដាសមួយទំព័រ ឬសាលាកប័ត្រមួយសម្រាប់សិស្ស១នាក់។

**ខ- សំណុំកិច្ចការសិស្ស**

គ្រូអាចប្រើសំណុំកិច្ចការសិស្ស ដើម្បីបង្ហាញភស្តុតាងនៃលទ្ធផល និងភាពរីកចម្រើនរបស់សិស្ស។ សំណុំកិច្ចការ គឺជាការប្រមូលកិច្ចការរបស់សិស្សដែលបានធ្វើក្នុងរយៈពេលមួយឆ្នាំសិក្សា។

**ខ.១- សំណុំកិច្ចការសិស្សបង្ហាញពីសមត្ថភាពសិស្សលើកិច្ចការជាច្រើនមានដូចជា៖**

- គំរូកិច្ចការ និងរបាយការណ៍វាយតម្លៃ
- បង្ហាញកិច្ចការរបស់សិស្សតាមមុខវិជ្ជានីមួយៗ
- ការងារបុគ្គល ឬ បទបង្ហាញរបស់ក្រុម
- ឯកសារ ស្នាដៃ ...។

**ខ.២- សំណុំកិច្ចការសិស្ស**

សំណុំកិច្ចការសិស្សមានច្រើនដូចជា កិច្ចការផ្ទះ លទ្ធផលតេស្ត របាយការណ៍ ស្នាដៃ តែងនិពន្ធ បទបង្ហាញជាបុគ្គល និងជាក្រុម គម្រោង តារាងវាយតម្លៃខ្លួនឯង ភស្តុតាងបំណិនសង្គមផ្ទាំងរូបភាព។ សិស្សអាចសម្រេចចិត្តថាតើការងារអ្វីខ្លះដែលគេចូលចិត្តធ្វើជាងគេក្នុងចំណោមសំណុំកិច្ចការរបស់គេ។ គ្រូអាចជួយសិស្សជ្រើសរើសកិច្ចការណាដែលត្រូវដាក់ចូលទៅក្នុងសំណុំកិច្ចការរបស់គេ។

## ៦.៨- របាយការណ៍

វាជាតម្រូវការមួយដែលគ្រូចាំបាច់ត្រូវរាយការណ៍ អំពីស្នាដៃសិស្សរបស់គាត់ឱ្យបានទៀងទាត់ដោយប្រើប្រាស់សន្លឹករបាយការណ៍របស់សាលារៀន។ សន្លឹករបាយការណ៍រួមមានឈ្មោះសិស្ស ថ្នាក់ និងពិន្ទុមូលវិចារបញ្ចប់របស់មុខវិជ្ជានីមួយៗ។ របាយការណ៍របស់សាលារៀនស្របគ្នានឹងលំណែនាំថ្នាក់ជាតិដោយទាក់ទងនឹងខ្លឹមសារ និងទម្រង់គំរូ។ របាយការណ៍មានគោលបំណងសំខាន់ៗដើម្បី៖

- ផ្ដល់ព័ត៌មានឱ្យសិស្សអំពីលទ្ធផល និងការរីកចម្រើនរបស់គេ
- ធ្វើឱ្យនាយកសាលារៀនអាចតាមដានដំណើរការសិក្សារបស់សិស្សទាំងអស់នៅក្នុងសាលារៀន
- ធ្វើឱ្យមាតាបិតាឬអាណាព្យាបាលបានដឹងពីសកម្មភាពរបស់កូនដែលកំពុងរៀននៅក្នុងសាលា។

របាយការណ៍ គឺជាមធ្យោបាយទំនាក់ទំនងតែមួយគត់រវាងសាលារៀនជាមួយមាតាបិតា ឬអាណាព្យាបាលសិស្ស។

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១(៤៥៤ ម៉ោង)

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| | **សមត្ថភាពស្ដាប់** | |
| បង្ហាញពីឥរិយាបថវិជ្ជមានក្នុងការស្ដាប់ប្រកបដោយប្រសិទ្ធភាព យល់ដឹងពីរបៀបស្ដាប់ ដើម្បីកំណត់បានស្រៈ ព្យញ្ជនៈ ព្យាង្គ និងកំណត់បានអត្ថន័យនៃពាក្យ កន្សោមពាក្យ ឃ្លា ល្បះ កថាខណ្ឌ អត្ថបទ និងរបៀបរកព័ត៌មានសំខាន់ៗ ដើម្បីឆ្លើយនឹងសំណួរទាក់ទងនឹងការស្ដាប់ | | |
| ១- ការកត់សម្គាល់អត្ថន័យនៃពាក្យដែលបានស្ដាប់ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីន័យនៃពាក្យដែលបានឮ<br>**បំណិនសម្បទា**<br>- បង្ហាញការយល់ដឹងអំពីន័យនៃពាក្យដែលបានស្ដាប់ តាមរយៈការប្រើពាក្យនោះនៅក្នុងល្បះ<br>**ចរិយាសម្បទា**<br>- មានទម្លាប់ចង់ដឹងន័យរបស់ពាក្យថ្មីៗ | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានន័យនៃពាក្យងាយៗដែលបានឮ<br>**បំណិនសម្បទា**<br>- ពន្យល់ន័យនៃពាក្យងាយៗដែលបានស្ដាប់<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការពន្យល់ន័យនៃពាក្យងាយៗដែលបានស្ដាប់ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានថានៅពេលដែលយើងមិនយល់ន័យនៃពាក្យណាមួយយើងអាចមើលរូបភាពដែលនៅជិតៗនោះ<br>**បំណិនសម្បទា**<br>- ប្រើប្រាស់រូបភាពជាបរិបទបញ្ជាក់ ដើម្បីយល់ន័យនៃពាក្យដែលបានស្ដាប់<br>**ចរិយាសម្បទា**<br>- មានទម្លាប់ប្រើវិធីផ្សេងៗ ដើម្បីយល់ន័យរបស់ពាក្យ | |
| ២- ការស្ដាប់ការណែនាំ | **វិជ្ជាសម្បទា**<br>- ប្រាប់បានអំពីន័យរបស់ការណែនាំ។ | |

| | | |
|---|---|---|
| | **បំណិនសម្បទា**<br>- ធ្វើតាមការណែនាំផ្ទាល់មាត់បីដំណាក់<br>**ចរិយាសម្បទា**<br>- មានឥរិយាបថល្អ និងប្រុងប្រយ័ត្នក្នុងការស្តាប់ការណែនាំ | |
| ៣- ការស្តាប់អត្ថបទពណ៌នា រឿងនិទាន កំណាព្យ និងចម្រៀងខ្លីៗ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបទស្សន៍ទាយ មុននឹងស្តាប់រឿងនិទាន<br>ឧ. មើលរូបភាព និងចំណងជើងរឿង<br>**បំណិនសម្បទា**<br>- ធ្វើការទស្សន៍ទាយ មុននឹងស្តាប់រឿងនិទានខ្លីៗ<br>**ចរិយាសម្បទា**<br>- មានគំនិតច្នៃប្រឌិតក្នុងការទស្សន៍ទាយ មុននឹងស្តាប់រឿងនិទាន | |
| | **វិជ្ជាសម្បទា**<br>- កត់ចំណាំបានដំណើររឿងជាបន្តបន្ទាប់ នៅពេលស្តាប់ មុននឹងទស្សន៍ទាយអ្វីដែលនឹងកើតឡើងបន្ទាប់<br>**បំណិនសម្បទា**<br>- ធ្វើការទស្សន៍ទាយអំពីអ្វី ដែលនឹងកើតឡើងបន្ទាប់ អំឡុងពេលកំពុងស្តាប់រឿងនិទាន<br>**ចរិយាសម្បទា**<br>- មានគំនិតច្នៃប្រឌិតក្នុងការទស្សន៍ទាយអំពីអ្វី ដែលនឹងកើតឡើងបន្ទាប់ អំឡុងពេលកំពុងស្តាប់រឿងនិទាន | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានពីខ្លឹមសារអត្ថបទនិងប្រាប់បានរបៀបរកព័ត៌មានដើម្បីឆ្លើយនឹងសំណួរ<br>**បំណិនសម្បទា**<br>- បង្ហាញសមត្ថភាពចងចាំនិងយល់ន័យអត្ថបទ ដោយឆ្លើយទៅនឹងសំណួរ អ្វី នរណា ឯណា ពេលណា ដូចម្តេច ហេតុអ្វី<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តនិងគំនិតច្នៃប្រឌិតក្នុងការឆ្លើយនឹងសំណួរ | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានពីដំណើររឿង និងប្រាប់ពីរបៀបរៀបព្រឹត្តិការណ៍រឿងតាមលំដាប់<br>**បំណិនសម្បទា**<br>- រៀបព្រឹត្តិការណ៍រឿងតាមលំដាប់ ដោយប្រើរូបភាព<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការរៀបព្រឹត្តិការណ៍រឿងតាមលំដាប់ | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានដំណើររឿងនិងរបៀបនិទានរឿងឡើងវិញ | |

| | | |
|---|---|---|
| | **បំណិនសម្បទា**<br>- និទានរឿងខ្លីៗឡើងវិញ ដោយប្រើពាក្យផ្ទាល់ខ្លួន<br>**ចរិយាសម្បទា**<br>- មានភាពក្លាហាននិងគំនិតច្នៃប្រឌិត ក្នុងការនិទានរឿងឡើងវិញ | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានពីចរិតលក្ខណៈរបស់តួអង្គនិងខ្លឹមសាររឿង<br>**បំណិនសម្បទា**<br>- បង្ហាញអារម្មណ៍ផ្ទាល់ខ្លួនចំពោះតួអង្គ និងខ្លឹមសាររឿង<br>**ចរិយាសម្បទា**<br>- មានគំនិតច្នៃប្រឌិត ក្នុងការសម្ដែងអារម្មណ៍ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ប្រធានបទគឺជាគំនិតធំដែលគ្របដណ្ដប់ខ្លឹមសារអត្ថបទ<br>**បំណិនសម្បទា**<br>- ប្រាប់អំពីប្រធានបទនៃអត្ថបទពណ៌នា រឿងនិទាន កំណាព្យនិងចម្រៀង<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការប្រាប់ប្រធានបទនៃអត្ថបទ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់ចរិតលក្ខណៈរបស់តួអង្គនីមួយៗ នៅក្នុងរឿង<br>**បំណិនសម្បទា**<br>- វិភាគរឿង<br>ឧ. កត់សម្គាល់ភាពដូចគ្នា និងភាពខុសគ្នានៃតួអង្គ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការវិភាគរឿងដែលបានស្ដាប់ | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានពាក្យគន្លឹះ ឃ្លា ឬល្បះដែលប្រាប់ហេតុ និងឃ្លា ឬ ល្បះ ដែលប្រាប់ផល<br>**បំណិនសម្បទា**<br>- ប្រាប់ទំនាក់ទំនងរវាងហេតុនិងផលនៅក្នុងរឿងនិទាន<br>**ចរិយាសម្បទា**<br>- ចូលចិត្តវិភាគរកហេតុនិងផលនៅក្នុងរឿងនិទាន | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ដំបូន្មានរឿង គឺជាអ្វីដែលអ្នកនិពន្ធចង់អប់រំយើង<br>**បំណិនសម្បទា**<br>- បង្ហាញដំបូន្មានរបស់រឿងនិទានខ្លីៗ<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍខ្លួនបានសមស្របតាមដំបូន្មានរបស់រឿង | |

| | | |
|---|---|---|
| | **វិជ្ជាសម្បទា**<br>- កំណត់បានអត្ថន័យនៃរឿងទាំងមូលដែលបានស្តាប់<br>**បំណិនសម្បទា**<br>- បង្កើតគំនិតថ្មី ដើម្បីបញ្ចប់រឿងនិទានខ្លីៗដែលបានស្តាប់<br>**ចរិយាសម្បទា**<br>- មានគំនិតច្នៃប្រឌិត ក្នុងការបញ្ចប់រឿងដែលបានស្តាប់ ទៅតាមចំណង់ចំណូលចិត្តនិងការស្រមើស្រមៃរបស់ខ្លួន | |
| **សមត្ថភាពនិយាយ** | | |
| បង្ហាញឥរិយាបថក្នុងការនិយាយប្រកបដោយប្រសិទ្ធភាព យល់ដឹងពីរបៀបនិយាយ ដោយចេះលើកដាក់សំឡេង សម្តែងកាយវិការ និងទឹកមុខបានសមស្របទៅតាមប្រធានបទនីមួយៗ | | |
| ១- ការប្រើសុជីវធម៌សង្គម និង គារវកិច្ច | **វិជ្ជាសម្បទា**<br>- កំណត់បានសំនួនគួរសម សម្រាប់ប្រើ ស្របតាមវ័យ និងស្ថានភាព<br>**បំណិនសម្បទា**<br>- ប្រើសុជីវធម៌ នៅក្នុងការជួបគ្នា ការលាគ្នា ដោយគោរពគ្នាទៅវិញទៅមកនៅក្នុងគ្រួសារ និងសាលារៀន<br>**ចរិយាសម្បទា**<br>- មានឥរិយាបថល្អ ក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់កាលៈទេសៈ ដែលត្រូវប្រើពាក្យអរគុណ<br>**បំណិនសម្បទា**<br>- ប្រើពាក្យអរគុណជាមួយអ្នកដទៃ ដូចជាមិត្តភក្តិ គ្រួសារ និងគ្រូបង្រៀន<br>**ចរិយាសម្បទា**<br>- មានទម្លាប់ប្រើពាក្យអរគុណជាមួយអ្នកដែលបានជួយ ឬឱ្យអ្វីមួយដល់ខ្លួន | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់កាលៈទេសៈ ដែលត្រូវនិយាយពាក្យសូមអភ័យទោស<br>**បំណិនសម្បទា**<br>- និយាយសូមអភ័យទោសពីអ្នកដទៃ ដូចជាមិត្តភក្តិ គ្រួសារនិងគ្រូបង្រៀន<br>**ចរិយាសម្បទា**<br>- មានទម្លាប់និយាយសូមអភ័យទោសនៅពេលដែលខ្លួនធ្វើអ្វីមួយខុស ឬមិនគប្បីចំពោះអ្នកណាម្នាក់ | |
| ២- ការណែនាំនិង ផ្តល់ព័ត៌មាន ផ្ទាល់ខ្លួន និង អ្នកដទៃ | **វិជ្ជាសម្បទា**<br>- ប្រាប់សំនួនគួរសមនិងបែបបទនៃការនិយាយណែនាំខ្លួនឯងឱ្យអ្នកដទៃស្គាល់<br>**បំណិនសម្បទា**<br>- ណែនាំខ្លួនឯង | |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- មានទម្លាប់ណែនាំខ្លួន ដោយប្រើពាក្យនិងកាយវិការបានសមរម្យ នៅពេលជួបប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ | |
| | **វិជ្ជាសម្បទា**<br>- និយាយប្រាប់ឈ្មោះ អាយុ អាសយដ្ឋានបានរហ័សនិងច្បាស់លាស់ដោយកាយវិការសមរម្យ<br>**បំណិនសម្បទា**<br>- ផ្តល់ព័ត៌មានអំពីឈ្មោះ អាយុ អាសយដ្ឋានរបស់ខ្លួន<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការផ្តល់ព័ត៌មានផ្ទាល់ខ្លួន | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់សំនួនគួរសម និងបែបបទនៃការនិយាយណែនាំមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត<br>**បំណិនសម្បទា**<br>- ណែនាំមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត<br>**ចរិយាសម្បទា**<br>- មានឥរិយាបថល្អក្នុងការណែនាំមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានច្បាស់អំពីព័ត៌មានមូលដ្ឋានរបស់មិត្តភក្តិ និងគ្រួសារ<br>**បំណិនសម្បទា**<br>- ផ្តល់ព័ត៌មានអំពីអ្នកដទៃ<br>**ចរិយាសម្បទា**<br>- មានឥរិយាបថល្អក្នុងការនិយាយផ្តល់ព័ត៌មានអំពីអ្នកដទៃ | |
| ៣- ការផ្តល់ព័ត៌មានផ្សេងៗ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីលំដាប់លំដោយនៃខ្លឹមសារក្នុងការបញ្ជូនសារផ្ទាល់មាត់<br>**បំណិនសម្បទា**<br>- និយាយបញ្ជូនសារផ្ទាល់មាត់ មួយទៅពីរចំណុច<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តនិងឥរិយាបថល្អ ក្នុងការនិយាយបញ្ជូនសារផ្ទាល់មាត់ | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានព័ត៌មានសំខាន់ៗ ដែលមានប្រយោជន៍សម្រាប់អ្នកស្តាប់<br>**បំណិនសម្បទា**<br>- រៀបរាប់ឡើងវិញអំពីពេលវេលានិងទីកន្លែងនៃព្រឹត្តិការណ៍ ដែលបានកើតឡើង<br>**ចរិយាសម្បទា**<br>- មានទម្លាប់កត់ចំណាំព្រឹត្តិការណ៍ផ្សេងៗ ដែលខ្លួនបានជួបប្រទះ | |
| | **វិជ្ជាសម្បទា** | |

| | | |
|---|---|---|
| | - កំណត់បានអត្ថន័យរបស់សញ្ញាងាយៗ ដែលខ្លួនធ្លាប់បានដឹង<br>**បំណិនសម្បទា**<br>- បកស្រាយសញ្ញាងាយៗ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការប្រើប្រាស់ពាក្យសម្ដី ដើម្បីបកស្រាយសញ្ញាងាយៗ ប្រកបដោយភាពប៉ិនប្រសប់ | |
| ៤- ការរៀបរាប់និងប្រៀបធៀប | **វិជ្ជាសម្បទា**<br>- កំណត់បានលក្ខណៈរបស់វត្ថុ របៀបនិយាយរៀបរាប់និងប្រៀបធៀប<br>**បំណិនសម្បទា**<br>- រៀបរាប់ខ្លីៗ និងប្រៀបធៀបអំពីទំហំនិងពណ៌នៃវត្ថុ<br>**ចរិយាសម្បទា**<br>- មានទម្លាប់សង្កេតលក្ខណៈរបស់វត្ថុ | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានពីលំដាប់លំដោយនៃសកម្មភាពនៅផ្ទះនិងនៅសាលារៀន<br>**បំណិនសម្បទា**<br>- រៀបរាប់ខ្លីៗពីសកម្មភាពនៅផ្ទះនិងនៅសាលារៀន<br>**ចរិយាសម្បទា**<br>- មានទម្លាប់សង្កេតសកម្មភាព | |
| ៥- ការសួរ និងឆ្លើយសំណួរ | **វិជ្ជាសម្បទា**<br>- កំណត់បានពីរបៀបសួរនិងឆ្លើយសំណួរ<br>**បំណិនសម្បទា**<br>- សួរនិងឆ្លើយសំណួរអំពីប្រធានបទងាយៗ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដទៃ | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានព័ត៌មានសំខាន់ៗនិងរបៀបប្រាប់ទីកន្លែង<br>**បំណិនសម្បទា**<br>- សួរនិងឆ្លើយសំណួរក្នុងការប្រាប់ទិស ដើម្បីទៅរកផ្ទះនិងសាលារៀន<br>**ចរិយាសម្បទា**<br>- មានឥរិយាបថល្អក្នុងការជួយប្រាប់ទីកន្លែងដល់អ្នកដទៃ | |
| ៦- ការនិទានរឿង | **វិជ្ជាសម្បទា**<br>- កំណត់បានដំណើររឿងទាំងមូល<br>**បំណិនសម្បទា**<br>- ប្រាប់រឿងខ្លីៗដែលធ្លាប់បានដឹងឡើងវិញ<br>**ចរិយាសម្បទា**<br>- មានភាពក្លាហាននិងគំនិតច្នៃប្រឌិតក្នុងការប្រាប់រឿងខ្លីៗដែលបានដឹង | |

| | | |
|---|---|---|
| | ឡើងវិញ។ | |
| ៧- វិន័យ និង បទបញ្ជា | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា វិន័យនិងបទបញ្ជានៅក្នុងសាលារៀន គឺជាច្បាប់សម្រាប់ឱ្យសិស្សអនុវត្ត ហើយវាចាប់ផ្ដើមឡើងដោយពាក្យ កុំ ហាម ត្រូវ...<br>**បំណិនសម្បទា**<br>- រៀបរាប់ពីវិន័យ និងបទបញ្ជាផ្ទៃក្នុងសាលារៀន<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្ត ក្នុងការនិយាយអំពីវិន័យនិងបទបញ្ជាផ្ទៃក្នុងសាលារៀន | |
| ៨- ការសម្ដែងគំនិត និងអារម្មណ៍ | **វិជ្ជាសម្បទា**<br>- កំណត់បានពាក្យទាក់ទងនឹងអារម្មណ៍<br>**បំណិនសម្បទា**<br>- សម្ដែងអារម្មណ៍ នៅពេលនិយាយ<br>ឧ. រីករាយ ឬមិនរីករាយ ពេញចិត្ត ឬមិនពេញចិត្តអំពីប្រធានបទផ្សេងៗ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តនិងឥរិយាបថល្អក្នុងការសម្ដែងអារម្មណ៍ | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានសំនួនសម្រាប់និយាយបង្ហាញការយល់ស្រប និងមិនយល់ស្រប<br>**បំណិនសម្បទា**<br>- សម្ដែងការយល់ស្រប ឬមិនយល់ស្របចំពោះគំនិតងាយៗ<br>**ចរិយាសម្បទា**<br>- មានឥរិយាបថល្អក្នុងការប្រាស្រ័យទាក់ទងគ្នា | |
| ៩- ការធ្វើសំណើ ឬ សំណូមពរ | **វិជ្ជាសម្បទា**<br>- កំណត់បានពាក្យគួរសមនិងរបៀបធ្វើសំណើផ្ទាល់ខ្លួន<br>**បំណិនសម្បទា**<br>- ប្រើពាក្យគួរសមដើម្បីធ្វើសំណើផ្ទាល់ខ្លួន<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តនិងឥរិយាបថល្អ ក្នុងការធ្វើសំណើអ្វីមួយសម្រាប់ខ្លួន | |
| **សមត្ថភាពអាន** | | |
| បង្ហាញពីឥរិយាបថវិជ្ជមានក្នុងការអានប្រកបដោយប្រសិទ្ធភាព អានស្ទាត់ ចេះលើកដាក់សំឡេង មានទឹកមុខ កាយវិការសមរម្យ យល់ដឹងរបៀបអានដើម្បីកំណត់បានពីខ្លឹមសារ និងរបៀបរកព័ត៌មានដើម្បីឆ្លើយនឹងសំណួរទាក់ទងនឹងការអានស្រៈ ព្យញ្ជនៈ ព្យាង្គ ពាក្យ កន្សោមពាក្យ ឃ្លា និងល្បះ | | |
| **I. បុរេអំណាន** | | |
| ១- ការបង្ហាញបំណិនក្នុងការញែកទម្រង់ | **វិជ្ជាសម្បទា**<br>- ប្រាប់ភាពដូចគ្នានិងខុសគ្នានៃទ្រង់ទ្រាយនិងតួអក្សរ<br>**បំណិនសម្បទា**<br>- បង្ហាញភាពដូចគ្នា និងខុសគ្នាតាមទ្រង់ទ្រាយនិងតួអក្សរ | |

| | | |
|---|---|---|
| | ឧ១. «ក គ ក ក» អក្សរដែលខុសគេគឺ គ<br>ឧ២. «□□O□□» ទ្រង់ទ្រាយដែលខុសគេគឺ O<br>**ចរិយាសម្បទា**<br>- មានទម្លាប់ក្នុងការសង្កេតទ្រង់ទ្រាយនិងតួអក្សរ ដោយប្រុងប្រយ័ត្ន | |
| **II. ការយល់ដឹងអំពីសូរ** | | |
| ១- ការបំបែកល្បះនិងពាក្យជាព្យាង្គ | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ពាក្យកើតឡើងពីព្យាង្គ<br>**បំណិនសម្បទា**<br>- បំបែកល្បះនិងពាក្យ ជាព្យាង្គ<br>ឧ. ទះដៃតាមចំនួនព្យាង្គ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការបំបែកល្បះនិងពាក្យ ជាព្យាង្គ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ពាក្យខ្លះកើតឡើងពីការផ្សំព្យាង្គបញ្ចូលគ្នា (ចាប់ពីពីរព្យាង្គឡើង)<br>**បំណិនសម្បទា**<br>- កំណត់ព្យាង្គ នៅក្នុងពាក្យ<br>ឧ. កាបូប កា បូប<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការកំណត់ព្យាង្គ នៅក្នុងពាក្យ | |
| ២- ការផ្សំព្យាង្គជាពាក្យ | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ពាក្យខ្លះកើតឡើងពីការផ្សំព្យាង្គបញ្ចូលគ្នា(ចាប់ពីពីរព្យាង្គឡើង)<br>**បំណិនសម្បទា**<br>- ផ្សំព្យាង្គជាពាក្យ<br>ឧ. កា បូប កាបូប<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការផ្សំព្យាង្គជាពាក្យ | |
| ៣- ការកំណត់សូរអក្សរ | **វិជ្ជាសម្បទា**<br>- ប្រាប់សូរព្យញ្ជនៈពីរក្រុមដែលខុសគ្នា (ពួក អ និង អ៊)<br>**បំណិនសម្បទា**<br>- កំណត់សូរព្យញ្ជនៈពួក អ និងពួក អ៊<br>ឧ. "ក" មានសូរ អ និង "គ" មានសូរ អ៊<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការកំណត់សូរព្យញ្ជនៈដែលបានស្តាប់ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីសូរដូចគ្នា និងសូរខុសគ្នានៃអក្សរ<br>**បំណិនសម្បទា** | |

| | | |
|---|---|---|
| | - កំណត់សូរអក្សរដូចគ្នា និង ខុសគ្នា<br>ឧ. សូរដូចគ្នា៖ "ក និង ក " " ែ" និង ែ"<br>ឧ. សូរខុសគ្នា៖ " ក និង ខ " " ិ និង ី "<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការកំណត់សូរអក្សរដែលបានស្ដាប់ | |
| ៤- ការកំណត់សូរ នៅក្នុងពាក្យ | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ពាក្យកើតពីការប្រកបសូរព្យញ្ជនៈ និងសូរស្រៈ<br>ឧ. ពាក្យ«កី» មានសូរព្យញ្ជនៈ «ក» និងសូរស្រៈ «អី»<br>**បំណិនសម្បទា**<br>- កំណត់សូរស្រៈ នៅចុងពាក្យ<br>ឧ ១. តើពាក្យណាមួយដែលមាន សូរ «អី»? ដី មេ ដើរ<br>ឧ ២. តើពាក្យណាមួយដែលមាន សូរ «អ៊ា» ? ទា សី កេះ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការស្ដាប់សូរស្រៈ នៅចុងពាក្យ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ពាក្យកើតពីការប្រកបសូរព្យញ្ជនៈ និងសូរស្រៈ<br>ឧ. ពាក្យ«កី» មានសូរព្យញ្ជនៈ «ក» និងសូរស្រៈ «អី»<br>**បំណិនសម្បទា**<br>- កំណត់សូរដើមនៃពាក្យ<br>ឧ. តើពាក្យណាដែលមានសូរដើម «ក» ? «កា ទី បេះ»<br>**ចរិយាសម្បទា**<br>- មានទម្លាប់ស្ដាប់សូរដើមនៃពាក្យ ដោយប្រុងប្រយ័ត្ន | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា សូរដើមនៃពាក្យខ្លះដូចគ្នា<br>**បំណិនសម្បទា**<br>- កំណត់សូរដើមដូចគ្នានៃពាក្យ<br>ឧ. ពាក្យ «កា កែ» មានសូរដើម «ក» ដូចគ្នា<br>**ចរិយាសម្បទា**<br>- មានទម្លាប់ស្ដាប់សូរដើមនៃពាក្យ ដោយប្រុងប្រយ័ត្ន | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ពាក្យកើតពីការប្រកបសូរព្យញ្ជនៈនិងសូរស្រៈ<br>**បំណិនសម្បទា**<br>- កំណត់សូរចុងនៃពាក្យ<br>ឧ. តើអ្វីជាសូរចុងនៃពាក្យ «ទា គា លា»? (សូរអ៊ា)<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការកំណត់សូរចុងនៃពាក្យ | |

| | | |
|---|---|---|
| | **វិជ្ជាសម្បទា**<br>- ប្រាប់ចំនួនសូរនៅក្នុងពាក្យប្រកប(ពសព)<br>**បំណិនសម្បទា**<br>- កំណត់សូរដើមនៃពាកប្រកប (ពសព)<br>ឧ. ពាក្យ«កាល» មានសូរដើម ក<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការស្តាប់សូរដើមនៃពាក្យប្រកប | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់ចំនួនសូរ នៅក្នុងពាក្យប្រកប<br>**បំណិនសម្បទា**<br>- កំណត់ «សូរបន្ទាប់» ឬ «សូរកណ្តាល» នៃពាក្យប្រកប(ពសព)<br>ឧ. សូរកណ្តាលនៃពាក្យ«កាល» គឺ «អា »<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រុងប្រយ័ត្នក្នុងការស្តាប់សូរកណ្តាលនៃពាក្យប្រកប | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់ចំនួនសូរនៅក្នុងពាក្យប្រកប<br>**បំណិនសម្បទា**<br>- កំណត់ «សូរចុង» នៃពាក្យប្រកប(ពសព)<br>ឧ. សូរចុងនៃពាក្យ «កាល» គឺ «ល»<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រុងប្រយ័ត្នក្នុងការស្តាប់សូរចុងនៃពាក្យប្រកប | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ផ្ញើជើងកើតពីសូរព្យញ្ជនៈ ប្រកបនឹងសូរជើងព្យញ្ជនៈ<br>**បំណិនសម្បទា**<br>- កំណត់សូរដើមនៃពាក្យផ្ញើជើង<br>ឧ. សូរដើមនៃពាក្យ «ក្បាល ផ្ទះ ស្រី» គឺ « ក្ប ផ្ទ ស្រ »<br>**ចរិយាសម្បទា**<br>- មានការប្រុងប្រយ័ត្នក្នុងការស្តាប់សូរដើមនៃពាក្យផ្ញើជើង | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ពាក្យប្រកបមានសូរវែងនិងសូរខ្លី<br>**បំណិនសម្បទា**<br>- កំណត់ភាពខុសគ្នារវាងសូរវែងនិងសូរខ្លីនៃពាក្យប្រកបដែលគ្មានបន្តក់និង មានបន្តក់<br>ឧ. ពាក្យ «កក កាក សាក»មានសូរវែង<br>ឧ. ពាក្យ« កក់ កាក់ សាក់» មានសូរខ្លី<br>**ចរិយាសម្បទា** | |

| | | |
|---|---|---|
| | - មានទំនុកចិត្តក្នុងការកំណត់សូរវែងនិងសូរខ្លីនៃពាក្យប្រកបដែលគ្មានបន្តក់និងមានបន្តក់ | |
| ៥- ការប្រកបសូរជាពាក្យ | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ពាក្យកើតឡើងពីការប្រកបសូរ<br>**បំណិនសម្បទា**<br>- ប្រកបសូរជាពាក្យ<br>ឧ. ក អា កា<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការប្រកបសូរជាពាក្យ | |
| ៦- ការបំបែកពាក្យជាសូរ | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ពាក្យកើតឡើងពីការប្រកបសូរ<br>**បំណិនសម្បទា**<br>- បំបែកពាក្យជាសូរ<br>ឧ. កា ក អា<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការបំបែកពាក្យ ជាសូរ | |
| ៧- ការយល់ដឹងអំពីពាក្យចួន | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា ពាក្យចួនគឺជាពាក្យដែលមានសូរចុងដូចគ្នា<br>**បំណិនសម្បទា**<br>- បង្ហាញពាក្យចួននៅពេលស្ដាប់<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការរកពាក្យចួន | |
| **III. ការយល់ដឹងអំពីទំនាក់ទំនងរវាងតួអក្សរនិងសូរ** | | |
| ១- ការបន្លឺតួអក្សរ | **វិជ្ជាសម្បទា**<br>- ប្រាប់រូបរាង និងឈ្មោះស្រៈនិស្ស័យព្រមទាំងបញ្ជាក់ថា ស្រៈនិស្ស័យមានសូរពីរផ្សេងគ្នា នៅពេលប្រកបជាមួយព្យញ្ជនៈពួក«អ» និងព្យញ្ជនៈពួក «អ៊»<br>**បំណិនសម្បទា**<br>- អានឈ្មោះស្រៈនិស្ស័យ និងសូររបស់វានៅពេលប្រកបជាមួយព្យញ្ជនៈពួក «អ» និង ព្យញ្ជនៈពួក «អ៊»<br>**ចរិយាសម្បទា**<br>- មានទម្លាប់សង្កេតរូបរាង ស្ដាប់សូរស្រៈនិស្ស័យនិងការប្រកបសូរស្រៈជាមួយព្យញ្ជនៈ ដោយប្រុងប្រយ័ត្ន | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់រូបរាង ឈ្មោះ និងសូរព្យញ្ជនៈព្រមទាំងបញ្ជាក់ថាសូរព្យញ្ជនៈមានពីរពួក<br>**បំណិនសម្បទា**<br>- អានឈ្មោះ និង សូរព្យញ្ជនៈ | |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- មានទម្លាប់សង្កេតរូបរាង  និងស្ដាប់សូរព្យញ្ជនៈដោយយកចិត្តទុកដាក់ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់រូបរាង ឈ្មោះ និងសូរជើងព្យញ្ជនៈ<br>**បំណិនសម្បទា**<br>- អានឈ្មោះ និង សូរជើងព្យញ្ជនៈ<br>**ចរិយាសម្បទា**<br>- មានទម្លាប់សង្កេតរូបរាងនិងស្ដាប់សូរជើងព្យញ្ជនៈ ដោយយកចិត្តទុកដាក់ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់រូបរាង ឈ្មោះ និងសូរស្រៈពេញតួ<br>**បំណិនសម្បទា**<br>- អានឈ្មោះ និងសូរស្រៈពេញតួ<br>**ចរិយាសម្បទា**<br>- មានទម្លាប់សង្កេតរូបរាងនិងស្ដាប់សូរស្រៈពេញតួ ដោយយកចិត្តទុកដាក់ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់ព្យញ្ជនៈមួយចំនួនដែលប្រើសញ្ញាមូសិកទន្ត និងត្រីសព្ទ ហើយប្រាប់បានថា នៅពេលព្យញ្ជនៈទាំងនេះប្រើជាមួយនឹងសញ្ញាមូសិកទន្តនិងត្រីសព្ទ វានឹងប្តូរសូរថ្មី<br>**បំណិនសម្បទា**<br>- អានព្យញ្ជនៈបន្ថែម (ព្យញ្ជនៈដែលមានសញ្ញាមូសិកទន្តនិងត្រីសព្ទ)<br>ឧ. ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ ប៊ ស៊ ហ៊ អ៊<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានព្យញ្ជនៈបន្ថែម | |
| ២- ការអានពាក្យ ដែលមាន ព្យញ្ជនៈផ្សំស្រៈ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបប្រកបសូរព្យញ្ជនៈពួក «អ» និងស្រៈ<br>**បំណិនសម្បទា**<br>- អានពាក្យដែលមានព្យញ្ជនៈពួក«អ» ផ្សំស្រៈ ដោយប្រកប<br>- ឧ. ក   អា   កា<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានព្យញ្ជនៈពួក «អ»ផ្សំស្រៈ ដោយប្រកប | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបអានព្យញ្ជនៈពួក «អ»  ផ្សំស្រៈដោយមិនប្រកប<br>**បំណិនសម្បទា**<br>- អានពាក្យដែលមានព្យញ្ជនៈពួក«អ» ផ្សំស្រៈ ដោយមិនប្រកប<br>ឧ. កា | |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានព្យញ្ជនៈពួក «អ»ផ្សំស្រៈ ដោយមិនប្រកប | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបប្រកបសូរព្យញ្ជនៈពួក «អ៊» និងស្រៈ<br>**បំណិនសម្បទា**<br>- អានពាក្យដែលមានព្យញ្ជនៈពួក«អ៊»ផ្សំស្រៈ ដោយប្រកប<br>ឧ. គ អ៊ា គា<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានព្យញ្ជនៈពួក «អ៊»ផ្សំស្រៈដោយប្រកប | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបអានព្យញ្ជនៈពួក«អ៊» ផ្សំស្រៈ ដោយមិនប្រកប<br>**បំណិនសម្បទា**<br>- អានពាក្យដែលមានព្យញ្ជនៈពួក «អ៊»ផ្សំស្រៈ ដោយមិនប្រកប<br>ឧ. គា<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានព្យញ្ជនៈពួក «អ៊»ផ្សំស្រៈ ដោយមិនប្រកប | |
| ៣- ការអានពាក្យដែលមានប្រើវណ្ណយុត្ត | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះសញ្ញាត្រីសព្ទ និងមូសិកទន្ត<br>**បំណិនសម្បទា**<br>- ហៅឈ្មោះវណ្ណយុត្តដែលប្រើញឹកញាប់ ដូចជា សញ្ញាត្រីសព្ទ( ៊ ) និង មូសិកទន្ត (៉)<br>**ចរិយាសម្បទា**<br>- មានទម្លាប់សង្កេតរូបរាងសញ្ញាវណ្ណយុត្តមួយចំនួនដែលប្រើញឹកញាប់ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបអានពាក្យដែលប្រើសញ្ញាត្រីសព្ទ និង មូសិកទន្តដោយប្រកប<br>**បំណិនសម្បទា**<br>- អានពាក្យដែលមានសញ្ញាត្រីសព្ទ និងមូសិកទន្ត ដោយប្រកប<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានពាក្យដែលមានសញ្ញាត្រីសព្ទ និងមូសិកទន្តដោយប្រកប | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបអានពាក្យដែលប្រើសញ្ញាត្រីសព្ទ និង មូសិកទន្ត ដោយមិនប្រកប<br>**បំណិនសម្បទា**<br>- អានពាក្យដែលមានប្រើសញ្ញាត្រីសព្ទ និងមូសិកទន្តដោយមិនប្រកប | |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានពាក្យដែលមានសញ្ញាត្រីសព្ទ និងមូសិកទន្ត ដោយមិនប្រកប | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះសញ្ញាលេខទោ និងរបៀបអានពាក្យដែលមានសញ្ញាលេខទោ<br>**បំណិនសម្បទា**<br>- អានពាក្យដែលមានសញ្ញាលេខទោ (ៗ)<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានពាក្យដែលមានសញ្ញាលេខទោ | |
| ៤-ការអានពាក្យប្រកបដែលគ្មានសញ្ញាបន្តក់ និងមានសញ្ញាបន្តក់ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបអានពាក្យប្រកបដែលគ្មានសញ្ញាបន្តក់និងមានសញ្ញាបន្តក់ ដោយប្រកប<br>**បំណិនសម្បទា**<br>- អានពាក្យប្រកបដែលគ្មានសញ្ញាបន្តក់ និងមានសញ្ញាបន្តក់ ដោយប្រកប<br>ឧ១. កាក អានថា ក...អា...កា... កា...ក......កាក<br>ឧ២. កាក់ អានថា ក...អា...កា... កា...ក បន្តក់មួយ កាក់<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានពាក្យប្រកបដែលគ្មានសញ្ញាបន្តក់ និងមានសញ្ញាបន្តក់ ដោយប្រកប | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបអានពាក្យប្រកបដែលគ្មានសញ្ញាបន្តក់និងមានសញ្ញាបន្តក់ ដោយមិនប្រកប<br>**បំណិនសម្បទា**<br>- អានពាក្យប្រកបដែលគ្មានសញ្ញាបន្តក់ និងមានសញ្ញាបន្តក់ដោយមិនប្រកប<br>ឧ១. កាក អានថា កាក<br>ឧ២. តាក់ អានថា តាក់<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានពាក្យប្រកបដែលគ្មានសញ្ញាបន្តក់ និងមានសញ្ញាបន្តក់ ដោយមិនប្រកប | |
| ៥-ការអានពាក្យដែលមានស្រៈពេញតួ | **វិជ្ជាសម្បទា**<br>- កំណត់បានពីសូររបស់ពាក្យដែលមានស្រៈពេញតួ<br>**បំណិនសម្បទា**<br>- អានពាក្យងាយៗខ្លះ ដែលមានស្រៈពេញតួ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានពាក្យងាយៗដែលមានស្រៈពេញតួ | |

| | | |
|---|---|---|
| ៦-ការអានពាក្យ<br>ផ្ញើជើង | **វិជ្ជាសម្បទា**<br>- ប្រាប់របៀបប្រកបសូរព្យញ្ជនៈ និងជើងព្យញ្ជនៈព្រមទាំងរបៀបអានពាក្យផ្ញើជើងដោយប្រកប<br>**បំណិនសម្បទា**<br>- អានពាក្យផ្ញើជើងងាយៗ ដោយប្រកប<br>ឧ. ស្រី អានថា ស...ជើង រ...ស្រ....ស្រ....អី.....ស្រី<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានពាក្យផ្ញើជើង ដោយប្រកប | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់របៀបអានពាក្យព្យាង្គតម្រួត ដោយមិនប្រកប<br>**បំណិនសម្បទា**<br>- អានពាក្យព្យាង្គតម្រួតងាយៗ ដោយមិនប្រកប<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានពាក្យព្យាង្គតម្រួតងាយៗ ដោយមិនប្រកប | |
| ៧- ការអានពាក្យ<br>ពហុព្យាង្គ | **វិជ្ជាសម្បទា**<br>- ប្រាប់ថាពាក្យខ្លះកើតឡើងដោយការផ្សំព្យាង្គ ចាប់ពីពីរព្យាង្គឡើង<br>**បំណិនសម្បទា**<br>- ប្រើវិធីញែកព្យាង្គ ដើម្បីអានពាក្យពីរព្យាង្គងាយៗ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការកំណត់ព្យាង្គ នៅក្នុងពាក្យពីរព្យាង្គ | |
| ៨-ការអានពាក្យ<br>ចំណាំ | **វិជ្ជាសម្បទា**<br>- កំណត់បានតួអក្សរនៅក្នុងឈ្មោះរបស់ខ្លួន<br>**បំណិនសម្បទា**<br>- អានឈ្មោះខ្លួនឯង<br>**ចរិយាសម្បទា**<br>- មានភាពសប្បាយរីករាយ ដោយចេះអានឈ្មោះរបស់ខ្លួន | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់តួអក្សរដែលមិនត្រូវអាន នៅក្នុងពាក្យដែលមានតួអក្សរមិនអាន<br>**បំណិនសម្បទា**<br>- អានពាក្យដែលមានតួអក្សរ(រ)នៅខាងចុងមិនអាន<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានពាក្យដែលមានតួអក្សរ(រ)មិនអាន | |
| | **វិជ្ជាសម្បទា**<br>- កត់ចំណាំពាក្យមួយចំនួនជាអញ្ញត្រសព្ទដែលមានសូរអានខុសពីសំណេរ<br>**បំណិនសម្បទា**<br>- អានពាក្យជាអញ្ញត្រសព្ទ | |

| | | |
|---|---|---|
| | ឱ. អ្នក អញ នេះ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានពាក្យដែលជាអញ្ញត្រសព្ទ | |
| **IV. ការអានស្ទាត់** | | |
| ១- ការអានពាក្យស្ទាត់ | **វិជ្ជាសម្បទា**<br>- ស្គាល់ពាក្យច្បាស់ និងដឹងពីរបៀបអានស្ទាត់<br>**បំណិនសម្បទា**<br>- អានពាក្យបានស្ទាត់(ត្រឹមត្រូវ ប្រើល្បឿនលឿន ដោយមិនបាច់ប្រកប)<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តនិងចូលចិត្តអានពាក្យ | |
| ២- ការអានល្បះ និងអត្ថបទខ្លីៗស្ទាត់ | **វិជ្ជាសម្បទា**<br>- កំណត់ពាក្យនីមួយៗនៅក្នុងល្បះ បានច្បាស់លាស់<br>**បំណិនសម្បទា**<br>- ញែកពាក្យក្នុងល្បះ ដើម្បីអានស្ទាត់<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការញែកពាក្យ នៅក្នុងល្បះ | |
| | **វិជ្ជាសម្បទា**<br>- អានពាក្យនីមួយៗ នៅក្នុងល្បះ ឬអត្ថបទ បានត្រឹមត្រូវ<br>**បំណិនសម្បទា**<br>- អានល្បះបានស្ទាត់(ត្រឹមត្រូវ ប្រើល្បឿនលឿន និងមានការលើកដាក់សំឡេង)<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានល្បះ អត្ថបទ និងចូលចិត្តអាន | |
| | **វិជ្ជាសម្បទា**<br>- អានពាក្យនីមួយៗ នៅក្នុងល្បះ ឬអត្ថបទ បានត្រឹមត្រូវ<br>**បំណិនសម្បទា**<br>- អានអត្ថបទខ្លី ចម្រៀង កំណាព្យ និងរឿងខ្លីៗនៅក្នុងសៀវភៅអំណានបន្ថែម បានស្ទាត់(ត្រឹមត្រូវ ប្រើល្បឿនលឿន និងមានការលើកដាក់សំឡេង)<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការអានល្បះ និងអត្ថបទ និងចូលចិត្តអាន | |
| ៣- ការអានដែលមានការលើកដាក់សំឡេងទៅតាមការប្រើប្រាស់សញ្ញាផ្សេងៗ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះសញ្ញា ការផ្អាកសំឡេង (ដកឃ្លា) និងការប្រើសំឡេងទៅតាមសញ្ញាផ្សេងៗ នៅក្នុងល្បះ<br>**បំណិនសម្បទា**<br>- ប្រាប់ឈ្មោះសញ្ញា ហើយអានល្បះ កថាខណ្ឌ និងអត្ថបទខ្លីៗ ដោយមានការផ្អាកសំឡេង(ដកឃ្លា) និងលើកដាក់សំឡេងទៅតាមសញ្ញាខណ្ឌ និងសញ្ញាសួរ | |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- មានទម្លាប់អានល្បះនិងអត្ថបទ ដោយគោរពសញ្ញាផ្សេងៗបានត្រឹមត្រូវ | |
| ៤-ការបង្ហាញ ឥរិយាបថ ក្នុងការអាន | **វិជ្ជាសម្បទា**<br>- ប្រាប់បានថា នៅពេលអាន គប្បីប្រើសំឡេង ទឹកមុខ និងកាយវិការទៅតាមខ្លឹមសារនៃអត្ថបទ<br>**បំណិនសម្បទា**<br>- អានបានត្រឹមត្រូវទៅតាមស្ថានភាព ដោយប្រើសូរសំឡេង និងបង្ហាញទឹកមុខ ឬកាយវិការបានសមរម្យ<br>**ចរិយាសម្បទា**<br>- មានបម្រុងប្រយ័ត្ន និងឥរិយាបថសមស្រប ក្នុងការអានអត្ថបទផ្សេងៗ | |
| V. វាក្យសព្ទ | | |
| ១- ការកត់សម្គាល់ ន័យនៃពាក្យ | **វិជ្ជាសម្បទា**<br>- ប្រាប់ន័យរបស់រូបភាពនីមួយៗ បានច្បាស់លាស់<br>**បំណិនសម្បទា**<br>- បង្ហាញន័យនៃពាក្យ តាមរយៈការភ្ជាប់ពាក្យទៅនឹងរូបភាព<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការភ្ជាប់ពាក្យទៅនឹងរូបភាព | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានន័យផ្សេងៗរបស់ពាក្យ<br>**បំណិនសម្បទា**<br>- ពន្យល់ន័យនៃពាក្យងាយៗ ដែលបានអាន<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការពន្យល់ន័យរបស់ពាក្យងាយៗ | |
| ២- ការប្រើវិធីផ្សេងៗ ដើម្បីរកន័យ របស់ពាក្យ | **វិជ្ជាសម្បទា**<br>- ពន្យល់បានថា រូបភាពអាចប្រាប់ន័យរបស់ពាក្យ<br>**បំណិនសម្បទា**<br>- រកន័យរបស់ពាក្យងាយៗ តាមរយៈការប្រើរូបភាពជាបរិបទ ឬទីសេចក្ដីបញ្ជាក់<br>**ចរិយាសម្បទា**<br>- មានទម្លាប់រកន័យរបស់ពាក្យ ដោយសង្កេតរូបភាព | |
| VI. **ការអានដើម្បីយល់ន័យ** | | |
| ១- ការអានអត្ថបទ ពណ៌នា រឿងនិទាន កំណាព្យ និង ចម្រៀងខ្លីៗ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបទស្សន៍ទាយខ្លឹមសារ មុននឹងអានរឿងនិទាន<br>**បំណិនសម្បទា**<br>- ទស្សន៍ទាយខ្លឹមសារ មុននឹងអានរឿងនិទាន<br>**ចរិយាសម្បទា**<br>- មានទម្លាប់ទស្សន៍ទាយខ្លឹមសាររឿង មុនពេលអានរឿងនិទាន | |

| | | |
|---|---|---|
| | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបរកព័ត៌មាន ដើម្បីឆ្លើយនឹងសំណួរ<br>**បំណិនសម្បទា**<br>- បង្ហាញការយល់ន័យអត្ថបទ បន្ទាប់ពីអានអត្ថបទផ្សេងៗដែលមានព័ត៌មានបង្ហាញត្រង់ ដោយឆ្លើយទៅនឹងសំណួរងាយៗដូចជា អ្វី នរណា ឯណា ពេលណា របៀបណា ឬដូចម្ដេច ហេតុអ្វី<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការបង្ហាញអត្ថន័យ វិភាគ និងវាយតម្លៃអត្ថបទ ដែលបានអាន | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបរកព័ត៌មាន ដើម្បីរៀបលំដាប់ព្រឹត្តិការណ៍រឿង<br>ឧ. អានអត្ថបទឡើងវិញ មើលចំណុចចាប់ផ្ដើម កណ្ដាល និងចុងបញ្ចប់<br>**បំណិនសម្បទា**<br>- រៀបព្រឹត្តិការណ៍រឿងឡើងវិញតាមលំដាប់ ដោយប្រើរូបភាពជាជំនួយ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការរៀបព្រឹត្តិការណ៍រឿងឡើងវិញ តាមលំដាប់ | |
| | **វិជ្ជាសម្បទា**<br>- កំណត់ដំណើររឿងបានតាមលំដាប់លំដោយនិងពាក្យនិយាយបានត្រឹមត្រូវ<br>**បំណិនសម្បទា**<br>- និទានរឿងខ្លីៗឡើងវិញ ដោយប្រើពាក្យផ្ទាល់ខ្លួនងាយៗ<br>**ចរិយាសម្បទា**<br>- មានភាពក្លាហានក្នុងការនិទានរឿងឡើងវិញ ដោយប្រើពាក្យផ្ទាល់ខ្លួន | |
| | **វិជ្ជាសម្បទា**<br>- ប្រើពាក្យសម្ដីដើម្បីបញ្ជាក់គំនិតផ្ទាល់ខ្លួនអំពីតួអង្គនិងខ្លឹមសាររឿង<br>**បំណិនសម្បទា**<br>- បង្ហាញអារម្មណ៍ផ្ទាល់ខ្លួនចំពោះតួអង្គ និងខ្លឹមសាររឿង<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចរិតលក្ខណៈតាមតួអង្គល្អក្នុងរឿងដែលខ្លួនពេញចិត្ត | |
| | **វិជ្ជាសម្បទា**<br>- កត់សម្គាល់ចរិតលក្ខណៈ ការប្រព្រឹត្តរបស់តួអង្គនីមួយៗនៅក្នុងរឿង<br>**បំណិនសម្បទា**<br>- វិភាគរឿង<br>ឧ. បង្ហាញភាពដូចគ្នា និងភាពខុសគ្នានៃតួអង្គ<br>**ចរិយាសម្បទា**<br>- មានទម្លាប់វិភាគតួអង្គ នៅក្នុងរឿង | |
| | **វិជ្ជាសម្បទា** | |

| | | |
|---|---|---|
| | - កំណត់ពាក្យគន្លឹះ ឃ្លាដែលបង្ហាញហេតុ និងឃ្លាដែលបង្ហាញផល<br>**បំណិនសម្បទា**<br>- ប្រាប់ទំនាក់ទំនងរវាងហេតុនិងផលដែលមានប្រើពាក្យគន្លឹះនៅក្នុងរឿងនិទាន និងអត្ថបទពណ៌នា<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការប្រាប់ទំនាក់ទំនងរវាងហេតុនិងផល នៅក្នុងរឿងនិទាន និងអត្ថបទពណ៌នា | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអត្ថន័យនៃដំបូន្មានរឿង  អត្ថបទពណ៌នា កំណាព្យនិងចម្រៀង<br>**បំណិនសម្បទា**<br>- បង្ហាញដំបូន្មានរបស់រឿងនិទាន អត្ថបទពណ៌នា  កំណាព្យនិងចម្រៀងខ្លីៗ<br>**ចរិយាសម្បទា**<br>- មានទម្លាប់ស្វែងយល់ដំបូន្មានរបស់រឿងនិទាន អត្ថបទ ពណ៌នាកំណាព្យ និងចម្រៀង | |
| | **វិជ្ជាសម្បទា**<br>- កំណត់បានអត្ថន័យនៃរឿងទាំងមូល<br>**បំណិនសម្បទា**<br>- បង្កើតគំនិតថ្មី ដើម្បីបញ្ចប់រឿងដែលបានអាន<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការបញ្ចប់រឿងដែលបានអាន តាមគំនិតផ្ទាល់ខ្លួន | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់ន័យរបស់រូបភាពដែលជាបរិបទបញ្ជាក់<br>**បំណិនសម្បទា**<br>- ប្រាប់ន័យរបស់ល្បះ រឿងនិទាន អត្ថបទពណ៌នា កំណាព្យឬចម្រៀង តាមរយៈការប្រើរូបភាពជាបរិបទបញ្ជាក់<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការប្រាប់ន័យរបស់ល្បះ ឬអត្ថបទខ្លីតាមការសង្កេតរូបភាពជាបរិបទ | |
| **សមត្ថភាពសរសេរ** | | |
| **I. បុរេសំណេរ** | | |
| ១- បំណិនប្រសប់ចក្ខុនិងហត្ថចលនា | **វិជ្ជាសម្បទា**<br>- ប្រាប់បានការណែនាំរបស់គ្រូ អំពីការគូសបន្ទាត់តាមទិសដៅនីមួយៗ ដោយនិយាយបណ្ដើរ គូសបណ្ដើរ<br>**បំណិនសម្បទា**<br>- ធ្វើតាមការណែនាំរបស់គ្រូ  ដោយនិយាយបណ្ដើរ គូសបណ្ដើរពីឆ្វេងទៅស្ដាំ ពីលើចុះក្រោម ឡើងចុះ ឬខ្សែកោង | |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការសម្របសម្រួលចលនាដៃនិងភ្នែក ដើម្បីគូសតាមការណែនាំរបស់គ្រូ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីទិសដៅនៃស្នាមគំនូស ឬបន្ទាត់នីមួយៗ(ពីឆ្វេងទៅស្តាំពីលើចុះក្រោម...)<br>**បំណិនសម្បទា**<br>- បង្ហាញចលនាដៃក្នុងការគូសតាមទិសដៅ ពីឆ្វេងទៅស្តាំ ពីលើចុះក្រោម ឬឡើងចុះ ខ្សែកោង ។ល។ បានយ៉ាងត្រឹមត្រូវ<br>**ចរិយាសម្បទា**<br>- មានការប្រុងប្រយ័ត្ន ក្នុងការកំណត់ទិសដៅនៃស្នាមគំនូស ឬបន្ទាត់ផ្សេងៗ | |
| **II. ការប្រើចលនាដៃសម្រាប់ការសរសេរ** | | |
| ១- ការសរសេរតួអក្សរតាមចលនា | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបសរសេរព្យញ្ជនៈ និងជើងព្យញ្ជនៈ តាមលំដាប់ លំដោយនៃចលនានីមួយៗ<br>**បំណិនសម្បទា**<br>- សរសេរព្យញ្ជនៈ និងជើងព្យញ្ជនៈ តាមចលនា បានត្រឹមត្រូវ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការសរសេរព្យញ្ជនៈ និងជើងព្យញ្ជនៈតាមចលនាបានត្រឹមត្រូវ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបសរសេរស្រៈនិស្ស័យ តាមលំដាប់លំដោយនៃចលនានីមួយៗ<br>**បំណិនសម្បទា**<br>- សរសេរស្រៈនិស្ស័យតាមចលនាបានត្រឹមត្រូវ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការសរសេរស្រៈនិស្ស័យតាមចលនា បានត្រឹមត្រូវ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបសរសេរស្រៈពេញតួ តាមលំដាប់លំដោយនៃចលនានីមួយៗ<br>**បំណិនសម្បទា**<br>- សរសេរស្រៈពេញតួ តាមចលនាបានត្រឹមត្រូវ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការសរសេរស្រៈពេញតួតាមចលនា បានត្រឹមត្រូវ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបសរសេរសញ្ញាមូសិកទន្ត សញ្ញាត្រីសព្ទ សញ្ញាលេខទោ និងសញ្ញាបន្តក់ តាមលំដាប់លំដោយនៃចលនានីមួយៗ<br>**បំណិនសម្បទា**<br>- សរសេរវណ្ណយុត្តដែលប្រើញឹកញាប់ដូចជា សញ្ញាមូសិកទន្ត សញ្ញាត្រីសព្ទ | |

| | | |
|---|---|---|
| | សញ្ញាលេខទោ និងសញ្ញាបន្តក់តាមចលនាបានត្រឹមត្រូវ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការសរសេរសញ្ញាមូសិកទន្ត សញ្ញាត្រីសព្ទ សញ្ញាលេខទោ និងសញ្ញាបន្តក់តាមចលនាបានត្រឹមត្រូវ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបសរសេរសញ្ញាខណ្ឌនិងសញ្ញាសួរ តាមលំដាប់ លំដោយនៃចលនានីមួយៗ<br>**បំណិនសម្បទា**<br>- សរសេរសញ្ញាខណ្ឌនិងសញ្ញាសួរតាមចលនា បានត្រឹមត្រូវ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការសរសេរសញ្ញាខណ្ឌនិងសញ្ញាសួរតាមចលនា បានត្រឹមត្រូវ | |
| ២- ការសរសេរអក្សរផ្ចង់ | **វិជ្ជាសម្បទា**<br>- កំណត់បានពីរូបរាងនិងទំហំនៃតួអក្សរដែលត្រូវសរសេរ<br>**បំណិនសម្បទា**<br>- ប្រើទម្រង់អក្សរផ្ចង់ដែលស្អាត និងច្បាស់លាស់<br>  ○ ទម្រង់អក្សរពុម្ព(ត្រង់)<br>**ចរិយាសម្បទា**<br>- មានទម្លាប់សរសេរអក្សរតាមទម្រង់អក្សរពុម្ពដោយផ្ចិតផ្ចង់បានយ៉ាងស្អាត និងត្រឹមត្រូវ | |
| **III. ការសរសេរតួអក្សរ និងពាក្យ** | | |
| ១- ការសរសេរតួអក្សរ | **វិជ្ជាសម្បទា**<br>- កំណត់បានពីសូរនិងរូបរាងនៃតួអក្សរ(ស្រៈនិស្ស័យ ព្យញ្ជនៈ ជើងព្យញ្ជនៈ និងស្រៈពេញតួ)<br>**បំណិនសម្បទា**<br>- បង្ហាញការយល់ដឹងអំពីទំនាក់ទំនងរវាងតួអក្សរ និងសូរ តាមរយៈការសរសេរស្រៈនិស្ស័យ ព្យញ្ជនៈ ជើងព្យញ្ជនៈ និងស្រៈពេញតួ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការសរសេរស្រៈនិស្ស័យ ព្យញ្ជនៈ ជើងព្យញ្ជនៈនិងស្រៈពេញតួ | |
| ២- ការសរសេរពាក្យ | **វិជ្ជាសម្បទា**<br>- កំណត់បានពីតួអក្សរនិងលំដាប់នៃតួអក្សរនីមួយៗ នៅក្នុងឈ្មោះរបស់ខ្លួនឯង<br>**បំណិនសម្បទា**<br>- សរសេរឈ្មោះខ្លួនឯង តាមការណែនាំរបស់គ្រូ(ប្រសិនបើចាំបាច់)<br>**ចរិយាសម្បទា**<br>- មានមោទនភាព ដោយចេះសរសេរឈ្មោះខ្លួនឯង | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីពាក្យដែលត្រូវបំពេញនិងតួអក្សរទាំងអស់ តាមលំដាប់ នៅក្នុងពាក្យ | |

| | | |
|---|---|---|
| | នោះ<br>**បំណិនសម្បទា**<br>- សរសេរតួអក្សរ ដើម្បីបំពេញពាក្យងាយៗ បានត្រឹមត្រូវ<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការបំពេញតួអក្សរ នៅក្នុងពាក្យងាយៗ | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីពាក្យដែលត្រូវនឹងរូបភាព និងតួអក្សរនៅក្នុងពាក្យនោះ<br>**បំណិនសម្បទា**<br>- សរសេរពាក្យងាយៗ តាមរូបភាព<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការសរសេរពាក្យងាយៗ តាមរូបភាព | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបធ្វើអក្ខរាវិរុទ្ធពាក្យផ្សេងៗ<br>**បំណិនសម្បទា**<br>- សរសេរពាក្យដែលមានព្យញ្ជនៈផ្សំស្រៈ ពាក្យប្រកប និងពាក្យផ្ញើជើងមួយចំនួន ដែលប្រើញឹកញាប់ ដោយធ្វើអក្ខរាវិរុទ្ធ<br>**ចរិយាសម្បទា**<br>- មានទម្លាប់ហាត់ធ្វើអក្ខរាវិរុទ្ធពាក្យ ដោយខ្លួនឯង | |
| | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីតួអក្សរទាំងអស់ តាមលំដាប់ នៅក្នុងពាក្យ ដែលមានតួអក្សរមិន អាន<br>**បំណិនសម្បទា**<br>- សរសេរពាក្យដែលមានតួអក្សរ(រ)មិនអាន(ឧ. ការ ដើរ) ដោយធ្វើអក្ខរាវិរុទ្ធ<br>**ចរិយាសម្បទា**<br>- មានទម្លាប់ហាត់ធ្វើអក្ខរាវិរុទ្ធពាក្យ ដោយខ្លួនឯង | |
